ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ
# (២០១១-២០១៥)
# ខេត្តកំពង់ស្ពឺ

ខែឧសភា ឆ្នាំ២០១១

# មាតិកា

ទំព័រ


មាតិកា.......i
សេចក្តីសម្រេចស្តីពី ការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខេត្ត.......iii
អារម្ភកថា.......v
សេចក្តីផ្តើម.......១
ផែនទីខេត្ត.......៤
**ជំពូកទី១ ÷ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច.......៥**
១.១.សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច.......៦
១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម.......៧
១.២.១.ស្ថានភាពសេដ្ឋកិច្ច.......៨
១.២.២.ស្ថានភាពសង្គមកិច្ច.......១៩
១.២.៣.ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន.....២៩
១.២.៤.ស្ថានភាពនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ......៣៥
១.២.៥.ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ.....៣៦
**ជំពូកទី២ ÷ ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត.......៤១**
២.១.ចក្ខុវិស័យអភិវឌ្ឍន៍.......៤២
២.២.គោលដៅអភិវឌ្ឍន៍.......៤២
២.៣.គោលបំណងអភិវឌ្ឍន៍.......៥២
២.៤.យុទ្ធសាស្ត្រអភិវឌ្ឍន៍.......៥៩
២.៤.១.យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច.......៥៩
២.៤.២.យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច.......៦៤
២.៤.៣.យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន...........៧០
២.៤.៤.យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ............៧៣
២.៤.៥.យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ...........៧៣
២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម.......៧៦
**ជំពូកទី៣ ÷ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍.........................៩០**
**ឧបសម្ព័ន្ធនានា**

ឧបសម្ព័ន្ធទី១ ៖ សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយសម្រាប់

ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**ឧបសម្ព័ន្ធទី២** ៖ រចនាសម្ព័ន្ធរដ្ឋបាលខេត្ត

**ឧបសម្ព័ន្ធទី៣** ៖ ប្រតិទិនការងារកសាងផែនការអភិវឌ្ឍន៍ខេត្ត

**ឧបសម្ព័ន្ធទី៤** ៖ របាយការណ៍ស្តីពីវឌ្ឍនភាពរបស់ខេត្ត ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា

**ឧបសម្ព័ន្ធទី៥** ៖ សេចក្តីសង្ខេបព័ត៌មានស្ថានភាព

**ឧបសម្ព័ន្ធទី៦** ៖ ផែនទីរដ្ឋបាលរបស់ខេត្ត

**ឧបសម្ព័ន្ធទី៧** ៖ ទម្រង់២.១៣ និងទម្រង់២.១៤

**ឧបសម្ព័ន្ធទី៨** ៖ របាយការណ៍សង្ខេប អំពីដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត ឬ កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាខេត្តក្នុងការពិនិត្យ និងអនុម័តផែនការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**

**ក្រុមប្រឹក្សាខេត្ត**

**លេខ ៖---------------**

# សេចក្តីសម្រេច

# ស្តីពី

# ការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០១១-២០១៥)

# របស់ខេត្តកំពង់ស្ពឺ

# ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ខេត្ត ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០៩/៦០២ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ក្នុងអណត្តិទី១
- យោងអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈ អភិបាលខេត្ត
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ខេត្ត ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពី ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីនៃកិច្ចប្រជុំលើកទី.........របស់ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ នាថ្ងៃទី.......... ខែ................. ឆ្នាំ២០១១។

# សម្រេច

**ប្រការ ១÷** ត្រូវបានដាក់ឲ្យប្រើប្រាស់នូវសៀវភៅផែនការអភិវឌ្ឍន៍០៥ឆ្នាំ (២០១១-២០១៥) របស់ខេត្តកំពង់ស្ពឺ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ នាកិច្ចប្រជុំសាមញ្ញលើកទី..... នាថ្ងៃទី...... ខែ........... ឆ្នាំ២០១១។

**ប្រការ២÷** គណៈអភិបាលខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះ ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ។ គណៈអភិបាល ត្រូវចាត់ចែងសម្របសម្រួល និងកៀរគរធនធាននានា ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍នេះ ប្រកបដោយការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

**ប្រការ៣÷** គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការ។ គណៈអភិបាលខេត្ត ត្រូវរៀបចំរបាយការណ៍ ស្ដីពីលទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ និង រាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខេត្ត អំពីវឌ្ឍនភាពនៃការអនុវត្តផែនការនេះ ទៅតាមកាលកំណត់។ គណៈអភិបាលខេត្ត ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សា អំពីរបាយការណ៍ប្រចាំឆ្នាំ ស្ដីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ។

**ប្រការ៤÷** គណៈអភិបាលខេត្ត ត្រូវធ្វើការវាយតម្លៃការអនុវត្ត ផែនការអភិវឌ្ឍន៍នេះ នៅពាក់កណ្ដាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីវាយតម្លៃអំពីលទ្ធផលសម្រេចបានធៀបនឹងគោលដៅ និងគោលបំណង ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត។

**ប្រការ៥÷** គណៈអភិបាលេខត្ត មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធទាំងអស់ក្នុងខេត្ត ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

កំពង់ស្ពឺ ថ្ងៃទី........ ខែ.....................ឆ្នាំ២០១១

**ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ**

**<u>ចម្លងជូន</u>**

*-ក្រសួងមហាផ្ទៃ*
*- ក្រសួងផែនការ*
*-លេខាធិការដ្ឋាន គ.ជ.អ.ប*
*(ដើម្បីជូនជ្រាប)*
*-ដូចក្នុងប្រការ៥*
*(ដើម្បីអនុវត្តន៍)*
*-ឯកសារកាលប្បវត្តិ*

# អារម្ភកថា

បន្ទាប់ពីងើបផុតពីសង្គ្រាមដ៏រ៉ាំរ៉ៃ ជាងពីរទសវត្សរ៍ ពិសេសរបបប៉ុលពត ដែលធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្តទាំងឡាយត្រូវបានបំផ្លាញខ្ទេចខ្ទីស្ទើរតែទាំងស្រុង និងផ្តើមចេញពីនយោបាយឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ថ្មីៗ ពិសេសលើកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជំរុញឲ្យដំណើរការ អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅមូលដ្ឋានមានការរីកដុះដាលជាបន្តបន្ទាប់ ក្នុងគោលបំណងសំដៅរួមចំណែកក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាព។

ទន្ទឹមនោះខេត្តកំពង់ស្ពឺ ក៏មានការរីកចម្រើនលើគ្រប់វិស័យ ធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កាន់តែល្អប្រសើរឡើងជាលំដាប់ តាមរយៈការកាត់បន្ថយបាននូវភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ដើម្បីចូលរួមចំណែកលើមាគ៌ាដ៏ត្រឹមត្រូវក្នុងការលើកកម្ពស់កិច្ចអភិវឌ្ឍន៍ និងការអនុវត្តលិទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានប្រកបដោយចីរភាព គណនេយ្យភាព និងតម្លាភាព ការកសាងផែនការអភិវឌ្ឍន៍រយៈពេលវែងមានភាពចាំបាច់បំផុត ដែលតម្រូវឲ្យមានការចូលរួមយ៉ាងពេញលេញពីសំណាក់ប្រជាពលរដ្ឋ។ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដែលរដ្ឋបាលខេត្តបានរៀបរៀងឡើងដោយសម្រិតសម្រាំងបំផុតនេះ មានផលប្រយោជន៍ណាស់ ក្នុងការចង្អុលទិសដៅក្នុងការកំណត់នូវចក្ខុវិស័យអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ និងគោលបំណងអភិវឌ្ឍន៍ច្បាស់លាស់ នឹងអាចក្លាយជាមូលដ្ឋានសម្រាប់ឆ្លើយតប នឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងសម្រាប់ឲ្យអង្គភាពស្ថាប័នបុគ្គលិកពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ទាំងអស់ ពិនិត្យពិចារណា និងចូលរួមផ្តល់វិភាគទានក្នុងការអនុវត្តឲ្យបានជោគជ័យ ដើម្បីជំរុញឲ្យវិស័យនានារបស់ខេត្តបន្តឆ្ពោះទៅរកការរីកចម្រើន ថែមទៀតរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរដ្ឋបាលខេត្តកំពង់ស្ពឺ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធពិសេស គ.ជ.អ.ប បណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត ការិយាល័យ អង្គការក្រៅរដ្ឋាភិបាលនិងវិស័យឯកជន លោក-លោកស្រីទាំងអស់ ដែលជាមន្ត្រីរាជការក្នុងដែនសមត្ថកិច្ចខេត្ត រដ្ឋបាលថ្នាក់ខេត្ត-ក្រុង-ស្រុក និងក្រុម

ប្រឹក្សាឃុំសង្កាត់ ដែលបានរួមចំណែកក្នុងការកសាងផែនការអភិវឌ្ឍន៍នេះឡើង។ រដ្ឋបាល ខេត្ត មានសង្ឃឹមយ៉ាងមុតមាំថា ផែនការអភិវឌ្ឍន៍នេះនឹងក្លាយជាឧបករណ៍ ដែលមានសារៈសំខាន់បំផុត សម្រាប់ឲ្យអ្នកពាក់ព័ន្ធទាំងអស់ប្រើប្រាស់ ដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខេត្តកំពង់ស្ពឺ ឲ្យមានការរីកចម្រើន ឆ្លើយតបបានសមស្របទៅនឹងតម្រូវការដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។

កំពង់ស្ពឺ ថ្ងៃទី.........ខែ......................ឆ្នាំ២០១១

**ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ**

# សេចក្ដីផ្ដើម

ខេត្តកំពង់ស្ពឺ ជាខេត្តមួយក្នុងចំណោម២៤រាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ហើយមានចម្ងាយ៤៨គីឡូម៉ែត្រ ខាងលិចរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកណ្ដាល និងតាកែវ ខាងត្បូងជាប់នឹងខេត្តតាកែវ និងខេត្តកំពត ខាងលិចជាប់នឹងខេត្តព្រះសីហនុ ខាងជើងជាប់នឹងខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់។

ខេត្តកំពង់ស្ពឺ ចែកជា៧ស្រុក ក្រុង១ និងមាន៨២ឃុំ និង៥សង្កាត់។ ភូមិមានចំនួន១,៣៧៣ ក្នុងនោះ ភូមិមានក្របខ័ណ្ឌចំនួន១,៣០៨ភូមិ មានផ្ទៃដីសរុប៦,៩៦៩.៧១៩គីឡូម៉ែត្រការ៉េ មានប្រជាពលរដ្ឋសរុបចំនួន៧៦៥,៣០២នាក់ មានគ្រួសារចំនួន១៥១,៣៩១គ្រួសារ ក្នុងនោះគ្រួសារប្រកបរបរកសិកម្មមានចំនួន៩២.០៦% និងមានដង់ស៊ីតេប្រជាពលរដ្ឋ១០៩នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ វិស័យកសិកម្មដែលជាវិស័យស្នូល និងវិស័យចម្បងផ្សេងៗទៀតដូចជា វិស័យធនធានទឹក វិស័យអប់រំ វិស័យសុខាភិបាល ការងារប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ...។ល។

បន្ទាប់ពីការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២ របស់រាជរដ្ឋាភិបាល កំណែទម្រង់ជាច្រើនត្រូវដាក់ចេញដោយរាជរដ្ឋាភិបាល ក្នុងនោះអភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រដែលមានចំណុចសំខាន់៤ គឺការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ អាស្រ័យដោយមានការផ្លាស់ប្ដូរគោលនយោបាយនេះ យើងឃើញថា កំណែទម្រង់រដ្ឋបាលសាធារណៈនេះ បានធ្វើឲ្យការគ្រប់គ្រងរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជា មានការប្រែប្រួលទាំងស្រុង ពិសេសច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតឲ្យមានអង្គក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដែលកើតឡើងដោយការបោះឆ្នោតជាសកលពីសំណាក់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងអសកលតាមរយៈឃុំ-សង្កាត់។ នៅថ្នាក់ឃុំ-សង្កាត់ ក្រោយដំណើរការបោះឆ្នោត យើងឃើញថា ឃុំ-សង្កាត់ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសការឆ្លើយតបនូវតម្រូវការរបស់ប្រជាពលរដ្ឋនូវថ្នាក់មូលដ្ឋាន ការពង្រឹងនូវការផ្ដល់សេវាសាធារណៈ ការផ្ដល់នូវភាពជាម្ចាស់ពេញលេញជូនប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។ កំណែទម្រង់រដ្ឋបាលសាធារណៈ និងការអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជា វិស័យការងារជាច្រើននៅក្នុងថ្នាក់រដ្ឋបាលខេត្ត មានការវិវត្តរីកចម្រើនគួរឲ្យមានមោទនភាព ដូចជាវិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល វិស័យសាធារណៈការ និងដឹកជញ្ជូន វិស័យអភិវឌ្ឍន៍ជនបទ វិស័យធនធានទឹក..។ល។ វិស័យទាំងនេះបានរួមចំណែកឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋធ្វើ

ឲ្យជីវភាពរស់នៅរបស់គាត់កាន់តែល្អប្រសើរ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈម និងតម្រូវការមួយចំនួនដែលទាមទារឲ្យមានការឆ្លើយតបបានត្រឹមត្រូវទាន់ពេល និងមានប្រសិទ្ធភាពពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ទើបគោលនយោបាយជាយុទ្ធសាស្ត្រទាំងឡាយរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព។

រដ្ឋបាលខេត្តដែលបានប្រសូត្រចេញពីច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីភារកិច្ចមុខងារ និងកាតព្វកិច្ចជាច្រើនដែលត្រូវបំពេញ ឲ្យខានតែបានក្នុងកាតព្វកិច្ចជាចំបងមុនគេ គឺការកសាងផែនកាអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅដើមអាណត្តិទី១ របស់ខ្លួនឲ្យស្របតាមអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យលេខ២១៩ អនក្រ.បក និងប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌលេខ២៥១៧ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១។

គោលបំណងសំខាន់នៃផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនេះសម្រាប់ធ្វើជាមូលដ្ឋាន ក្នុងការចាត់ចែងអនុវត្តស្របតាមចក្ខុវិស័យរួម ដែលមានក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលដៅ និងគោលបំណងរបស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការដែលមានយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ក្នុងបរិបទនៃការពង្រឹងលិទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

ក្នុងរយៈពេលដ៏ខ្លីមួយ ដើម្បីរួមចំណែកបំពេញកាតព្វកិច្ច ដែលច្បាប់បានកំណត់ផែនការនេះបានដំណើរការយ៉ាងមមាញឹក ក្រោយពីកិច្ចប្រជុំណែនាំស្តីពី ដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត នាថ្ងៃទី១-៤ ខែមីនា ឆ្នាំ២០១១។ វគ្គបណ្តុះបណ្តាលជូនអង្គភាព មន្ត្រីរាជការសង្គមស៊ីវិល និងផ្នែកឯកជនពាក់ព័ន្ធ បានប្រព្រឹត្តិទៅជាបន្ទាន់ដែរ។ បន្ទាប់ពីនោះ ដំណើរការត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន ទៅតាមប្រតិទិន មួយដ៏ជាក់លាក់តាមជំហានដូចខាងក្រោមៈ

. ការត្រួតពិនិត្យ និងបំពេញតារាងពាក់ព័ន្ធនានា

. ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍

. ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍

. ការប្រជុំវិភាគស្ថានភាពខេត្តលើគ្រប់វិស័យ

. ការផ្ញើសេចក្តីព្រាងផែនការជូនអ្នកពាក់ព័ន្ធនានា ដូចជាតំណាងប្រជាពលរដ្ឋ សង្គមស៊ីវិល

ផ្នែកឯកជន គណៈអភិបាលខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីសុំការពិគ្រោះយោបល់បំពេញបន្ថែម។ ចុងក្រោយនៃផែនការអភិវឌ្ឍន៍ខេត្ត ត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាខេត្ត នាសម័យប្រជុំលើកទី២៤ នាថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១១។

ទោះបីផែនការអភិវឌ្ឍន៍នេះ បានកសាងឡើងក្នុងរយៈពេលខ្លី និងពុំទាន់បានប្រមូលព័ត៌មានទិន្នន័យគ្រប់ជ្រុងជ្រោយក៏ដោយ និងស្របពេលដែលមន្ត្រីរាជការ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់របស់រដ្ឋបាលខេត្ត មានសមត្ថភាពនៅមានកម្រិត និងមានពេលវេលាមិនគ្រប់គ្រាន់ក៏ដោយ តែយើងខ្ញុំសង្ឃឹមថា ផែនការអភិវឌ្ឍន៍នេះ នឹងក្លាយជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញផ្លូវឲ្យរដ្ឋបាលខេត្តចាត់តាំងអនុវត្តតាមជំហាននីមួយៗសំដៅដោះស្រាយបញ្ហាប្រឈម តម្រូវការ និងសំណូមពរនានាសំដៅលើកកម្ពស់សេវាកម្មសាធារណៈនានា រួមចំណែកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ផែនការអភិវឌ្ឍន៍៥ឆ្នាំ (២០១១-២០១៥) របស់ខេត្តមានបីជំពូក ជំពូកទី១ បរិយាយពីស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ជំពូកទី២ បរិយាយអំពីក្របខ័ណ្ឌអភិវឌ្ឍន៍ និងជំពូកទី៣ បរិយាយអំពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអនុវត្តផែនការអភិវឌ្ឍន៍សម្រាប់រយៈពេល៥ឆ្នាំខាងមុខ៕

ធ្វើនៅកំពង់ស្ពឺ ខែឧសភា ឆ្នាំ២០១១

# ផែនទី ខេត្តកំពង់ស្ពឺ

# Kampong Speu Map



# ជំពូកទី ១

## ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច

# ជំពូកទី១

## ១. ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច

## ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ច

### ព័ត៌មានសំខាន់ៗក្នុងខេត្តកំពង់ស្ពឺ

| បរិយាយ | ឯកតា | ឆ្នាំ២០១០ |
|---|---|---|
| ផ្ទៃដីខេត្ត | គម២ | ៦,៩៦៩.៧១៩ |
| ផ្ទៃដីស្រែ | ហិចតា | ១១០,០០០ |
| ផ្ទៃដីចំការ | ហិចតា | ១០,២០២ |
| ផ្ទៃដីលំនៅដ្ឋាន | ហិចតា | ១១,៩៩៦ |
| ផ្ទៃដីព្រៃភ្នំ និងធារាសាស្ត្រ | ហិចតា | ៥៦៤,៣៦៥ |
| ផ្ទៃដីទំនេរ | ហិចតា | ៤០៨,៩២៩ |
| ចំនួនស្រុក-ក្រុង | ស្រុក ក្រុង | ៨ |
| ចំនួនឃុំ-សង្កាត់ | ឃុំ-សង្កាត់ | ៨៧ |
| ចំនួនភូមិសរុប | ភូមិ | ១,៣៧៣ |
| ចំនួនភូមិមាន ក្របខ័ណ្ឌ | ភូមិ | ១,៣០៨ |
| ចំនួនប្រជាពលរដ្ឋសរុប | នាក់ | ៧៦៥,៣០២ |
| កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ | % | ២ |
| ចំនួនគ្រួសារសរុប | គ្រួសារ | ១៥១,៣៩១ |
| អត្រាមេគ្រួសារជាស្ត្រី | % | ១៤.៨០ |
| អត្រាគ្រួសារមានមុខរបរកសិករជាចម្បង | % | ៩២.០៦ |
| អត្រាកុមារអាយុ ៦-១៤ ឆ្នាំមិនបានចូលរៀន | % | ១៦.៨៣ |
| អត្រាអ្នកមិនចេះអក្សរអាយុពី ១៥-៦០ ឆ្នាំ | % | ៥.៧៩ |
| អត្រាស្ត្រីមិនចេះអក្សរអាយុពី ១៥ -៦០ ឆ្នាំ | % | ៣.០៦ |
| ចំនួនស្ត្រីសម្រាលកូនដោយពេទ្យឆ្មបសរុប | នាក់ | ១១,៥៧២ |
| មរណភាពមាតាក្នុង១០ម៉ឺនកំណើតក្រោយពេលសម្រាលកូនពី ០-១ ខែ | នាក់ | ៤៧ |
| មរណភាពទារកអាយុ ពី ០-១ ខែ | នាក់ | ៩៨ |
| អត្រាគ្រួសារប្រើប្រាស់ទឹកម៉ាស៊ីន | % | ៤.៨៤ |
| អាត្រាគ្រួសារប្រើប្រាស់អណ្តូងទឹកស្អាត | % | ៤៦.៧៨ |
| សមាមាត្រគ្រួសារគ្មានបង្គន់អនាម័យប្រើប្រាស់ | % | ៧៨.៥២ |

## ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ខេត្តកំពង់ស្ពឺ ជាខេត្តមួយដែលស្ថិតនៅភាគខាងលិចរាជធានីភ្នំពេញ ប្រមាណជា៤៨គីឡូម៉ែត្រ ដែលឆ្លងកាត់ដោយផ្លូវជាតិលេខ៤។ យោងតាមលក្ខណៈភូមិសាស្ត្រ ខេត្តកំពង់ស្ពឺចែកចេញជា៧ស្រុក និងក្រុងចំនួន១ រួមមាន៨២ឃុំ និង៥សង្កាត់ ដែលមានចំនួន១,៣៧៣ភូមិ ក្នុងនោះភូមិមានក្រុមខ័ណ្ឌ១,៣០៨ និងមានប្រជាពលរដ្ឋរស់នៅចំនួន១៥១,៣៩១គ្រួសារ ហើយមានមនុស្សសរុបចំនួន៧៦៥,៣០២នាក់ ក្នុងនោះស្រីចំនួន៣៩២,៨៨៦នាក់។ ដង់ស៊ីតេប្រជាពលរដ្ឋ១០៩នាក់ក្នុងមួយគីឡូមែត្រការ៉េ និងមានទំហំគ្រួសារជាមធ្យម៥នាក់។ ជាងនេះទៅទៀត ខេត្តមានផ្ទៃដីស្រែចំនួន១១០,០០០ហិចតា ផ្ទៃដីចំការចំនួន១០,២០២ហិចតា សម្រាប់បង្កើតរបរកសិកម្មផងដែរ។ ប្រជាពលរដ្ឋមានកំណើនមធ្យមចំនួន២% ក្នុងឆ្នាំ២០១០ កំណើននេះឃើញថាមានលក្ខណៈសមរម្យអាចទទួលយកបាន។

ផ្ទៃដីរបស់ខេត្ត ប៉ែកខាងលិចគ្របដណ្តប់ដោយជួរភ្នំក្រវាញដែលជាហេតុធ្វើឲ្យខេត្ត ខ្សត់ទឹកភ្លៀង ដោយសារខ្យល់ និងកម្ពស់ជួរភ្នំក្រវាញ ដែលបាននាំទឹកភ្លៀងអស់មួយចំនួនធំ ប៉ុន្តែខេត្តអាចជៀសវាងបានយ៉ាងងាយពីការប៉ះទង្គិចដោយខ្យល់ព្យុះ។ ភាគខាងជើងគ្របដណ្តប់ដោយតំបន់ទំនាបសម្បូរទៅដោយដីមានជីជាតិ ដែលបង្កលក្ខណៈងាយស្រួល ដល់ការងារបង្កបង្កើនផលកសិកម្ម ពិសេសដំណាំស្រូវ និងដំណាំចម្រុះផ្សេងៗទៀត។ ម្យ៉ាងទៀតស្ទឹងព្រែកត្នោតជាស្ទឹងមួយដែលហូរកាត់ខេត្តកំពង់ស្ពឺ បាននាំនូវប្រភពទឹកមកស្រោចស្រពដីទំនាបទាំងឡាយ ដែលកត្តាទាំងនេះហើយ ដែលនាំឲ្យចំនួនប្រជាកសិករមានរហូតដល់៩២.០៦% ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ផ្ទៃដីខេត្តទាំងមូល ទទួលបាននូវកម្រិតទឹកភ្លៀងតិចជាងបណ្តាខេត្តផ្សេងៗទៀតដោយសារខេត្តខ្វះខាតប្រភពទឹកមេ និងប្រព័ន្ធប្រឡាយចែកចាយខ្វាតតូចសម្រាប់ធ្វើការស្រោចស្រព។

ស្រុកសំរោងទង និងក្រុងច្បារមន ស្ថិតនៅក្នុងតំបន់កណ្តាលនៃខេត្ត ហើយប្រជាពលរដ្ឋមួយចំនួនប្រកបរបរលក់ដូរ មួយចំនួនទៀតជាមន្ត្រីរាជការ និងរបរផ្សេងៗទៀត។ ស្រុកទាំងពីរនេះជាទីតាំងមួយដ៏សំខាន់ដែលមានសក្តានុពលខាងវិស័យកាត់ដេរ សហគ្រាសធន់តូច និងមធ្យមសិប្បកម្ម និងអាជីវកម្មធំតូចផ្សេងៗទៀតផងដែរ។ ស្រុកឱរ៉ាល ស្រុកថ្ពង និងស្រុកភ្នំស្រួច ផ្ទៃដីមួយភាគធំគ្របដណ្តប់ដោយព្រៃឈើ និងមានភ្នំរាយប៉ាយ ហើយក៏ជាតំបន់ដែលមានជីជាតិល្អ សម្រាប់ការប្រកបរបរកសិកម្ម អាជីវកម្មថ្ម-រ៉ែក្រោមដី ការដកយកអនុផលព្រៃឈើ និងជាតំបន់ដែលមានសក្តានុពលខាងវិស័យកសិ-ឧស្សាហកម្ម(ដូងប្រេង ពោត អំពៅ..) និងកសិដ្ឋានចិញ្ចឹមសត្វធំតូចផងដែរ។ ចំណែកស្រុកគងពិសី ស្រុកឧដុង្គ និងស្រុកបរសេដ្ឋ ប្រជាពលរដ្ឋភាគច្រើន ប្រកបរបរកសិកម្មការដាំដំណាំរួមផ្សំ និងមុខរបរបន្ទាប់បន្សំប៉ុណ្ណោះ ព្រោះស្រុកទាំងនេះមានទីតាំងភូមិសាស្ត្រ ជាតំបន់ទំនាប និងមានជួរភ្នំព័ទ្ធជុំវិញ ហើយក៏ឧស្សាហ៍ជួបគ្រោះរាំងស្ងួតផងដែរ។ ក្រៅពីនេះ ស្រុក

ទាំងបីមានលក្ខណៈអំណោយផលលើមុខរបរឡើងត្នោត ពិសេសស្រុកឧដុង្គ មុខរបរនេះត្រូវបានគេយកចិត្តទុកដាក់។ បច្ចុប្បន្ននេះ ផលិតផលស្ករត្នោតត្រូវបានគេកែឆ្នៃជាម្សៅ ហើយធ្វើការនាំចេញទៅក្រៅប្រទេស និងទីផ្សារក្នុងស្រុកដោយតម្លៃខ្ពស់ ព្រោះតែរសជាតិដ៏ផ្អែមឈ្ងុយឆ្ងាញ់របស់វា។

## ១.២.១. ស្ថានភាពសេដ្ឋកិច្ច

ដើម្បីជំរុញក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តទាំងឡាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធដល់ការលើកកម្ពស់គុណភាព ប្រសិទ្ធភាពក្នុងផ្នែកសេដ្ឋកិច្ច ពិសេសការជំរុញការបង្កើនផលិតកម្មស្រូវនិងការនាំចេញអង្ករទៅកាន់ទីផ្សារបរទេសរបស់រាជរដ្ឋាភិបាល។ គោលនយោបាយសំខាន់ៗរបស់រដ្ឋបាលខេត្ត បានចាត់តាំងអនុវត្តដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខាងបានប្រសើរឡើង បើទោះបីខេត្តមានបញ្ហាច្រើនកំពុងជួបប្រទះក្នុងស្ថានភាពសេដ្ឋកិច្ចនាពេលចប្បុប្បន្ន ដែលទាមទារការដោះស្រាយជាបន្តបន្ទាប់។ ស្ថានភាពសេដ្ឋកិច្ចនេះ ត្រូវស្តែងចេញតាមវិស័យនីមួយៗដូចខាងក្រោមៈ

### ១.២.១.១ វិស័យកសិកម្ម

វិស័យកសិកម្ម ជាវិស័យអាទិភាពរបស់ខេត្ត ហើយខេត្តមានកសិកររហូតដល់៩២.០៦% នៃចំនួនប្រជាពលរដ្ឋសរុប។ ដូចនេះបញ្ហាកសិកម្ម គឺជាបញ្ហាអាទិភាព ដែលរដ្ឋបាលខេត្តត្រូវយកចិត្តទុកដាក់បំផុតក្នុងផ្នែកសេដ្ឋកិច្ច។

### ក. ការបង្កបង្កើនផលស្រូវប្រាំង និងវស្សា

បើប្រៀបធៀបរវាងឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ ពិនិត្យឃើញថា ការងារបង្កបង្កើនផលស្រូវប្រាំង ផ្ទៃដីដែលអនុវត្តបានមានចំនួន១៩១ហិចតាឆ្នាំ២០០៨ និងមានចំនួន៦០៩ហិចតាឆ្នាំ២០១០ កើនបាន៥.៧០% សម្រាប់ស្រូវដើមរដូវ និងស្រូវប្រាំង មានការថយចុះពីចំនួន៣,១០៨ហិចតា មកត្រឹមតែ១,០៣៧ហិចតា គឺថយចុះ៩.៤៣%បើប្រៀបធៀបសម្រាប់ឆ្នាំ២០០៩-២០១០។ ទិន្នផលមធ្យមសម្រាប់ស្រូវប្រាំងមានចំនួន២.៦០តោន/ហ.តសម្រាប់ឆ្នាំ២០០៨ ចំនួន២.២៧៥តោន/ហតសម្រាប់ឆ្នាំ២០០៩ និងចំនួន៣.១៩៤តោន/ហ.ត ក្នុងឆ្នាំ២០១០។ ស្រូវវស្សាមានចំនួន២.៣៣៥តោន/ហ.តក្នុងឆ្នាំ២០០៨ ២.៤១៦តោន/ហ.តក្នុងឆ្នាំ២០០៩ និងចំនួន២.៦៩០តោន/ហ.ត ក្នុងឆ្នាំ២០១០ ដែលសរុបមកទាំងប្រាំង និងវស្សាកើនបាន១៥.២០% សម្រាប់ឆ្នាំ២០០៨-២០១០។ ក្នុងចន្លោះឆ្នាំ២០០៨ដល់ឆ្នាំ២០១០ ផ្ទៃដីខូចខាតទាំងស្រុងទាំងប្រាំង និងវស្សាមានចំនួន៦១ហ.តក្នុងឆ្នាំ២០០៨ ចំនួន៣៣៦ហតក្នុងឆ្នាំ២០០៩ និងចំនួន២២៣ហិចតាក្នុងឆ្នាំ២០១០។ បរិមាណស្បៀងសល់ជាអង្ករទាំងប្រាំង និងវស្សាមានចំនួន៣៣,២៤៦តោនក្នុងឆ្នាំ២០០៨ ចំនួន៤៥,៧១៨តោន ក្នុងឆ្នាំ២០០៩ និងចំនួន៥៧,៤៤៥តោនក្នុងឆ្នាំ២០១០ស្មើនឹង៧២.៧៩% បើប្រៀបធៀបសម្រាប់ឆ្នាំ២០០៨-២០១០។ បរិមាណស្បៀងសល់ជាស្រូវទាំងប្រាំងនិងវស្សាមានចំនួន៥១,៩៤៧

តោន ក្នុងឆ្នាំ២០០៨ ៧១,៨៣៩តោនក្នុងឆ្នាំ២០០៩ និង៨៩,៧៥៧តោនក្នុងឆ្នាំ២០១០ កើនបាន ៧២.៧៩% ដែរបើប្រៀបធៀបសម្រាប់ឆ្នាំ២០០៨-២០១០។

ជាលទ្ធផល យើងពិនិត្យមើលយើងឃើញថា ទិន្នផលស្រូវប្រាំងបានកើនឡើង ដែលនេះអាចបណ្តាលមកពីបរិមាណផ្ទៃដីអនុវត្ត និងផ្ទៃដីប្រមូលផលសរុប នៃការបង្កបង្កើនផលកសិកម្មមានការកើនឡើងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធនៃការស្តុកទឹកស្រោចស្រព នៅមានកម្រិតតិចតួចដែលប៉ះពាល់ដល់ផ្ទៃដីស្រូវប្រាំង ចំណែកឯផ្ទៃដី និងបរិមាណស្រូវវស្សាមានការប៉ះពាល់ដែរ បើទោះបីមានប្រឡាយមេសំខាន់ៗក្នុងតំបន់អភិវឌ្ឍន៍ចម្រុះខាងលិច និងខាងជើងរាជធានីភ្នំពេញ ដែលកសាងឡើងដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ហើយអាចនាំទឹកស្រោចស្រពដល់ស្រុក និងទីប្រជុំជនមួយចំនួនដូចជា ក្រុងច្បារមន ស្រុកសំរោងទង ស្រុកគងពិសី ស្រុកថ្ពង ស្រុកឱរ៉ាល់ និងស្រុកឧដុង្គក៏ដោយ។

### ខ. ការចិញ្ចឹមសត្វ និងដំណាំរួមផ្សំ

ការចិញ្ចឹមសត្វក៏ជាកត្តាដ៏សំខាន់របស់ការងារកសិកម្ម ពិសេសដើម្បីផ្គត់ផ្គង់ម្ហូបអាហារ និងលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋក្នុងខេត្ត ជាលទ្ធផល គ្រួសារចិញ្ចឹមគោក្របីសរុបមានចំនួន១២១,១២០គ្រួសារក្នុងឆ្នាំ២០០៩ ចំនួនគ្រួសារដែលប្រើប្រាស់គោក្របីជាកំលាំងអូសទាញមានចំនួន៩៩,២៤២នៃចំនួនគ្រួសារសរុបទូទាំងខេត្ត ហើយចំនួនគោរក្របីសរុប៣៦៦,១៨៤ក្បាលក្នុងឆ្នាំ២០០៧ កើនឡើងដល់៤០១,៩៨២ក្បាលនាឆ្នាំ២០០៩ ការចិញ្ចឹមគោរជាលក្ខណៈកសិដ្ឋានមានការកើនឡើងនាឆ្នាំ២០០៩ និង២០១០។ ការចិញ្ចឹមសត្វជ្រូកមានការថយចុះពី៤០.០២%មកត្រឹម៣១.២៧%នាឆ្នាំ២០០៩។ យើងមានគ្រួសារចំនួន៤៧,៣៣៥គ្រួសារដែលចិញ្ចឹមជ្រូក ក្នុងនោះដែរ ការចិញ្ចឹមជាលក្ខណៈកសិដ្ឋានក្នុងខេត្តមានការថយពីឆ្នាំ២០០៧-២០០៩ គឺពី១២១កន្លែង មកត្រឹម៨៣កន្លែង។ ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ មានចំនួនសរុប១២៨,០៦៥គ្រួសារ។ គ្រួសារដែលមានមាន់លើសពី០៣ក្បាលមានចំនួន១០០,០៩៩គ្រួសារ មានការប្រែប្រួលពី៨៣.៤៣% ទៅ៨៤.៥៩%នាឆ្នាំ២០០៩ ចំណែកការចិញ្ចឹមមាន់ជាលក្ខណៈកសិដ្ឋានមានការថយចុ។ ឯចំនួនគ្រួសារចិញ្ចឹមទាក៏មានការថយចុះដែរពី៨.២៧%មកនូវត្រឹម៧.៦៦% ស្មើនឹង១១,៥៨៩គ្រួសារនាចុងឆ្នាំ២០០៩នេះ ចំណែកឯកសិដ្ឋានថយចុះពីចំនួន២៣កន្លែង មកនូវត្រឹម៩កន្លែង។

ដំណាំរួមផ្សំនានា ដូចជាដំណាំពោតផ្ទៃដីពោត មានចំនួន១២១៧.៩ ហិចតាក្នុងឆ្នាំ២០០៧ មានការថយចុះត្រឹម៧៦១.៩ហិចតា ក្នុងឆ្នាំ២០០៩ ចំណែកឯទិន្នផល ក៏មានការថយចុះពីចំនួន១,៩៧៨.០តោន មកនូវត្រឹម១,០២៦តោននាឆ្នាំ២០០៩ ផ្ទៃដីសម្រាប់ការដាំសណ្តែកបាយ១,២៧១ហិចតានាឆ្នាំ២០០៧ កើនឡើងដល់១,៧៤៧.៧ហិចតានាឆ្នាំ២០០៩ ហើយទិន្នផលមានការកើនឡើង១,៥៤៣.៧តោន ទៅ២,២៧៣.៩តោន ចំណែកការដាំដំឡូងមី ផ្ទៃដីការដំណាំដុះមានការកើនឡើង៥៩៨.៥០ហិចតាដល់ ១,៥២២.៥០ហិចតា បានដាំដុះជាមធ្យម៣តោនក្នុង១ហិចតា។

ក្នុងមួយឆ្នាំៗ ការដាំបន្លែគ្រប់មុខមានការថយចុះវិញចំនួន៣៧.៦៤% បើប្រៀបធៀបសម្រាប់ឆ្នាំ ២០០៨-២០១០។ ការដាំដំណាំឪឡឹកក៏មានការថយចុះផងដែរប្រមាណ៥.៦៨% ប៉ុន្តែទិន្នផល នៅតិចតួចគ្រាន់សម្រាប់តែផ្គត់ផ្គង់ជីវភាពប៉ុណ្ណោះ។

ជារួមយើងពិនិត្យឃើញថា បរិមាណនៃការចិញ្ចឹមសត្វមានការថយចុះបើប្រៀបធៀប ក្នុងឆ្នាំ ២០០៧ ដោយសារមូលហេតុផ្សេងៗដូចជា តម្លៃក្នុងទីផ្សារមានការធ្លាក់ចុះ ចំណីសត្វឡើងថ្លៃ ពិសេសមានការប្រកួតប្រជែងតម្លៃជាមួយផលិតផលសត្វ ដែលនាំចូលពីក្រៅប្រទេស ចំណែកឯ ការបង្កបង្កើនផលដំណាំរួមផ្សំមានការកើនឡើង ពិសេសអំពៅ ពោត និងដំឡូងជី និងដំណាំកសិ-ឧស្សាហកម្ម។

### គ. ការងារជលផល

យោងតាមការជាក់ស្តែងដែលបានវិភាគក្នុងវិភាគស្ថានភាពខេត្ត យើងឃើញថា ខេត្តកំពង់ស្ពឺ គ្មានទន្លេ ឬសមុទ្រឡើយ ហើយវិស័យជលផលក៏គ្រាន់តែសម្រាប់ផ្គត់ផ្គង់ម្ហូបអាហារក្នុងគ្រួសារ។ តែជារួម មានស្រះចិញ្ចឹមត្រីកើនឡើងពី២,០៧៥គ្រួសារ រហូតដល់២,៧១៦គ្រួសារ។

ចលនាចិញ្ចឹមត្រី និងការលែងត្រីក្នុងបឹងធម្មជាតិត្រូវបានចាប់ផ្តើមមានសកម្មភាពជាបណ្តើរៗ ដោយមានការគាំទ្រពីគម្រោងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាពរស់នៅថ្នាក់ឃុំទាំង៨២ លើ ៨៧ឃុំ-សង្កាត់ ក្នុងនោះឃុំនីមួយៗ បានទទួលថវិកាចំនួន៤,០០០ ទៅ៦,០០០ ដុល្លារ និងគម្រោង ពង្រឹងតួនាទីថ្នាក់ស្រុក ដែលផ្តល់ថវិកាចំនួន៣០,០០០ដុល្លារអាមេរិច ហើយថវិកាទាំងអស់នេះ បានទទួលការគាំទ្រប្រភពជានីជារបស់ប្រទេសដាណឺម៉ាក់ ដោយមានកិច្ចសហការល្អពីខណ្ឌរដ្ឋ បាលជលផល អាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋ។

កត់សម្គាល់ឃើញថា ការបង្កើនផលិតភាពវិស័យកសិកម្ម ត្រូវបានលើកកម្ពស់ និងបច្ចេក វិទ្យាត្រូវបានបញ្ចូលទៅក្នុងការធ្វើពិពិធកម្មដំណាំ តាមប្រព័ន្ធកសិកម្ម ដោយបានប្រែក្លាយពីការធ្វើ ដំណាំស្រូវតែមួយមុខក្នុង១ឆ្នាំតែ១ដង មកជាការធ្វើ២ ឬ៣ដងក្នុងមួយឆ្នាំដោយការធ្វើស្រូវ ឬដំណាំ ចម្រុះ និងការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ដែលមានការកំណត់នូវប្រភេទដី ប្រភេទដំណាំ និងវិធី សាស្ត្រ ដាំដុះសមស្រប។

ការប្រែប្រួលនេះ កើតឡើងដោយមានការផ្សព្វផ្សាយនូវចំណេះដឹងបច្ចេកវិទ្យា តាមរយៈការ ធ្វើឲ្យប្រសើរឡើង នូវការផ្សារភ្ជាប់រវាងការស្រាវជ្រាវ និងការផ្សព្វផ្សាយតាមរូបភាព ការអភិវឌ្ឍ សមត្ថភាពធនធានមនុស្សក្នុងនោះរួមមាន ទិវាស្រែកសិករ សិក្ខាសាលា អង្គប្រជុំវគ្គបណ្តុះបណ្តាល រយៈពេលខ្លី និងមធ្យមជាបន្តបន្ទាប់គួបផ្សំ និងកម្រិតភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ។

ទោះបីមានវឌ្ឍនភាព ដូចបានរៀបរាប់ខាងលើក៏ដោយ ក៏វិស័យនេះនៅមានបញ្ហាប្រឈម មួយចំនួនដូចខាងក្រោម៖

- ការបង្កើនផលិតភាពដំណាំស្រូវ និងដំណាំផ្សេងៗ នៅមានកម្រិតដោយលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេស និងការគាំទ្រឥណទាន និងកត្តាផលិតកម្មមានតិចតួច លទ្ធភាពទទួលបានការស្រោចស្រពនៅមានកម្រិត ទន្ទឹមនឹងកង្វះខាតការយល់ដឹងរបស់កសិករក្នុងការប្រើប្រាស់កត្តាផលិតកម្មកសិកម្ម ការគ្រប់គ្រងបច្ចេកទេស និងការកែប្រែគុណភាពដី
- ការបង្កើតយន្តការនានានៅថ្នាក់មូលដ្ឋាន ដែលអាចផ្តល់បច្ចេកទេស និងសេវាកម្មដល់កសិករដោយផ្ទាល់ពុំទាន់អនុវត្តបានល្អ
- ចលនាចិញ្ចឹមសត្វនៅមានលក្ខណៈតូចចង្អៀត ស្របពេលដែលការទប់ស្កាត់ ជម្ងឺរាតត្បាតនានា មកលើសត្វពុំទាន់មានប្រសិទ្ធភាពខ្ពស់ ទន្ទឹមនឹងចំណីសត្វមានតម្លៃខ្ពស់ គួបផ្សំនឹងប្រជាពលរដ្ឋភាគច្រើនពុំទាន់ចេះច្នៃប្រឌិតរកចំណីបន្ថែមទៀត ដែលពួកគាត់អាចមានលទ្ធភាពរកបាននៅមូលដ្ឋាន
- ចលនាចិញ្ចឹមត្រីបានចាប់ផ្តើមដោយយឺតយ៉ាវ និងពុំទាន់មានជំនឿចិត្ត ស្របពេលដែលការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលចំណេះដឹងពុំទាន់បានទូលំទូលាយ។
- ការវិនិយោគរោងម៉ាស៊ីនកែច្នៃស្រូវ ដែលមានលក្ខណៈទំនើប ហើយមានការសន្សំសំចៃនៅមានកម្រិតទាប
- កំណើនប្រជាពលរដ្ឋ សមាជិកគ្រួសារកើនឡើង ធ្វើឲ្យខ្វះខាតដីកសិកម្ម
- ផលិតកម្មដំណាំស្រូវ ជួបឧបសគ្គធ្ងន់ធ្ងរ ពិសេសគ្រោះរាំងស្ងួត
- ដីភាគច្រើនខ្សត់ជីជាតិ ប្រព័ន្ធប្រឡាយស្រោចស្រពមានតិចតួច
- សេវាកម្មផ្សព្វផ្សាយនៅមានកម្រិត
- ការគាំទ្រផ្នែកឥណទាននៅខ្សោយ
- ប្រជាពលរដ្ឋមានចំណេះដឹងទាប ដែលធ្វើឲ្យពួកគាត់មិនអាចទទួលយកបាននូវបច្ចេកទេសថ្មីៗ។

### ១.២.១.២ វិស័យធនធានទឹក

វឌ្ឍនភាពក្នុងវិស័យធនធានទឹកក្នុងខេត្ត មានការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធស្រោចស្រព បានផ្តល់នូវកំណើនផ្ទៃស្រោចស្រព និងកំណើនទិន្នផលដំណាំកសិកម្មព្រមទាំងបានផ្តល់នូវការការពារពីគ្រោះមហន្តរាយដោយធម្មជាតិ(គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់)កាន់តែមានប្រសិទ្ធភាព។ ទូទាំងខេត្ត មានប្រព័ន្ធស្រោចស្រពសរុប៣៧៤ប្រព័ន្ធ ក្នុងនោះប្រព័ន្ធបានស្តារហើយមានចំនួន៨៧ប្រព័ន្ធ ។ ប្រព័ន្ធស្រោចស្រពខ្នាតធំដែលបានស្តារហើយ គឺប្រព័ន្ធស្រោចស្រពរលាំងជ្រៃ ដែលស្រោចស្រពលើតំបន់កណ្តាលនៃខេត្តមាន(ស្រុកសំរោងទង ក្រុងច្បារមន និងស្រុកគងពិសី) ប្រព័ន្ធស្រោចស្រពពាមពូល ដែលស្រោចស្រពផ្នែកខាងលិចនៃខេត្ត (ភ្នំស្រួច) ប្រព័ន្ធស្រោចស្រពអន្លង់ជ្រៃ ប្រាំបីមុំ និងចាន់ថ្នាល ដែលអាចស្រោចស្រពនៅផ្នែកខាងជើងនៃខេត្ត (ស្រុកថ្ពង និងឧដុង្គ) ដែលបានដំណើការចប់រួចរាល់ និងសំណង់ប្រព័ន្ធស្រោចស្រពស្វាយ (កំពុងស្តារប្រព័ន្ធ

ប្រឡាយដែលបញ្ចប់ក្នុងឆ្នាំ២០១១) ប្រព័ន្ធស្រោចស្រពអូរគ្រែង ខ្ពបគ្រួស តានួន-តាដែង អង្គតាកិប ដែលអាចដំណើការស្រោចស្រពបាននៅផ្នែកខាងត្បូងនៃខេត្ត។ សំណង់សិល្បការ ដែលបានកសាង និងស្តារសរុបមាន២៦៩កន្លែង សំណង់បង្ហៀរ១៧កន្លែង ទ្វារទឹក៩២កន្លែង ស្ពាន២១កន្លែង និងលូ១៣៩កន្លែង។ ស្តារប្រឡាយមេបាន២៦ខ្សែប្រវែង៥១៦,៧០៨ម៉ែត្រ និងស្តារប្រឡាយរង ៣៩៨ខ្សែ ប្រវែង៥៩៨,៨៣២ម៉ែត្រ។

ជាទូទៅ ក្នុងឆ្នាំ២០១០ កម្ពស់ទឹកភ្លៀងមធ្យមទូទាំងខេត្ត មានកម្ពស់១,២៤០.៥០មម បើប្រៀបធៀបទៅនឹងឆ្នាំ២០០៩ ខ្ពស់ជាង៥៩មម។ ស្រុកដែលទទួលទឹកភ្លៀងច្រើនជាងគេ គឺស្រុកថ្ពងទឹកភ្លៀងមានកម្ពស់១,៥០៦.១មម បន្ទាប់មកស្រុកឱរ៉ាល់ មានកម្ពស់១,៤២៨.៨មម ហើយស្រុកដែលទទួលទឹកភ្លៀងតិចជាងគេ គឺស្រុកបរសេដ្ឋ មានកម្ពស់៩៨៧.៩មម បន្ទាប់មកក្រុងច្បារមនមានកម្ពស់១,១០៧.៩មម។

ទោះបីជាមានវឌ្ឍនភាព ដូចបានលើកខាងលើ ក៏នៅមានបញ្ហាប្រឈមច្រើន ដែលទាមទារឲ្យមានការដោះស្រាយបន្តទៀត ដូចជា៖

- សណ្តាស្ទឹងព្រែកត្នោត ពុំទាន់ធានាការពាររឹងមាំនូវផលដំណាំ ពិសេសស្រូវរបស់ប្រជាជនបាននៅឡើយ
- ពុំទាន់មានប្រភពទឹកគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ការស្រោចស្រព ដើម្បីឆ្លើយតបទៅតាមសំណូមពររបស់ប្រជាពលរដ្ឋ ក្នុងការបង្កបង្កើនផលនូវរដូវប្រាំង និងការធ្វើស្រូវរដូវដែលមាននិន្នាការកើនឡើង
- យន្តការគ្រប់គ្រងចែកចាយការប្រើប្រាស់ទឹក និងសហគមន៍កសិករប្រើប្រាស់ទឹក និងការពារទឹកពុំទាន់ឆ្លើយតបតាមសំណូមពរ
- ការជួសជុលថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត ដោយសារតែប្រជាកសិករ និងសហគមន៍កសិករប្រើប្រាស់ទឹក ពុំទាន់បានចូលរួមឲ្យអស់លទ្ធភាពក្នុងការងារខាងលើ
- ភាពអាណាធិបតេយ្យលើវិស័យធនធានទឹក នៅតែកើតមាន
- ពុំទាន់មានលិខិតបទដ្ឋានច្បាប់ឲ្យបានគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រង និងថែទាំប្រភពធនធានទឹក។

### ១.២.១.៣ វិស័យសាធារណៈការ និងដឹកជញ្ជូន

វិស័យគមនាគមន៍ គឺជាកត្តាសំខាន់បំផុតផ្នែកសេដ្ឋកិច្ច ព្រោះគមនាគមន៍ជាសសៃឈាមសំខាន់បំផុត សម្រាប់ភ្ជាប់ពីតំបន់មួយ ទៅតំបន់មួយទៀត ពិសេសផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៤ ដែលឆ្លងកាត់ស្រុកគងពិសី បរសេដ្ឋ សំរោងទង ច្បារមន និងស្រុកភ្នំស្រួច កត្តានេះហើយដែលធ្វើឲ្យការប្រកបរបរទទួលទានរបស់អាជីវករតាមបណ្តាស្រុកទាំងនោះ រីកលូតលាស់គួរឲ្យកត់សម្គាល់។ ការស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តខាងវិស័យគមនាគមន៍សម្រេចបាន

លទ្ធផលក្នុងឆ្នាំ២០០៩ មានដូចតទៅៈ ផ្លូវបេទីមីណឺមានប្រវែង២៣,១០០ម៉ែត្រ ផ្លូវក្រាលកៅស៊ូមានប្រវែង១០,៣០០ម៉ែត្រ ផ្លូវក្រាលបេតុងប្រវែង៤៣៦ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម និងថ្មភ្នំមានប្រវែង១,១៣៥,៩៥៩ម៉ែត្រ ផ្លូវលំដីសមានប្រវែង៤៣២,២២៥ម៉ែត្រ ផ្លូវលំធម្មតាមានប្រវែង៦២៦,៦២៧ម៉ែត្រ លូមុខកាត់៣០-៥០សង់ទីម៉ែត្រ មានចំនួន១៥,៥៥៤កន្លែង លូមុខកាត់៦០-១០០សង់ទីម៉ែត្រមានចំនួន៥,៤៦២កន្លែង លូមុខកាត់លើសពី១០០សង់ទីម៉ែត្រ មានចំនួន ៤,៩៩៣កន្លែង ស្ពានឈើមានចំនួន៥៧កន្លែង ស្មើនឹង២,២៤២ម៉ែត្រ ស្ពានដែកមានចំនួន ៣៧កន្លែង ស្មើនឹង៥៥៨ម៉ែត្រ និងស្ពានបេតុងមានចំនួន១៨៤កន្លែង ប្រវែង១,៩៦៥ម៉ែត្រ ត្រូវបានជួសជុលដោយថវិការបស់រាជរដ្ឋាភិបាលតាមរយៈក្រសួង និងមន្ទីរជំនាញ ពិសេសការវិភាជន៍ថវិកាមូលនិធិអភិវឌ្ឍន៍ឃុំសង្កាត់ជាដើម។ ក្នុងឆ្នាំ២០១០ មន្ទីរបានផ្តល់ប័ណ្ណសម្គាល់ទោចក្រយានយន្តសម្គាល់រថយន្តសរុបចំនួន៥,១០៣គ្រឿង ប្រលងយកប័ណ្ណបើកបរទោចក្រយានយន្ត និងរថយន្តចំនួន៣៣លើកមានបេក្ខជនចំនួន២,៦៥៣នាក់ និងបង់ចំណូលថវិកាជូនរដ្ឋបានចំនួន៦៥,៣៤៣,៩០០រៀល។

បញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយរួមមានៈ

- ផ្លូវលំជនបទភាគច្រើនពុំទាន់មានគុណភាព និងនិរន្តរភាព ព្រោះវាជាប្រភេទផ្លូវដែលធ្វើដោយដីសធម្មតា
- ការជួសជុលថែទាំផ្លូវដែលមានហើយពុំទាន់មានសកម្មភាពល្អ និងខ្វះការចូលរួមរបស់ប្រជាពលរដ្ឋ
- ការបំផុសចលនាចូលរួមរបស់ប្រជាពលរដ្ឋក្នុងការជួសជុលថែទាំផ្លូវនៅមានកម្រិត
- ការរំលោភយកដីផ្លូវ ឬ ដីចំណីផ្លូវគ្រប់ប្រភេទប្រើប្រាស់ជាឯកជននៅមានច្រើន
- ការគោរព និងការអនុវត្តតាមច្បាប់ចរាចរណ៍ផ្លូវគោក នៅធូររលុងបណ្តាលឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍នៅមានកម្រិតខ្ពស់។

## ១.២.១.៤ វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

ការងារគ្រប់គ្រងឧស្សាហកម្ម រ៉ែ និងថាមពលក្នុងឆ្នាំ២០០៩ ខេត្តកំពង់ស្ពឺ មានសិប្បកម្មធនតូច និងមធ្យមជាច្រើនដូចជា ម៉ាស៊ីនកិនស្រូវខ្នាតតូចចំនួន៤,៥១៣កន្លែង ម៉ាស៊ីនកិនស្រូវខ្នាតមធ្យម ឬធំមានចំនួន៤៧កន្លែង កន្លែងជួសជុលកង់-ម៉ូតូមានចំនួន៥៩៦កន្លែង កន្លែងជួសជុលគ្រឿងយន្ត និងឧបករណ៍កសិកម្មមានចំនួន៩១កន្លែង កន្លែងជួសជុលគ្រឿងអេឡិចត្រូនិចមានចំនួន១៦១កន្លែង សិប្បកម្មបិតស្រាមានចំនួន៦៧៩កន្លែង និងសិប្បកម្មផ្សេងៗ មានចំនួន៧៣កន្លែង។ ខេត្តមានសេវាកម្មផ្នែកអគ្គីសនី មានចំនួន១៨កន្លែងកំពុងធ្វើសកម្មភាពក្នុង នោះក្រុងច្បារមនគ្រប់គ្រងដោយអគ្គីសនីកម្ពុជា ការលក់ថាមពលអគ្គីសនីក្នុងឆ្នាំ២០១០ បាន៧,៦៦០,០០០គីឡូវ៉ាតម៉ោង សម្រាប់ផ្គត់ផ្គង់អតិថិជនគ្រប់ប្រភេទចំនួន៥,០៦៥ តាមបណ្តាខេត្ត និងទីប្រជុំជន១៧កន្លែង មានអតិថិជនចំនួន១០,៩១៥នាក់ មានចំនួន១០,៩១៥កុងទ័រ។ ចំពោះការងារគ្រប់គ្រងឧបករណ៍ផ្ទៀងផ្ទាត់មាត្រាសាស្រ្ត បានចុះផ្ទៀងផ្ទាត់កែវវែចំណុះ៥លីត្រ ចំនួន៣៣២គ្រឿង ក្នុងនោះ មិនប្រក្រតីចំនួន១៥គ្រឿង បានណែនាំឲ្យជួសជុលនឹងកែលម្អឡើងវិញ ផ្ទៀងផ្ទាត់កុងទ័រ

ប្រេងឥន្ធនៈតាមបណ្ដាស្ថានីយ៍ និងដេប៉ូប្រេងក្នុងខេត្តបានចំនួន១២១កុងទ័រ ស្មើនឹង២៧៣ដៃបាញ់។ ការងារបណ្ដាញទឹកស្អាតក្នុងខេត្ត មានចំនួន៩កន្លែង ដែលបានផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជនក្រុងច្បារមន និងស្រុកសំខាន់ៗផ្សេងទៀត។

វឌ្ឍនភាពគួរកត់សម្គាល់ត្រូវបានធ្វើឲ្យកើតមានឡើង នៅក្នុងការបង្កើតលទ្ធភាពផ្គត់ផ្គង់អគ្គីសនី និងការពង្រីកបណ្ដាញអគ្គីសនី បន្ទាប់ពីរាជរដ្ឋាភិបាលនាំចូលអគ្គីសនី ពីប្រទេសវៀតណាមឆ្លងកាត់ភូមិសាស្ត្រខេត្ត។ សេវាករផ្គត់ផ្គង់អគ្គីសនីចំនួន១៨ ត្រូវបានលើកទឹកចិត្តឲ្យវិនិយោគផ្គត់ផ្គង់អគ្គីសនីជូនប្រជាពលរដ្ឋ ។

ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ត្រូវបានធ្វើឲ្យកើតមានឡើងក៏ដោយ ក៏វិស័យនេះ ជួបប្រទះនឹងបញ្ហាប្រឈមចម្បងៗមួយចំនួនគឺៈ

- ការចាត់ចែងគ្រប់គ្រងធនធានរ៉ែខ្សាច់ ដី ថ្ម ដែលមានក្នុងខេត្ត ពុំទាន់ទទួលបានផលប្រយោជន៍ពេញលេញសម្រាប់សេដ្ឋកិច្ចខេត្តនៅឡើយ
- ប្រភព និងធនធានសម្រាប់ចូលរួមក្នុងការកែឆ្នៃប្រើប្រាស់សក្ដានុពលក្នុងវិស័យនេះ ពុំទាន់មានការចាប់ផ្ដើមបានល្អ
- ការធ្វើពិពិធកម្មនៃកម្មន្តសាល និងផលិតកម្ម កសិ-ឧស្សាហកម្ម សេវាកម្មនានាដើម្បីទាញយកប្រយោជន៍ ពីធនធានធម្មជាតិក្នុងខេត្ត ពុំទាន់មានសកម្មភាពជាដុំកំភួន
- លទ្ធភាពបណ្ដាញចែកចាយផ្គត់ផ្គង់ថាមពលអគ្គីសនី របស់សេវាករមួយចំនួន នៅមានកម្រិត ថាមពលអគ្គីសនីមិនទាន់បានប្រើប្រាស់ពេញលេញគ្រប់បណ្ដាទីប្រជុំជន ទន្ទឹមនេះ ស្ថានភាពជីវភាពប្រជាពលរដ្ឋមួយចំនួនមានការខ្វះខាត ឯតម្លៃអគ្គីសនីក៏ខ្ពស់ ធ្វើឲ្យ អត្រាគ្របដណ្ដប់នៃការប្រើប្រាស់អគ្គីសនីមានសន្ទុះយឺតយ៉ាវ
- រោងម៉ាស៊ីនកិនថ្មមួយចំនួន ពុំសូវចាប់បង់ពន្ធចូលថវិការដ្ឋ និងមានការយឺតយ៉ាវ
- ការផ្គត់ផ្គង់ទឹកស្អាតមិនទាន់បានល្អប្រសើរទាំងគុណភាព និងការតបណ្ដាញផ្គត់ផ្គង់ព្រមទាំងសំពាធទឹកមិនទាន់គ្រប់គ្រាន់តាមតម្រូវការ។

### ១.២.១.៥ វិស័យអភិវឌ្ឍន៍ជនបទ

ចំពោះការងារអភិវឌ្ឍន៍ជនបទឆ្នាំ២០១០ ក្នុងខេត្តកំពង់ស្ពឺ មានការរីកចម្រើនគួរកត់ឲ្យកត់សម្គាល់ដូចជា ការជួសជុលផ្លូវក្រាលគ្រួសក្រហមមានប្រវែង៤.៨០គ.ម ផ្លូវដីសមានប្រវែង២១.២២គ.ម ការថែទាំផ្លូវជាលក្ខណៈខួបអនុវត្តបានប្រវែង៣៧.៦០គ.ម ការថែទាំលក្ខណៈប្រចាំអនុវត្តបានប្រវែង៥៣.៨០គ.ម និងជួសជុលអណ្ដូងស្នប់ចំនួន១០២អណ្ដូង ខួង និងតម្លើងអណ្ដូងបានចំនួន១០៨អណ្ដូង ស្ពានស្រះសហគមន៍បានចំនួន៥កន្លែង និងស្ពានប្រឡាយខ្នាតតូចប្រវែង៤.៩១គ.ម និងធ្វើទឹកស្អាត និងអាងស្តុកទឹកទុកប្រកបដោយសុវត្ថិភាពតាមគ្រួសារបានចំនួន៥៥ភូមិ។ ការងារដឹកនាំអនុវត្តអនាម័យទាំងស្រុងអនុវត្តបានចំនួន១៧៨ភូមិ និង៣៣សាលា ជាលទ្ធផលសម្រេចបានការសាងសង់បង្គន់អនាម័យបានចំនួន១,០៣០បង្គន់ និងបង្គន់សាធារណៈចំនួន២៥ខ្នង ហើយ

ទទួលសម្រេចបានភូមិដែលមានបង្គន់ប្រើប្រាស់ ឈប់បត់ជើងពាសវាលពាសកាលចំនួន៧៨ភូមិ។ ការបើកវគ្គបណ្តុះបណ្តាលមុខជំនាញចំនួន៥មុខ ស្មើនឹង១៥វគ្គ មានសិក្ខាកាមចំនួន២៨៥នាក់ ស្រី ១១៩នាក់។ ការងារអភិវឌ្ឍន៍សហគមន៍បោះឆ្នោតជ្រើសរើស គ.អ.ភ បានចំនួន៩៥ភូមិ បើកវគ្គបណ្តុះបណ្តាលដល់ គ.អ.ភ និងមេភូមិចំនួន២០វគ្គ និងរៀបចំភូមិអភិវឌ្ឍន៍ចំនួន១ភូមិ។

ទន្ទឹមនឹងមានវឌ្ឍនភាព ក៏លេចចេញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រភពក្នុងការផ្គត់ផ្គង់ទឹក នៅតាមជនបទ ទាំងទឹកសម្រាប់ប្រើប្រាស់ក៏ដូចជាទឹកស្អាតសម្រាប់ហូបចុកពុំទាន់គ្រប់គ្រាន់ ស្របពេលដែលប្រជាពលរដ្ឋមួយចំនួន មានប្រភពទឹកនៅឆ្ងាយពីផ្ទះ
- ប្រជាពលរដ្ឋពុំទាន់បានទទួលទឹកស្អាតប្រើប្រាស់គ្រប់គ្រួសារនៅឡើយ គឺនៅមានប្រជាពលរដ្ឋដែលប្រើប្រាស់ប្រភពទឹកមិនស្អាត
- ប្រជាពលរដ្ឋមួយចំនួនធំទៀត ពុំទាន់មានបង្គន់អនាម័យប្រើប្រាស់ ដោយពុំទាន់យល់ដឹងខ្ពស់ អំពីផលប្រយោជន៍នៃការប្រើប្រាស់បង្គន់ និងមួយចំនួនតូចខ្វះខាតថវិកា
- ការងារអភិវឌ្ឍន៍សហគមន៍ និងសេដ្ឋកិច្ចជនបទ ពុំទាន់បានចាប់ផ្តើមសម្រាប់ជាគំរូឈានទៅពង្រីកសកម្មភាពនេះឲ្យបានល្អនៅឡើយ
- ខ្វះខាតធនធានសម្រាប់សាងសង់ផ្លូវ និងការដឹកជញ្ជូនលើសទម្ងន់ និងប្រជាពលរដ្ឋខ្វះភាពជាម្ចាស់លើការថែទាំផ្លូវ
- ប្រជាពលរដ្ឋខ្វះភាពជាម្ចាស់លើការថែទាំអណ្តូង និងប្រភពទឹកនានា
- ប្រជាពលរដ្ឋខ្វះការយល់ដឹងពីអនាម័យ និងផ្លាស់ប្តូរទម្លាប់ ហើយពុំទាន់មានបង្គន់ប្រើប្រាស់
- ខ្វះមធ្យោបាយ សម្ភារៈ ថវិកា និងគ្រូបណ្តុះបណ្តាលជំនាញ។

### ១.២.១.៦ វិស័យពាណិជ្ជកម្ម

ការងារពាណិជ្ជកម្មនៅក្នុងខេត្ត បើទោះជាពុំសូវមានអាជីវករឬឈ្មួញរកស៊ីធំដុំក៏ខេត្តកំពង់ស្ពឺមានផ្លូវជាតិលេខ៤ ឆ្លងកាត់ផ្លូវនេះមានសក្តានុពលខ្លាំងផ្នែកពាណិជ្ជកម្ម ព្រោះវាជាច្រកដែលនាំទំនិញទៅមកពីខេត្តព្រះសីហនុ ទៅរាជធានីភ្នំពេញ មិនតែប៉ុណ្ណោះផ្លូវបង្ករលក្ខណៈឲ្យមានការងាយស្រួលក្នុងការដោះដូរផលិតផលកសិកម្ម សិប្បកម្ម របស់ប្រជាពលរដ្ឋបានយ៉ាងងាយ។ក្នុងឆ្នាំ២០១០ ខេត្តបានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយប្រកាសរបស់ក្រសួងពាណិជ្ជកម្មលេខ២២៨ ស្តីពីការគ្រប់គ្រងអាជីវកម្មលោហៈធាតុត្បូងថ្ម មានតម្លៃជាគ្រឿងអលង្ការបានចំនួន៦លើក ក្រុងច្បារមន ២លើក ស្រុកភ្នំស្រួច២លើក ឧដុង្គ២លើក សរុបបានចំនួន២២៣ ទីតាំងចុះដាក់ស្តែងដល់ស្តង់អាជីវកម្ម ដើម្បីជួយបំពេញបែបបទសុំច្បាប់ប្រកបអាជីកម្មសរុប១៣៣កន្លែង និង៧០កន្លែងទៀត មិនទាន់ព្រមសុំច្បាប់ចុះផ្សព្វផ្សាយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចំនួន១៨លើក នៅស្រុក

បរសេដ្ឋចំនួន១០លើក គងពិសី៦លើក ឱរ៉ាល់១លើក និងថ្ពង១លើក មានសមាជិកចំនួន៥១២នាក់ ស្រី២៥៧នាក់។ ក្រៅពីការចុះផ្សព្វផ្សាយខេត្តបានចាត់មន្ទីរឲ្យតាមដានជាប្រចាំ ស្តីពីការកំណត់ និងបិតស្លាកលើមុខថ្លៃទំនិញជាប្រចាំ។ ក្នុងខេត្តមានផ្សារធំចំនួន៧កន្លែង និងផ្សារខ្នាតតូចចំនួន ៨៣កន្លែង និងស្ថាននីយ៍ប្រេងឥន្ធនៈចំនួន៣៥កន្លែង ចំនួនអាជីវកម្មខ្នាតតូច (លក់បាយ គ្រឿងទេស លក់ភេសជ្ជៈ....) ចំនួន២,៧៦៧កន្លែងក្នុងឆ្នាំ២០១០។ ចំណែកឯតម្លៃស្រូវមានសន្ទស្សន៍កើនឡើងពី១០០០រៀល ក្នុងឆ្នាំ២០០៩ដល់តម្លៃ១,០៩០រៀលក្នុងឆ្នាំ២០១០។ ខេត្តបានរៀបចំឲ្យមានជាសភាពាណិជ្ជកម្មខេត្ត ដែលមានទីតាំងនៅក្នុងភូមិស្មោទី១ សង្កាត់រកាធំ ក្រុងច្បារមន និងរៀបចំបោះឆ្នោតសភាពាណិជ្ជកម្មអាណត្តិទី១ លើកទី២ក្នុងខែឧសភាឆ្នាំ២០១១នេះ។

ទន្ទឹមនឹងមានវឌ្ឍនភាពនេះ ក៏លេចចេញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- អាជីករមួយចំនួន មិនព្រមសុំការអនុញ្ញាតច្បាប់ឲ្យបានត្រឹមត្រូវពីមន្ទីរពាណិជ្ជកម្ម បើប្រៀបធៀបចំនួនអាជីវករ និងអ្នកសុំច្បាប់មានគំលាតគ្នាឆ្ងាយ គឺសុំលិខិតអនុញ្ញាតច្បាប់បានតែចំនួន១៧.៩២%តែប៉ុណ្ណោះ
- អាជីវករមួយចំនួនធំ ពុំសូវយកចិត្តទុកដាក់ ក្នុងការបិតស្លាកថ្លៃលើមុខទំនិញរបស់ខ្លួនឡើយ
- ក្រុមហ៊ុនមួយចំនួន ពុំសូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ឲ្យបានត្រឹមត្រូវតាមគោលការណ៍។

### ១.២.១.៧ វិស័យឯកជន

ការវិនិយោគឯកជនក្នុងខេត្តមានលក្ខណៈល្អប្រសើរ ពិសេសវិស័យធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលបានផ្តល់ឥណទានខ្នាតតូចជូនដល់កសិករសម្រាប់ប្រកបរបរផ្សេងៗ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងខេត្ត ម្យ៉ាងទៀតវិស័យកាត់ដេរ និងសហគ្រាសផ្សេងៗមានការរីកចម្រើនច្រើន ជារួមក្នុងខេត្តទាំងមូលមានសហគ្រាសឯកជនចំនួន៥៧កន្លែង នឹងបានចុះបញ្ជីត្រឹមត្រូវចំនួន៣៩កន្លែង ដែលអាចផ្តល់ការងារជូនប្រជាពលរដ្ឋទាំងក្នុង និងក្រៅខេត្តប្រមាណ ២១,៨៨៣នាក់ ស្រី១៩,០៤៧នាក់ ក្នុងឆ្នាំ២០១០នេះ ។ ការវិនិយោគដំណាំអំពៅរបស់ក្រុមហ៊ុនលោកឧញ្ញា លី យ៉ុងផាត់ ប្រមាណជាង៣០,០០០ហិចតាក្នុងតំបន់ថ្ពង និងឱរ៉ាល់ ដែលអាចផ្តល់ការងារជាច្រើនជូនកសិករ។

ទន្ទឹមនឹងមានវឌ្ឍនភាព ក៏លេចចេញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- វិស័យឯកជនមួយចំនួន ពុំសូវយកចិត្តទុកដាក់ក្នុងការបង់ពន្ធជូនថវិការដ្ឋ និងរៀបចំលិខិតបទដ្ឋានឲ្យបានត្រឹមត្រូវ
- វិស័យខ្លះមានលក្ខណៈស្មុគ្រស្មាញពិបាកគ្រប់គ្រង ហើយពុំសូវស្តាប់ការណែនាំ

- ក្រុមហ៊ុនមួយចំនួន ពុំសូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ឲ្យបានត្រឹមត្រូវតាមគោលការណ៍។

### ១.២.១.៨ ស្ថានភាពវិស័យទេសចរណ៍

ខេត្តកំពង់ស្ពឺ មានតំបន់ទេសចរណ៍សំខាន់ៗចំនួន៧កន្លែង មានដូចជារមណីយដ្ឋានអំពែភ្នំ ឱទ្យានជាតិគីរីរម្យ រមណីយដ្ឋានគីរីរម្យ រមណីយដ្ឋានទឹកធ្លាក់ធម្មជាតិចំបក់ រមណីយដ្ឋានតេទឹកពុះ រមណីដ្ឋានបុរាណវិទ្យាភ្នំចាស់ ភ្នំព្រះ និងកីឡាដ្ឋានវាយកូនគោល១កន្លែងផងដែរ។ តំបន់ទេសចរណ៍ទាំងនេះ ព្រមទាំងកីឡាវាយកូនគោល ពិតជាបានទាក់ទាញភ្ញៀវទេសចរជាច្រើនចូលទស្សនាប្រមាណ១៩៦,៨៩០នាក់ ក្នុងឆ្នាំ២០១០កើនឡើង១០.៤៩% បើប្រៀបធៀបឆ្នាំ២០០៩មានចំនួន១៧៦,២៣០នាក់ ពិសេសតំបន់ឧទ្យានជាតិគីរីរម្យ ដែលមានបរិយាកាសត្រជាក់ស្រួលហើយសម្បូរទៅដោយរុក្ខជាតិស្រស់។ ទន្ទឹមនឹងនោះយើងមានសេវាកម្មម្ហូបអាហារ សេវាកម្មស្នាក់នៅនិងសេវាកម្មកំសាន្តមួយចំនួនទៀតផងដែរ។

ខេត្តនៅមានបញ្ហាប្រឈមសំខាន់ៗ លើវិស័យទេសចរណ៍មួយចំនួន ដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយរួមមានដូចខាងក្រោម៖

- មូលដ្ឋានអាជីវកម្មសេវាកម្មមួយចំនួន មិនទាន់មានលក្ខណៈបច្ចេកទេសទៅតាមស្តង់ដារតម្រូវ
- ការគ្រប់គ្រងក្នុងឧស្សាហកម្មទេសចរណ៍ មិនទាន់បានល្អប្រសើរគ្រប់ជ្រុងជ្រោយ ដែលធ្វើឲ្យអាជីវកម្ម សេវាកម្មមួយចំនួនមានភាពអាណាធិបតេយ្យ
- ខ្វះការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការជំរុញ និងលើកស្ទួយវិស័យទេសចរណ៍
- ការផ្សព្វផ្សាយសក្តានុពលទេសចរណ៍ពុំទាន់មានលក្ខណៈទូលំទូលាយ។

### ១.២.១.៩ ស្ថានភាពវិស័យពន្ធដារ

ស្ថានភាពពន្ធដារក្នុងខេត្ត មានលក្ខណៈល្អប្រសើរ ទោះជាខេត្តពុំសូវមានមូលដ្ឋានអាជីវកម្មច្រើន ឬធំដុំយ៉ាងណាក៏ដោយ ក៏បច្ចុប្បន្នសាខាពន្ធដារខេត្ត ប្រមូលពន្ធតាមពីរប្រព័ន្ធគឺ៖

១. ប្រព័ន្ធគ្រប់គ្រងការប្រមូលពន្ធតាមរបបម៉ៅការ៖ ចំណូលពន្ធសំខាន់ៗ តាមរបបម៉ៅការតាមប្រភេទពន្ធ ពន្ធប្រថាប់ត្រា ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធអាករលើផលរបរ ពន្ធប៉ាតង់ពន្ធលើមធ្យោបាយ និងយានជំនិះគ្រប់ប្រភេទ។ល។

២. ប្រព័ន្ធគ្រប់គ្រងការប្រមូលពន្ធតាមរបបស្វ័យប្រកាស៖ ចំណូលពន្ធសំខាន់ៗ តាមរបបស្វ័យប្រកាសតាមប្រភេទពន្ធ ពន្ធអាករលើតម្លៃបន្ថែម ពន្ធប្រាក់រំដោះលើប្រាក់ចំណេញ ពន្ធលើប្រាក់បៀវត្សរ៍ និងពន្ធកាត់ទុកទូទៅ។

ជាចំណូលសរុបឆ្នាំ២០១០ របស់ខេត្តមានចំនួន៥,៤១៥,៦៨០,៤៧០រៀលស្មើនឹង៦១.០៧% ក្នុងនោះ ថវិការជ្ជមានចំនួន៣,០១៦,០៦៦,៧៥៤រៀល ស្មើ៣៩.៥៧% ថវិកាខេត្តមានចំនួន ២,៣៩៩,៦១៣,៧២៦រៀល ស្មើនឹង១៩២.៥៩%។

### ១.២.១.១០ ស្ថានភាពវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវបានចាត់ទុកជាគម្រោងផែនការ និងសកម្មភាព ការងារសំដៅជំរុញការរៀបចំប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍មួយស្របតាមការរីកចម្រើននៃ បណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិឲ្យមានប្រសិទ្ធសេដ្ឋកិច្ចខ្ពស់ សេវាកម្មទំនើប និងគ្របដណ្តប់ ទូទាំងខេត្ត ដោយមានប្រព័ន្ធត្រួតពិនិត្យគុណភាពសំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងលើក កម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ។ ការធ្វើការពង្រីកសេវាកម្មប្រៃសណីយ៍ និងទូរគមនាគមន៍ នៅ តាមតំបន់ជនបទបង្ករលក្ខណៈ ឲ្យប្រជាពលរដ្ឋងាយទទួលបានព័ត៌មាន និងបញ្ជូនព័ត៌មានក្នុងការ ទំនាក់ទំនងឱ្យបានឆាប់រហ័ស និងបង្កើនសហប្រតិបត្តិការទាក់ទាញ និងលើកទឹកចិត្តអ្នកវិនិយោគ ឯកជន។

### ក. វិស័យប្រៃសណីយ៍

សេវាកម្ម-អាជីវកម្មប្រៃសណីយ៍ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយបង្កើនឥតឈប់ ឈរនូវទំនុកទុកចិត្ត និងការជឿជាក់ពីសំណាក់អតិថិជនជាតិ និងអន្តរជាតិ ជាពិសេសធ្វើការប្រកួត ប្រជែងជាមួយបណ្តាក្រុមហ៊ុនឯកជនដែលរកស៊ីប្រហាក់ប្រហែល។ បម្រើសេវាកម្មបញ្ជូន និងទទួល បញ្ញើនៅក្នុងប្រទេសក្នុង១សប្តាហ៍តែពី៣ជើងទៅ៥ជើង ចំពោះបញ្ញើទៅតាមបណ្តាស្រុកទាំង៨ ក្នុងខេត្តក្នុង១សប្តាហ៍បានតែពី១ជើងប៉ុណ្ណោះ។ ចំពោះបញ្ញើតាមផ្លូវរាបពីភ្នំពេញមកមន្ទីរប្រៃ សណីយ៍ និងទូរគមនាគមន៍ខេត្ត១សប្តាហ៍បញ្ជូន និងទទួលបាន៥ជើង មានបញ្ញើក្នុង និងក្រៅ ប្រទេស។ ដោយឡែកបញ្ញើឆាប់រហ័ស EMS បញ្ជូនទទួលពីខេត្តទៅតាមបណ្តាប្រទេសជាង៩០ លើពិភពលោក តាមរយៈក្រសួងប្រៃសណីយ៍មាន៥ជើងក្នុង១សប្តាហ៍ចំពោះ (បញ្ជូន និងទទួល បញ្ញើទាំង២ប្រភេទគឺមានរយៈពេលតែមួយ)។ ក្នុងឆ្នាំ២០១០ ការបញ្ជូន និងទទួលបញ្ញើក្នុងប្រទេស សម្រេចបាន១,៥១១ច្បាប់ បញ្ជូន និងទទួលបញ្ញើក្រៅប្រទេសសម្រេចបាន៧២៨ច្បាប់ ក្នុងនោះ កញ្ចប់ផ្សេងៗសរុប១២៦កញ្ចប់។

### ខ. វិស័យទូរគមនាគមន៍

សេវាកម្ម-អាជីវកម្មវិស័យទូរគមនាគមន៍ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ព្រោះការ រីកចម្រើនវិស័យបានបង្កើនឡើងឥតឈប់ឈរនូវទំនុកចិត្ត និងការជឿជាក់ពីសំណាក់អតិថិជន ជាតិ និងអន្តជាតិ ជាពិសេសធ្វើការប្រកួតប្រជែងរបស់បណ្តាក្រុមហ៊ុនរដ្ឋ និងឯកជនដែលមានការ រកស៊ីប្រហាក់ប្រហែលគ្នា។ ស្ថិតិដែលមន្ទីរទទួលបានពីការស្រង់ទិន្នន័យលើវិស័យទូរគមនាគមន៍

និងព័ត៌មានវិទ្យាទូទាំងខេត្ត មានក្រុមហ៊ុនទូរស័ព្ទអចល័តចំនួន២ក្រុមហ៊ុន ក្រុមហ៊ុនទូរស័ព្ទចល័តចំនួន៨ក្រុមហ៊ុន បណ្តាញក្រុមហ៊ុនខ្សែកាប្លិ៍អុបទិចចំនួន៥ក្រុមហ៊ុន ក្រុមហ៊ុនបម្រើប្រព័ន្ធអ៊ីនធឺណេតចំនួន៤ក្រុមហ៊ុន មានទីតាំងនៅស្ថានីយ៍ទូរស័ព្ទ ក្រុមហ៊ុននានាទូទាំងខេត្តចំនួន៣១១បង្គោលដែលបានបំពាក់ម៉ែក្រូវ៉េវ តាមស្ថានីយ៍ចំនួន៣៤៤ម៉ែក្រូវ៉េវ និងមាទីតាំងអ្នកលក់ និងជួសជុលទូរស័ព្ទមាន៧០កន្លែង បម្រើទូរស័ព្ទសាធារណៈ៥០កន្លែង PCO ១២គ្រឿង អ៊ីនធឺណេត៣៦កន្លែង។

ទន្ទឹមនឹងលទ្ធផលខាងលើ ក៏លេចចេញនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោមៈ

- ខ្វះមន្ត្រីជំនាញក្នុងការបំពេញការងារ
- បុគ្គលិកមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ
- ខ្វះមធ្យោបាយលើការងារបម្រើសេវាកម្ម អាជីវកម្ម
- ថវិការដ្ឋចំណាយប្រចាំឆ្នាំ នៅមានកម្រិតទាបបើធៀបទៅនឹងវង្វង់ការងារ
- ក្រុមហ៊ុនទូរស័ព្ទមួយចំនួន មិនគោរពគោលការណ៍បទដ្ឋានបច្ចេកទេស និងមន្ទីរជំនាញមុនពេលតម្លើងស្ថានីយ៍ថ្មី
- ខ្វះថវិកាក្នុងការផ្សព្វផ្សាយសេវាប្រៃសណីយ៍ និងសេវាកម្មជាវប្រអប់សំបុត្រ។

## ១.២.២. ស្ថានភាពសង្គមកិច្ច

វឌ្ឍនភាពគួរកត់សម្គាល់ បានសម្តែងឲ្យឃើញថា ស្ថានភាពសង្គមកិច្ចនៅក្នុងខេត្តកំពង់ស្ពឺហាក់ដូចជាមានការប្រែប្រួលច្រើនលើគ្រប់វិស័យ តាមរយៈការយកចិត្តទុកដាក់របស់ខេត្ត លើការអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងគុណភាពអប់រំ ការលើកកម្ពស់សេវាសុខាភិបាល សមភាពយេនឌ័រ និងការអនុវត្តគោលនយោបាយប្រជាជន។ ទន្ទឹមនឹងការរីកចម្រើននេះដែរ រដ្ឋបាលខេត្តនៅតែមានបញ្ហាប្រឈម និងកង្វះខាតជាច្រើន ដែលតម្រូវឲ្យមានការគាំទ្រពីគ្រប់មជ្ឈដ្ឋានអ្នកពាក់ព័ន្ធ ដើម្បីជំរុញវិស័យសំខាន់ៗក្នុងផ្នែកសង្គមកិច្ច ដែលស្តែងចេញនូវស្ថានភាពតាមវិស័យផ្សេងៗ នាពេលបច្ចុប្បន្នតាមរយៈសូចនាករជាក់ស្តែងដែលប្រមូលបាន ទាក់ទងនឹងការកើនឡើង និងការថយចុះនូវតួលេខសំខាន់ៗ ព្រមទាំងបញ្ហាប្រឈមនានាដែលខេត្តមាន។

ខាងក្រោមនេះ ជាស្ថានភាពជាក់ស្តែងទាក់ទងនឹងផ្នែកសង្គមកិច្ច នាពេលបច្ចុប្បន្ន ហើយទាមទារការយកចិត្តទុកដាក់បន្តពីរដ្ឋបាលខេត្តទាំងមូលៈ

### ១.២.២.១-វិស័យអប់រំ

ស្ថានភាពវិស័យអប់រំក្នុង ខេត្តមានភាពល្អប្រសើរ ដោយបានអនុវត្តតាមគោលដៅអភិវឌ្ឍន៍របស់ជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហសវត្សន៍ ដោយក្នុងនោះទូទាំងខេត្តបានសម្រេចនូវលទ្ធផល និងបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោមៈ

- ចំនួនមត្តេយ្យរដ្ឋ និងឯកជនមាន៨៣សាលា ចំនួនបន្ទប់មត្តេយ្យរដ្ឋ និងឯកជនមាន ចំនួន១៣៨បន្ទប់ ចំនួនថ្នាក់រៀនមត្តេយ្យរដ្ឋ និងឯកជន១៣៨ថ្នាក់ ចំនួនគ្រូមត្តេយ្យរដ្ឋ និងឯកជនចំនួន១៥២នាក់ ទទួលសិស្សអាយុពី៣- ៥ឆ្នាំ ចំនួន៤,៨៧៩នាក់ ក្នុងនោះ ស្រីចំនួន២,៤៣៧នាក់។ មត្តេយ្យសហគមន៍មានចំនួន១៩៥មណ្ឌល ស្មើនឹង២១៦ បន្ទប់ត្រូវជា២១៦ថ្នាក់ ដែលមានគ្រូមត្តេយ្យចំនួន២១៧នាក់ ស្រី២១៤នាក់ ទទួល សិស្សអាយុ០៣-០៥ឆ្នាំចំនួន៥,៣៦០នាក់ ស្រីចំនួន២,៦៩៥នាក់។ កម្មវិធីអប់រំកុមារ តូចផ្ទះ មានចំនួន២៧ភូមិ ម៉ែបង្គោល២៧កន្លែង ម៉ែកុមារ១,៤៥៨នាក់ កុមារអាយុ៣-៥ ឆ្នាំចំនួន១,១៥៩នាក់ ស្រី៥៩៧នាក់។ បញ្ហាប្រឈម កុមាររៀនថ្នាក់មត្តេយ្យនៅមាន ចំនួនតិច ដោយសារខ្វះអគារសិក្សា ខ្វះគ្រូ មាតាបិតាមិនសូវយល់ពីការបញ្ជូនកូនទៅ រៀននៅមត្តេយ្យសិក្សា និងសមត្ថភាពគ្រូមត្តេយ្យនៅមានកម្រិត។
- ចំនួនសាលាបឋមសិក្សាមានចំនួន៣០៦សាលា មានបន្ទប់សិក្សាចំនួន២,៣៩២បន្ទប់ មានថ្នាក់ចំនួន២,៧៧៩ថ្នាក់ និងមានគ្រូបឋមសិក្សាសរុបចំនួន២,៩០៥នាក់ មានសិស្ស អាយុពី៦-១១ឆ្នាំ កំពុងរៀនសរុប១០៤,៧៦៧នាក់ ស្មើនឹង៩៥.២០%។ កុមារអាយុពី៦- ១១ឆ្នាំ មិនបានចូលរៀន៤.៨% នៃចំនួនកុមារសរុប ដោយសារកត្តាការមិនយល់ដឹង ពីតម្លៃសិក្សា គ្រួសារក្រីក្រទុកកូនឲ្យជួយធ្វើការងារផ្ទះដើម្បីដោះស្រាយជីវភាព ខ្វះបន្ទប់ រៀន សាលារៀនខ្លះនៅឆ្ងាយពីផ្ទះពេក ខ្វះការទំនាក់ទំនងជាមួយអជ្ញាធរដែនដី អាណា ព្យាបាលសិស្ស និងលោកគ្រូ-អ្នកគ្រូ។
- អនុវិទ្យាល័យមានចំនួន៧០សាលា ស្មើនឹង៩១៩បន្ទប់ និងមាន៩៣៧ថ្នាក់ និងមានគ្រូ ចំនួន១,០៧៨នាក់ មានសិស្សអាយុពី១២-១៤ឆ្នាំ ចូលរៀនចំនួន១៦,៩០០នាក់ ហើយ កុមារ(១២-១៤ឆ្នាំ)មិនបានចូលរៀនចំនួន៤០,៨៨២នាក់។ ការទៅរកការងារធ្វើជាកម្មករ សំណង់ ឬកម្មករ កម្មការនីរោងចក្រកាត់ដេរការបង្ខំឲ្យកូនស្រីរៀបការក្នុងវ័យការសិក្សា របស់សិស្សជីវភាពក្រីក្រ និងការគេចមិនចូលរៀនគ្រូបង្រៀន ផ្ទះនៅឆ្ងាយ និងខ្វះខាត ក្នុងជីវភាពរស់នៅទៅបង្រៀនមិនបានជាប់លាប់ និងមិនចប់តាមកម្មវិធី។
- វិទ្យាល័យមានចំនួន១៧កន្លែង ស្មើនឹង៣៣៨បន្ទប់ ត្រូវជា៣៩៦ថ្នាក់ មានសិស្សចូល រៀនចំនួន២២,៨១២នាក់ និងយុវជនអាយុ(១៥-១៧ឆ្នាំ )ចំនួន៥៩,១៧៣នាក់ មិនបាន ចូលរៀនស្មើនឹង៨៨.២០%ក្នុងឆ្នាំ២០១០ ដែលបានបង្ហាញឲ្យឃើញថា ការអប់រំនៅ ថ្នាក់មធ្យមសិក្សាក៏នៅមានបញ្ហារាំងស្ទះមួយចំនួនដែរ ដោយសារកត្តាមួយចំនួនដូចជា ការទៅរកការងារធ្វើជាកម្មករសំណង់ ឬកម្មករ កម្មការនីរោងចក្រកាត់ដេរ ការបង្ខំឲ្យ កូនស្រីរៀបការមិនទាន់ពេញវ័យ សាលារៀនថ្នាក់វិទ្យាល័យនៅឆ្ងាយពីផ្ទះ ការខ្វះខាត ក្នុងជីវភាព ការសេពគប់ក្មេងទំនើង និងការសេពគ្រឿងញៀន។

- ការអប់រំក្រៅប្រព័ន្ធ មិនទាន់អនុវត្តតាមផែនការបាន១០០% ដោយយើងសង្កេតឃើញថា មានអត្រាអ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ ចំនួន២៥,៩២៩នាក់ ស្មើនឹង៥.៧៦% ទៀត ដោយសារកត្តាមិនទាន់មានថ្នាក់អក្ខរកម្ម នៅតាមភូមិដែលមានអ្នកមិនចេះអក្សរច្រើនគ្រូអក្ខរកម្មមិនទាន់មានគ្រប់ចំនួន ខ្វះការគាំទ្របំប៉ន់គ្រូអក្ខរកម្មគ្រប់ឃុំ និមិនទាន់មានមជ្ឈមណ្ឌលសិក្សាសហគមន៍គ្រប់ឃុំ ។

បញ្ហាប្រឈមផ្សេងៗទៀត ដែលត្រូវបន្តដោះស្រាយរួមមាន៖

- ត្រូវធ្វើវិមជ្ឈការ និងវិសហមជ្ឈការប្រព័ន្ធអប់រំឲ្យបានស្របទៅនឹងច្បាប់អង្គការ និងកម្មវិធីជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- សាលារៀនគ្រប់កម្រិតថ្នាក់ បានកាត់បន្ថយ
- ការពង្រីកអនុវិទ្យាល័យក្នុងបឋមសិក្សា តាមគោលការណ៍ឃុំមួយត្រូវមានអនុវិទ្យាល័យមួយ ប៉ុន្តែឃុំចំនួន៩ ពុំទាន់មានអនុវិទ្យាល័យនៅឡើយ
- អនុវិទ្យាល័យមួយចំនួនពុំទាន់មានអាគារសិក្សាគ្រប់គ្រាន់ និងការផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សិស្សានុសិស្ស ពុំទាន់ពេលវេលា និងមិនបានគ្រប់គ្រាន់
- អត្រាត្រួតថ្នាក់ និងបោះបង់ចោលការសិក្សានៅមានកម្រិតខ្ពស់
- នាយកសាលាមួយចំនួនពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តវិមជ្ឈការ ដូចជាការគ្រប់គ្រងសាលារៀនតាមបែបការគ្រប់គ្រង ផ្តោតលើលទ្ធផលការគ្រប់គ្រងថ្នាក់រៀន ការរៀន និងបង្រៀនការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការប្រើប្រាស់ថវិកា
- គុណភាពអប់រំនៅតែជាបញ្ហាដែលតម្រូវឲ្យអ្នកពាក់ព័ន្ធទាំងអស់បន្តយកចិត្តទុកដាក់។

### ១.២.២.២ វិស័យសុខាភិបាល

វិស័យសុខាភិបាលមានរីកចម្រើនគួជាទីមោទនៈដោយខេត្ត មានមន្ទីរពេទ្យបង្អែកចំនួន៣ការិយាល័យ ស្រុកប្រតិបត្តិមានចំនួន៣កន្លែង មណ្ឌលសុខភាពចំនួន៥០កន្លែង និងមានមន្ត្រីសុខាភិបាល វេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុបដ្ឋាកយិកា និងឆ្មបសម្រាប់បម្រើសេវាជូនប្រជាពលរដ្ឋដែលមានតម្រូវការផ្នែកព្យាបាល និងថែទាំសុខភាពនៅមណ្ឌលសុខភាពទាំងនោះ។ បច្ចុប្បន្នមន្ទីរសុខាភិបាលខេត្តមាន កិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីពួតដៃគ្នាក្នុងការអនុវត្តកម្មវិធីផ្សេងៗ ដូចជាការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ ជម្ងឺគ្រុនចាញ់ និងរបេងជាដើម ធ្វើយ៉ាងណាចូលរួមសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ ទន្ទឹមនឹងការរីកចម្រើននេះ បញ្ហាសុខភាពក៏នៅមានបញ្ហាមួយចំនួនដែរ ដូចជាចំនួនបន្ទប់សម្រាប់អ្នកជម្ងឺ នៅមិនទាន់គ្រប់ចំនួន ចំនួនវេជ្ជបណ្ឌិតមានចំនួនតិចនៅតាម

ស្រុក មណ្ឌលសុខភាពមានចំនួនតិច មណ្ឌល១សម្រាប់ប្រជាពលរដ្ឋ២ឃុំ ហើយការពិនិត្យព្យាបាលជម្ងឺនៅតាមមណ្ឌលសុខភាព នៅមានកម្រិតព្រោះខ្វះឧបករណ៍ ឱសថមានការខ្វះខាត ប្រជាពលរដ្ឋភាគច្រើនប្រើប្រាស់សេវាឯកជនដែលគ្មានច្បាប់អនុញ្ញាត។

### ការថែទាំសុខភាពមាតា និងទារក

- ភាគរយស្ត្រីដែលសម្រាលលកូន ដោយឆ្មបបុរាណ នៅឆ្នាំ២០១០ មានចំនួន៣,៤៩១នាក់ ថយចុះពី២២.៩២%នៅឆ្នាំ២០០៩ មក១៣.៩៥%។ បញ្ហានៃការសម្រាលកូនដោយឆ្មបបុរាណនេះ ដោយសារតែមណ្ឌល់សុខភាពនៅឆ្ងាយពីផ្ទះពេក និងមិនមានមធ្យោបាយក្នុងការបញ្ជូនទៅមណ្ឌលសុខភាព។
- អត្រាមរណភាពមាតាក្រោយពេលសម្រាលកូន(0-១ខែ) ក្នុង១០០,០០០កំណើត មានការថយចុះពី២០៩នាក់ក្នុងឆ្នាំ២០០៩ មកនៅត្រឹម៩៧នាក់នៅឆ្នាំ២០១០។ អត្រាមរណភាពនេះបើពិនិត្យជារួមបណ្តាលមកពី (១) ភាពទ្រុឌទ្រោមសុខភាពពេល មានផ្ទៃពោះដោយសារការធ្វើការងារធ្ងន់ និងកង្វះអាហារូបត្ថម្ភ (២) ការសម្រាលកូនដោយមានការឆ្លងរោគ (៣) ការយឺតយ៉ាវក្នុងការសម្រេចចិត្តបញ្ជូនទៅរកសេវាសម្រាល ដែលមានសុវត្ថិភាព (៤)ការប្រកាន់យកនូវទម្លាប់ចាស់បុរាណ មិនសមស្រប (៥) ការសម្រាលដោយឆ្មបបុរាណអស់ចិត្ត និងអស់លទ្ធភាព ទើបបញ្ជូនមកឆ្មបពេទ្យដែល កត្តានេះគួរមានការយកចិត្តទុកដាក់បន្ថែមទៀត (៦) ការមិនយល់ដឹងពីវិធីថែទាំខ្លួនក្រោយពេលសម្រាល។ល។
- អត្រាមរណភាពទារកអាយុ(0-១ខែ)ក្នុង១,០០០កំណើតរស់ ថយចុះពី១១នាក់ នៅឆ្នាំ២០០៩ មកនៅត្រឹម៧នាក់ក្នុងឆ្នាំ២០១០ ដែលចំនុចនេះមន្ទីរសុខាភិបាលត្រូវយកចិត្តទុកដាក់បន្ថែមទៀត។ ចំនួនមរណភាពកុមារអាយុ៥ឆ្នាំចុះ មានចំនួន១៤៩នាក់ក្នុងឆ្នាំ២០១០។ ចំពោះការស្លាប់របស់ទារក និងកុមារគឺបណ្តាលមកពី (ក) កង្វះអាហារូបត្ថម្ភ (ខ)កង្វះអនាម័យ (គ)កង្វះការយល់ដឹងពីរបៀបថែទាំទារក និងកុមារ (ឃ) ដោយសារជម្ងឺផ្សេងៗ ហើយមិនបានយកមកព្យាបាលនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព។

### ការចាក់ថ្នាំបង្ការជម្ងឺ៧មុខ ដល់កុមារ

ចំនួនកុមារអាយុពី៩-១២ឆ្នាំដែលមិនបានទទួលថ្នាំបង្ការមានចំនួន២១២នាក់ ស្មើនឹង២.០២ភាគរយ។ ការដែលសម្រេចមិនបាន១០០%នេះ គឺបណ្តាលមកពីកត្តាមួយចំនួនដូចជា៖

- ប្រជាពលរដ្ឋខ្លះមានទីលំនៅឆ្ងាយពីមណ្ឌលសុខភាព
- ខ្វះការផ្សព្វផ្សាយពីភ្នាក់ងារមណ្ឌល់សុខភាព និងអាជ្ញាធរភូមិ និងឃុំ
- មាតាបិតាខ្លះគ្មានឆន្ទៈក្នុងការយកកូនទៅទទួលថ្នាំបង្ការខ្លះទៀត និងមានការស្ទាក់ស្ទើរក្នុងការឲ្យកូនទទួលថ្នាំបង្កាដោយខ្លាចប្រតិកម្មរបស់វ៉ាក់សាំង

- អ្នកស្ម័គ្រចិត្តភូមិមិនសូវទទួលបានការលើកទឹកចិត្ត ដូចជាប្រាក់ឧបត្ថម្ភ និងមធ្យោបាយជាដើមដែលនាំឲ្យការប្រមូលផ្តុំកុមារមានការលំបាក
- បុគ្គលិកពេទ្យទទួលបានថវិកាមិនគ្រប់គ្រាន់ និងមិនទៀងទាត់ និងខ្វះមធ្យោបាយធ្វើដំណើរ។

## ការអប់រំថែទាំពីសុខភាពអនាម័យ

គ្រួសារដែលមានបង្គន់អនាម័យសរុបចំនួន២១.៤៨ % ដូចនេះមានគ្រួសារចំនួន ៧៨.៥២% ទៀតដែលមិនទាន់មានបង្គន់អនាម័យ នេះបង្ហាញឲ្យឃើញថាប្រជាពលរដ្ឋក្នុងខេត្តជាច្រើន គឺមិនបានយល់ពីអត្ថប្រយោជន៍ ក្នុងការប្រើប្រាស់បង្គន់អនាម័យ និងផលវិបាកនៃការឆ្លងមេរោគតាមរយៈការបន្ទោរបង់ពាសវាលពាសកាលនៅឡើយ។ មូលហេតុនេះ គឺបណ្តាលមកពីការខ្វះការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ការខ្វះខាតថវិកាក្នុងការសង់បង្គន់ និងការមិនព្រមផ្លាស់ប្តូរទម្លាប់ចាស់ ។

## ការទទួលបានទឹកស្អាត និងអនាម័យ

ភាគរយគ្រួសារដែលមានប្រភពទឹកស្អាតប្រើប្រាស់ នៅរដូវប្រាំងមានចំនួន៦៣.៤៥%។ តាមរយៈស្ថិតិនេះ បង្ហាញថាមានប្រជាពលរដ្ឋចំនួន៣៦.៥៦% ទៀតមិនមានទឹកស្អាតប្រើប្រាស់ទេនៅរដូវប្រាំង។ កត្តានេះដោយសារតែគ្រួសារដែលប្រើប្រាស់ប្រភពទឹកអណ្តូងស្នប់អណ្តូងចម្រុះមានត្រឹមតែ៤៦.៧៨% ស្មើនឹង៧០,៨១៧គ្រួសារ និងគ្រួសារដែលប្រើប្រាស់ប្រភពទឹកទន្លេ ស្ទឹង បឹង ត្រពាំង និងអាងទឹកមានចំនួន៩,៩០៤ស្មើនឹង៦.៥៤ %។

## ក្រុមជនងាយរងគ្រោះ ដែលត្រូវទទួលកិច្ចការពារពិសេស

បច្ចុប្បន្ននេះ ខេត្តត្រូវប្រឈមនឹងបញ្ហាជាច្រើនជាមួយក្រុមជនងាយរងគ្រោះ ដែលពួកគេរស់នៅរបស់គេស្ថិតក្នុងការលំបាក ដែលទាមទារឲ្យមានការយកចិត្តទុកដាក់លើបញ្ហា និងតម្រូវការរបស់ពួកគេដែលក្នុងនោះមាន៖

- ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទមានចំនួន២១នាក់ក្នុងឆ្នាំ២០១០
- ចំនួនគ្រួសារដែលមានសមាជិកប្រើប្រាស់គ្រឿងញៀនចំនួន២០៦គ្រួសារក្នុងឆ្នាំ២០១០
- ចំនួនគ្រួសារដែលមានសមាជិកកើតជម្ងឺអេដស៍មានចំនួន៨៩៦នាក់
- ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំដោយសារអេដស៍មានចំនួន១,៣៩៦នាក់
- ចំនួនកុមារកំព្រាទូទៅ មានចំនួន៤,៧៣២នាក់
- ចំនួនមនុស្សចាស់គ្មានទីពឹងមានចំនួន១,២៥៤នាក់
- ចំនួនជនពិកាមិនអាចរកចំណូលបានមានចំនួន១,១៨៦នាក់
- ចំនួនជនពិការក្រោមអាយុ១៨ឆ្នាំមាន៧០៤នាក់។

## ១-២.២.៣ ស្ថានភាពយេនឌ័រ

បច្ចុប្បន្ននេះ សមាសភាពក្រុមប្រឹក្សាខេត្ត ក្រុង និងស្រុកជាស្ត្រីមានចំនួន២០នាក់ ក្នុង

ចំណោម១៥៣នាក់ ដែលក្នុងនោះក្រុមប្រឹក្សាខេត្តមានចំនួន២នាក់ ក្រុងច្បារមនមាន ចំនួន៣នាក់ ស្រុកសំរោងទង២នាក់ ស្រុកគងពិសី២នាក់ ស្រុកបរសេដ្ឋ៣នាក់ ស្រុកឧដុង្គ២នាក់ ស្រុកថ្ពង២នាក់ ស្រុកភ្នំស្រួច២នាក់ ស្រុកឱរ៉ាល់២នាក់។ តួនាទីរបស់ស្ត្រីក្នុងគណៈអភិបាលខេត្ត ក្រុង ស្រុកក្នុងឆ្នាំ២០០៨មានចំនួន៩នាក់ ក្នុងចំណោមចំនួនសរុប៤៥នាក់ ហើយចំនួននេះនៅតែថេររហូតដល់ឆ្នាំ២០១០។ ចំនួនស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំមានចំនួន៥៥នាក់នៅក្នុងចំណោម៦០៦ នាក់ សម្រាប់ ៥សង្កាត់ និង៨២ឃុំ ដែលក្នុងនោះមេឃុំ-សង្កាត់ជាស្ត្រីមានចំនួន៣នាក់ ជំទប់ទី១ជាស្ត្រី មានចំនួន ៣នាក់ ជំទប់ទី២ជាស្ត្រីមានចំនួន៩នាក់ និងអ្នកទទួលបន្ទុកកិច្ចការនារីមានចំនួន៨៥នាក់ ក្រៅពីក្រុមប្រឹក្សាឃុំ-សង្កាត់។ ចំនួនថ្នាក់ដឹកនាំភូមិជាស្ត្រីមានចំនួន១២២២នាក់ ក្នុងចំណោមថ្នាក់ដឹកនាំភូមិចំនួន៣៩៥៧នាក់ទូទាំងខេត្ត ដែលក្នុងនោះ មេភូមិជាស្ត្រីមានចំនួន៣៣នាក់អនុភូមិជាស្ត្រី មានចំនួន១២៨នាក់ និងជំនួយការភូមិជាស្ត្រីមានចំនួន១០៦៥នាក់។ ទិន្នន័យខាងលើនេះបានបង្ហាញថា ចំនួនស្ត្រី ដែលចូលរួមក្នុងការសម្រេចចិត្តមានចំនួនតិចនៅឡើយបើប្រៀបធៀបនឹងចំនួនបុរស។

អនុវត្តតាមអនុសាសន៍ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្តដែលមានមន្ទីរកិច្ចការនារីនិងមន្ទីរនានា ដែលមានការពាក់ព័ន្ធជាសេនាធិកាបានយកចិត្តទុកដាក់ ជំរុញការលើកកម្ពស់សិទ្ធិរបស់ស្ត្រី តាមរយៈការតែងតាំងថ្នាក់ដឹកនាំស្ត្រីនៅតាមមន្ទីរ និងអង្គភាពនានារបស់ខេត្ត ដូចជា ស្ត្រីក្នុងក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង-ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈអភិបាលខេត្ត គណៈអភិបាលក្រុង-ស្រុក ប្រធាននិងអនុប្រធានមន្ទីរជាដើម ដើម្បីផ្តល់ឱកាសឲ្យស្ត្រីបានបញ្ចេញសមត្ថភាពរបស់ខ្លួន ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តលើគ្រប់សកម្មភាពនិងវិស័យរបស់ខេត្ត។ ជាពិសេសស្ត្រីថ្នាក់ដឹកនាំអាចធ្វើជាគំរូដល់ស្ត្រីជំនាន់ក្រោយ និងជួយជំរុញលើកស្ត្រីឲ្យមានភាពក្លាហានហ៊ានបញ្ចេញសមត្ថភាពដូច និងបុរសដែរ។ លើសពីនេះយើងសង្កេតឃើញថា ចំនួនមន្ត្រីរាជការស៊ីវិលនៅតាមមន្ទីរ និងអង្គភាពជាស្ត្រីមានការកើនឡើងគួរឲ្យកត់សម្គាល់ លើសពីនេះទៀត ដោយមានការជួយជ្រោមជ្រែងផ្តល់ថវិកាពីកម្មវិធី គ.ជ.អ.ប កម្មវិធីសិទ្ធិកុមារ អង្គការជាតិ និងអន្តរជាតិនានា ខេត្តបានធ្វើការចុះអប់រំផ្សព្វផ្សាយពីបញ្ហាយេនឌ័រ ទៅដល់ប្រជាពលរដ្ឋ ចាប់ពីទីក្រុងដល់សហគមន៍ជនបទ ដែលធ្វើឲ្យបច្ចុប្បន្ននេះ យើងអាចបានទទួលស្គាល់ថា គំលាតរវាងស្ថានភាពស្ត្រី និងបុរសត្រូវបានកាត់បន្ថយក្នុងកម្រិតមួយដ៏ល្អ ប៉ុន្តែពុំមានសូចនាករ និងតួរលេខច្បាស់លាស់នៅឡើយ។

មានបុរសជាច្រើនបានទទួលស្គាល់ពីតម្លៃស្ត្រីជាមេផ្ទះ និងបានចាត់ទុកថា ការងារក្នុងផ្ទះ និងការមើលថែទាំកូនជាការងាររួម ដោយមិនប្រកាន់ឡើយ។ ប៉ុន្តែក៏មានគ្រួសារ ខ្លះប្តីនៅប្រកាន់គំនិតចាស់គំរិល ហើយបែងចែកការងារខាងក្រៅ និងខាងក្នុងផ្ទះដែលពេលខ្លះនាំឲ្យមានការ

ឈ្លោះទាស់ទែងគ្នានាំឲ្យមានអំពើហិង្សាក្នុងគ្រួសារ។ ចំនួនសិស្សស្រ្តីនៅតាមភូមិ សិក្សាក៏មានការកើនឡើងផងដែរ ហើយមានសិស្សស្រ្តីជាច្រើនត្រូវបានចាត់តាំងធ្វើជាប្រធានថ្នាក់ និងរៀនសូត្រ បានទទួលចំណាត់ថ្នាក់ល្អ ក្នុងការសិក្សាទៀតផង។ ទន្ទឹមនិងនេះ ក៏មានបញ្ហាប្រឈមដូចជាសិស្ស ស្រ្តីក្រីក្រ និងនៅតាមជនបទមួយចំនួនត្រូវបាន ឱពុកម្តាយបង្ខំឲ្យឈប់រៀន ដើម្បីនៅផ្ទះដាំបាយ មើលប្អូនតូច ទៅធ្វើការជាកម្មការនីរោងចក្រ ឬសំណង់ ធ្វើចំណាកស្រុក រហូតមានស្រ្តីវ័យក្មេងខ្លះ ចាញ់បោកគេធ្លាក់ខ្លួនប្រកបរបរអណាចារក៏មាន។

ជាទូទៅចំនួនស្រ្តីមានចំណេះដឹង មានតិចជាងបុរសដោយសារឱកាស នៃការសិក្សាមានតិចជាងបុរសជាហេតុធ្វើឲ្យសមត្ថភាពបំពេញការងារទាំងឡាយ នៅតាមសហគមន៍ ឬនៅតាមស្ថាប័នរដ្ឋាភិបាល មានចំនួនតិចជាងបុរសផងដែរ។ ប៉ុន្តែកន្លងមកខេត្ត បានយកចិត្តទុកដាក់ក្នុងការបំពាក់បំប៉នសមត្ថភាពដល់ស្រ្តី នៅតាមសហគមន៍បានច្រើនបង្គួរផងដែរ ដែលអាចឲ្យស្រ្តីមួយចំនួនបានចូលប្រលូកក្នុងការងារសហគមន៍ក៏ដូចជា ក្នុងជួរក្រុមប្រឹក្សាឃុំ-សង្កាត់ និងគណៈកម្មការនានា របស់ឃុំ-សង្កាត់ ដែលជាចំនុចផ្តើមដ៏ល្អក្នុងការពង្រឹងសមត្ថភាពរបស់ស្រ្តី និងជំរុញការចូលរួមរបស់ស្រ្តី ក្នុងការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានយ៉ាងសកម្ម។

ម៉្យាងទៀត យើងសង្កេតឃើញមានស្រ្តីជាច្រើន បានដើរតួយ៉ាងសំខាន់ក្នុងការរកចំណូលសម្រាប់គ្រួសារ ដោយបានទៅប្រកបរបរក្រៅពីមេផ្ទះ ដូចជាធ្វើជាកម្មការនីរោងចក្រកម្មករសំណង់ បុគ្គលិកក្រុមហ៊ុននានាដែលអាចចិញ្ចឹមជីវិតផ្ទាល់ខ្លួនរបស់ពួកគេ និងគ្រួសារទាំងមូលទៀតផង។

### ១-២.២.៤ ស្ថានភាពភាពក្រីក្រ

**តារាងស្តីពីស្ថានភាពក្រីក្រក្នុងខេត្តកំពង់ស្ពឺ**




| | ច្បារមន | សំរោងទង | គងពិសី | ឧដុង្គ | បរសេដ្ឋ | ភ្នំស្រួច | ថ្ពង | ឱរ៉ាល់ |
|---|---|---|---|---|---|---|---|---|
| 2005 | 32.28 | 37.61 | 38.65 | 40.08 | 42.03 | 42.59 | 44.02 | 50.41 |
| 2009 | 16.58 | 29.53 | 31.00 | 29.97 | 36.00 | 36.85 | 36.85 | 42.28 |
| 2010 | 14.37 | 27.29 | 28.44 | 28.94 | 33.80 | 33.95 | 34.21 | 40.22 |

## និន្នាការភាពក្រីក្រតាមបណ្ដាឆ្នាំ




| កូដ | ខេត្ត | ក្រុង ស្រុក ខណ្ឌ | 2005 | 2006 | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|---|---|---|
| 501 | កំពង់ស្ពឺ | បរសេដ្ឋ | 42.03 | 41.52 | 39.95 | 38.27 | 36.00 | 33.80 |
| 502 | កំពង់ស្ពឺ | ច្បារមន | 32.28 | 31.75 | 20.93 | 18.24 | 16.58 | 14.37 |
| 503 | កំពង់ស្ពឺ | គងពិសី | 38.65 | 37.49 | 36.21 | 33.85 | 31.00 | 28.44 |
| 504 | កំពង់ស្ពឺ | ឱរ៉ាល់ | 50.41 | 48.78 | 48.14 | 46.52 | 42.28 | 40.22 |
| 505 | កំពង់ស្ពឺ | ឧដុង្គ | 40.08 | 38.82 | 36.42 | 33.99 | 29.97 | 28.94 |
| 506 | កំពង់ស្ពឺ | ភ្នំស្រួច | 42.59 | 42.57 | 40.96 | 39.23 | 36.85 | 33.95 |
| 507 | កំពង់ស្ពឺ | សំរោងទង | 37.61 | 36.87 | 34.88 | 32.61 | 29.53 | 27.29 |
| 508 | កំពង់ស្ពឺ | ថ្ពង | 44.02 | 43.99 | 41.67 | 40.13 | 36.85 | 34.21 |
| អត្រាភាពក្រីក្រទូទាំងខេត្ត | | | 40.28 | 39.48 | 37.33 | 35.23 | 32.21 | 30.06 |

តាមរយៈទិន្នន័យនេះ យើងអាចវាយតម្លៃបានថា ភាពក្រីក្ររបស់ប្រជាពលរដ្ឋមានការថយចុះបន្តិចម្ដងៗ ទោះជាយ៉ាងណាការថយចុះនេះហាក់មានល្បឿនយឺតនៅឡើយ ដែលទាមទារឲ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋខិតខំបន្ថែមទៀត។

កត្តាសំខាន់ៗដែលនាំឲ្យមានភាពក្រីក្រមានដូចជា៖

- សមាជិកគ្រួសារកើតជម្ងឺរ៉ាំរ៉ៃ ជាពិសេសមេគ្រួសារដែលជាអ្នករកចំណូល
- ការខ្វះខាតនូវមុខរបរចិញ្ចឹមជីវិត ដោយសាភាពមិនចេះអក្សរ និងកង្វះសមត្ថភាពដោយសារមិនសូវមានការងារធ្វើ និងមិនសូវមានវិនិយោគ
- ខ្វះដីស្រែ និងដីចំការក្នុងការប្រកបរបរកសិកម្ម
- ទិន្នផលស្រូវនូវមានកម្រិតទាប

- ប្រព័ន្ធធារាសាស្ត្រនៅមិនទាន់ឆ្លើយតបទៅនិងផ្ទៃដីស្រោចស្រពបច្ចេកទេសកសិកម្មនៅមានកម្រិត។

ដើម្បីបញ្ចៀសភាពក្រីក្រខេត្ត ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការបន្ថយចំណុចអវិជ្ជមានទាំងនេះដើម្បីធានាការកាត់បន្ថយភាពក្រីក្រ ឲ្យនៅកម្រិតអប្បបរិមាបំផុត។

### ១-២.២.៥.សង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា

បច្ចុប្បន្ននេះ មន្ទីរសង្គមកិច្ចបានយកចិត្តទុកដាក់ក្នុងការងារសំខាន់ៗ របស់ខ្លួនដូចជា ការងារសោធននិវត្តន៍ និងការងារចាស់ជរា ត្រូវបានយកចិត្តទុកដាក់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវដើម្បីធានាការបើកប្រាក់សោធននិវត្តន៍ប្រចាំខែបានទាន់ពេលវេលា ពិសេសការជំរុញការងារសមាគមចាស់ជរាឲ្យមានដំណើរការល្អ។ ការការពារសិទ្ធកុមារ និងទប់ស្កាត់ ការជួញដូរស្ត្រីនិងកុមារក៏បានពង្រីកសកម្មភាពនៅតាមសហគមន៍គោលដៅ ដោយប្រើប្រាស់ ថវិការដ្ឋាភិបាលនិងអង្គការដៃគូនានា។ ចំណែកកុមារកំព្រា និងជនអនាថាក៏បានបន្តការជួយសង្គ្រោះតាមលទ្ធភាពនៃថវិកាដែលមាន ។ ចំពោះជនពិការក៏កំពុងមានការយកចិត្តទុកដាក់តាមរយៈការផ្តល់ជារទេះរុញនិងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីចិញ្ចឹមជីវិត។

### ១-២.២.៦ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វិស័យនេះ ខេត្តកំពង់អនុវត្តយ៉ាងសកម្មផងដែរដើម្បីជំរុញការអនុវត្តច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានា ស្តីពីតួនាទីសហជីពក្នុងគោលដៅដើម្បីធានានូវសិទ្ធ និងផលប្រយោជន៍កម្មករព្រោះខេត្តកំពង់ស្ពឺ មានការរីកចម្រើនខាងវិស័យរោងចក្រកាត់ដេរ។ ដូច្នេះខេត្ត បានធ្វើការតាមដានតាមរោងចក្រ ដើម្បីធានាឲ្យកម្មករទទួលបាននូវលក្ខខ័ណ្ឌការងារល្អ ជំរុញការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខ និងធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ។ ចំពោះការងារបណ្តុះបណ្តាល ក៏ត្រូវបានអនុវត្តបានល្អ ដោយបានបន្តបើកវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងរយៈពេលវែងតាមលទ្ធភាពនៃថវិកា ដូចជាការចិញ្ចឹមត្រី ជ្រូក ការកាត់ដេរសំលៀកបំពាក់ ការកែសម្ផស្ស ជំនាញកុំព្យូទ័រ ការជួសជុលម៉ាញ៉េ ទូរទស្សន៍ ម៉ូតូ និងបរិក្ខាអគ្គីសនី ធ្វើយ៉ាងណាឲ្យយុវជនដែលគ្មានលទ្ធភាព ទទួលបាននូវវិជ្ជាជីវៈដើម្បីចិញ្ចឹមជីវិត។

### ១-២.២.៧ វប្បធម៌ និងវចិត្រសិល្បៈ

វិស័យវប្បធម៌ត្រូវអភិវឌ្ឍន៍ និងអភិរក្សយ៉ាងយកចិត្តទុកដាក់ តាមការណែនាំពីថ្នាក់ជាតិ និងមានការសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋ។ ការបណ្តុះបណ្តាលជាបន្តបន្ទាប់នូវជំនាញសិល្បៈសូនរូប និងសិប្បកម្ម (តម្បាញ ចម្លាក់ និងគំនូរ ) ។ការងារសិល្បៈទស្សនីយភាព ក៏កំពុងបណ្តុះបណ្តាលយុវជនជំនាន់ក្រោយលើវិជ្ជាជីវៈ របាំល្ខោន ចាប៉ី ភ្លេងសម័យ និងបុរាណ ព្រមទាំងមានការបើកជាមហោស្រពទៀតផង។ ការប្រមូលវត្ថុបុរាណដែល

នៅវាយប៉ាយមករក្សាទុកក្នុងសារមន្ទីរ។ បន្តអភិរក្ស និងអភិវឌ្ឍវប្បធម៌ជនជាតិដើមភាគតិចតាមរយៈការរៀបចំភូមិវប្បធម៌។ អនុវត្តការចុះបញ្ជីបេតិកភ័ណ្ឌបោះបង្គោលដែនការពារបេតិកភណ្ឌ និងធ្វើប្លង់កាន់កាប់ជាសម្បត្តិរដ្ឋ។ យកចិត្តទុកដាក់ក្នុងការទប់ស្កាត់ការជួល និងចាក់វីដេអូអាសអាភាស។

### ១-២.២.៨ ព័ត៌មាន

មន្ទីរព័ត៌មានមានតួនាទីក្នុងការផ្សាយព័ត៌មាន និងសោតទស្សន៍ ក្នុងក្របខ័ណ្ឌខេត្ត ដែលក្នុងនោះរួមមាន ព័ត៌មាន តាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ព្រឹត្តប័ត្រ សារព័ត៌មាន និងរូបថត ...., ។ល។ ខេត្តបានបង្កលក្ខណៈឲ្យក្រុមហ៊ុនឯកជនតម្លើងទូរទស្សន៍ខ្សែកាប១កន្លែង។ បណ្ដុះបណ្ដាលទេសអ្នកយកព័ត៌មាន ជួសជុលអាគារ និងស្នីឌីយោថតផ្សាយ និងមានខិតខំកៀរគររកប្រភពថវិកាដើម្បីអភិវឌ្ឍវិស័យនេះ ឲ្យកាន់តែប្រសើរ។

### ១-២.២.៩ វិស័យធម្មការ និងសាសនា

ខេត្តកំពង់ស្ពឺ មានវត្តចំនួន២៨២ ក្នុងនោះវត្តធម្មយុត្តិមានចំនួន១៦វត្ត និងមហានិកាយចំនួន២៦៦វត្ត ហើយភាគច្រើនជា វត្តដែលមានព្រះវិហារ ឧបដ្ឋានសាលាត្រឹមត្រូវ ដើម្បីបម្រើឲ្យពុទ្ធសាសនិកជនដែលគោរពបូជាសាសនាព្រះពុទ្ធ ដែលជាសាសនារបស់រដ្ឋ ក្នុងការធ្វើបុណ្យទានផ្សេងៗ ។ ចំណែកព្រះសង្ឃមានចំនួនសរុប ៣,២៨៦អង្គ ក្នុងនោះភិក្ខុចំនួន១,១៧៨អង្គ សាមណេរចំនួន២,១០៨ អង្គ។ សាលាធម្មវិន័យមានចំនួន៥៥សាលា មានសាមណសិស្សចំនួន៦៥៣អង្គ។ សាលាពុទ្ធិកបឋមមានចំនួន២១សាលា មានសាមណសិស្សចំនួន៣៨៥អង្គ។ ពាហិរសាសនាមាន គ្រឹស្ទសាសនាមាន៦៩កន្លែង ក្នុងនោះព្រះវិហារមាន៥២កន្លែង និងទីស្នាក់ការថ្វាយបង្គំ១៧កន្លែង។ សូរ៉ាវ ឬឥស្លាមមាន១ កន្លែង វិហារចិនមាន១កន្លែង។

ទន្ទឹមនិងនេះក៏មានកង្វះខាតខ្លះៗដែរ ដែលខេត្តត្រូវបន្តអនុវត្តដូចជា៖

- លើកកម្ពស់ការប្រតិបត្តិធម្មវិន័យរបស់ព្រះសង្ឃ និងគ្រហស្ថ
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវបទបញ្ញាត្តិអមពុទ្ធវិន័យ សង្ឃប្រកាសសារាចរណ៍ណែនាំ
- ប្រជុំមន្ត្រីសង្ឃ និងធម្មការខេត្ត ស្រុកដើម្បីពង្រឹងតួនាទីភារកិច្ច និងដឹកនាំវិស័យសាសនា
- អប់រំផ្សព្វផ្សាយពីក្រមសីលធម៌របស់អាចារ្យ ឲ្យអនុវត្តឲ្យត្រូវទៅតាមប្រពៃណីជាតិ។

### ១-២.២.១០ វិស័យទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច

បច្ចុប្បន្ន ខេត្តបានផ្សព្វផ្សាយច្បាប់មួយចំនួនដូចជា ច្បាប់ភូមិបាល ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ចរាចរផ្លូវគោក...។ ប៉ុន្តែការផ្សព្វផ្សាយទាំងនេះ នៅ

មានកម្រិត ដោយសារស្ថានចំណេះដឹងនៃការទទួលបាន និងផ្តល់ឲ្យនៅមានកម្រិតព្រមទាំងធនធានដែលត្រូវធ្វើការផ្សព្វផ្សាយនៅមានកម្រិត។ ចំពោះការតាមដានការអនុវត្តច្បាប់ មិនទាន់ធ្វើបានទូលំទូលាយ និងឲ្យមានសុក្រិតនៅឡើយទេ ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅមានកម្រិត ដោយសារមន្ត្រីមានសមត្ថកិច្ចមិនមានអំណាចគ្រាន់គ្រាន់ ដោយសារភាគីទំនាស់ ជាអ្នកមានអំណាច។ ជាយុទ្ធសាស្ត្រ ការផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់ក្នុងវិស័យផ្សព្វផ្សាយច្បាប់នេះជារឿងសំខាន់ និងផ្តល់អាទិភាពលើការអនុវត្តច្បាប់ ដោយផ្តល់អំណាចដល់មន្ត្រីតាមដានការអនុវត្តច្បាប់ និងដាក់ទោស ណ្ដាដល់មន្ត្រីដែលមិនគោរពច្បាប់ ឬបំពានច្បាប់។

## ១.២.៣ ស្ថានភាព នៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ផ្អែកតាមទីតាំងភូមិសាស្ត្រ និងស្ថានភាពជាក់ស្តែងរបស់ខេត្តកំពង់ស្ពឺ ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៅមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីប្រើប្រាស់នូវសក្តានុពលដែលខ្លួនមាន បើទោះបីសណ្ឋានដីនៅតំបន់ខ្លះមានដីជាតិល្អ មធ្យម និងមានតំបន់វាលរាបសម្រាប់ផលិតកម្មសិកម្ម និងសំណង់លំនៅដ្ឋានក៏ដោយ។ កង្វះខាតប្រភពទឹក និងប្រព័ន្ធធារាសាស្ត្រ ធ្វើឲ្យការប្រើប្រាស់ដីធ្លីសម្រាប់វិស័យកសិកម្ម និងវិស័យសំខាន់ទៀត ហាក់មិនទាន់ឆ្លើយតបនឹងតម្រូវការបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ជាហេតុធ្វើឲ្យការគ្រប់គ្រង ធនធានធម្មជាតិ និងបរិស្ថាន ក៏ត្រូវរងផលប៉ះពាល់មួយចំនួនធំដែរ ដែលនោះជាផលនៃការអនុវត្តមិនទាន់ល្អ នៃប្រព័ន្ធច្បាប់បូកផ្សំនឹងកម្រិតការយល់ដឹង និងស្ថានភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតំបន់ ដែលការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានត្រូវការការពារនិងអភិវឌ្ឍន៍។ តែទោះបីជាយ៉ាងនេះក្តី កំណែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន របស់រាជរដ្ឋាភិបាល និងដោយមានការយកចិត្តទុកដាក់ពីបណ្តាអង្គភាពពាក់ព័ន្ធ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការវិវឌ្ឍជាច្រើនទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធនិង កម្រិតការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន មានការកើនឡើងជាក់ស្តែង ចំនួនគ្រួសាររងគ្រោះដោយធម្មជាតិមានការថយចុះពី៩.២៣៧នាក់ នៅឆ្នាំ២០០៧ មកនៅត្រឹមតែ៩៤នាក់ប៉ុណ្ណោះ នៅឆ្នាំ២០១០នេះ ប៉ុន្តែក្នុងនោះចំនួនករណីរឿងដីធ្លីមានការកើនឡើងវិញនៅដើមឆ្នាំ២០០៩។

### ១.២.៣.១ ការប្រើប្រាស់ដីធ្លី

ការប្រើប្រាស់ដីធ្លី មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្នុងខេត្ត

ព្រោះថា ប្រជាពលរដ្ឋ ៩២.០៦% មានមុខរបរកសិកម្មជាចំបង។ ការប្រើប្រាស់ដីនៅខេត្តកំពង់ស្ពឺអាច ចែកចេញជា៥ចំណាត់ថ្នាក់សាមញ្ញរួមមាន: ដីលំនៅដ្ឋាន ដីកសិកម្ម (ស្រែវស្សា និងចំការ)

ដីព្រៃ តាមតំបន់ភ្នំ ដីខ្សោះ ដីជាតិគ្មានរុក្ខជាតិដុះ និងដីអាងស្តុកទឹក (ស្ទឹង ប្រឡាយ អូរ និង ត្រពាំង)។ ការកាន់កាប់ និងគ្រប់គ្រងដីធ្លីក្រៅពីដីលំនៅដ្ឋាន និងដីស្រែចំការដែលជាកម្មសិទ្ធិរបស់ឯកជន គឺសុទ្ធសឹងជាដីរបស់រដ្ឋដែលស្ថិតនៅក្រោមរូបភាពពីរៈ ទី១-ដីឯកជនរបស់រដ្ឋ ដែលភាគច្រើនជាតំបន់ភ្នំ និងតំបន់ខ្ពង់រាបស្ថិតនៅក្នុងបណ្តាស្រុកទាំង៧ លើកលែងក្រុងច្បារមនមួយចេញ និង ទី២ ដីសាធារណៈរបស់រដ្ឋ ដោយស្ថានភាពភូមិសាស្ត្រខេត្ត ស្ថិតនៅជាប់ព្រំប្រទល់ ខេត្តកោះកុង ខេត្ត ព្រះសីហនុ ដូច្នេះដីសាធារណៈរបស់រដ្ឋមានលក្ខណៈជាដីព្រៃធំៗ ឬតំបន់ការពារតំបន់អភិរក្សធំៗ តំបន់ការពារជាលក្ខណៈសហគមន៍ និងតំបន់រដ្ឋបាលសាធារណៈដូចជា មន្ទីរពេទ្យ សាលារៀន ផ្លូវ ថ្នល់ វត្តអារ៉ាម និងអាងទំនប់។

បន្ថែមលើនេះអាជ្ញាធរខេត្ត ជាពិសេសមន្ទីរបរិស្ថានបានបង្កើតនូវតំបន់ការពារជាលក្ខណៈសហគមន៍ជាច្រើន ហិចតាទៀត។ ស្ថានភាពនៃការកាន់កាប់ និងគ្រប់គ្រងដី នៅក្នុងខេត្តទាំងមូលមានដីកម្មសិទ្ធិរបស់ឯកជន និងដីរបស់រដ្ឋ គឺកំពុងធ្វើឲ្យមានភាពច្បាស់លាស់តាមរយៈការចុះបញ្ជីជាប្រព័ន្ធ ដែលពីមុនដីភាគច្រើន គឺពុំមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនទ្រព្យ ដែលជាហេតុធ្វើឲ្យទំនាស់ដីធ្លីកើតមានជាច្រើនករណីដូចជាៈ ទំនាស់ដោយសារដណ្តើមទាមទារដីកេរ្តិ៍អាករ ទំនាស់ ដោយសារព្រំប្រទល់ដីមិនច្បាស់លាស់ ទំនាស់ដោយសារការទន្រ្ទានកាន់កាប់ដីដោយខុសច្បាប់ និងទំនាស់ដោយសារចេញប័ណ្ណកាន់កាប់ដីជាន់គ្នា ហើយជាក់ស្តែងក្នុងឆ្នាំ២០១០នេះ ខេត្តកំពង់ស្ពឺ។

មានទំនាស់ដីធ្លីរហូតដល់ ១,១៧៣ករណី និងគ្រួសារ ដែលមានលំនៅដ្ឋាន នៅលើដីសាធារណៈចំនួន៥០៦គ្រួសារ។ ផលធៀបចំនួនទំនាស់ដីធ្លីក្នុង១,០០០គ្រួសារ មាន១០.០៤% ក្នុងឆ្នាំ២០០៨ ៩.៣០% ក្នុងឆ្នាំ២០០៩ និង៨.៦៤% ក្នុងឆ្នាំ២០១០។ គណៈកម្មការសុរិយោដីខេត្ត និងអាជ្ញាធរស្រុក-ឃុំបានយកចិត្តទុកដាក់ដោះស្រាយវិវាទ ដីធ្លីដែលមានក្នុងដែនសមត្ថកិច្ចជាបន្តបន្ទាប់ទំនាស់ដីធ្លីកំពុងដោះស្រាយមាន១៣ករណី នៅឆ្នាំ២០១០ ជាពិសេស ទំនាស់ដីធំៗនៅតំបន់ស្រុកភ្នំស្រួច និងឱរ៉ាល់រវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនឧកញ៉ាលីយ៉ុងផាតត្រូវបានបញ្ចប់តាមផ្លូវច្បាប់ទោះបីនៅមានការតវ៉ាបន្តិចបន្តួចក្តី។

ចំពោះដីលំនៅដ្ឋាននៅក្នុងខេត្តគឺ សំដៅទៅដល់ដីដែលប្រើប្រាស់សម្រាប់សង់លំនៅដ្ឋាន អគាររដ្ឋបាល និងសម្រាប់ដាំដំណាំសួនជាលក្ខណៈគ្រួសារនៅឆ្នាំ២០១០ មានការកើនឡើងប្រមាណ៥០% ដែលនេះជាតម្រូវការមួយធ្វើឲ្យតម្លៃដីធ្លីសម្រាប់លំនៅដ្ឋានកើនឡើងមួយកម្រិតទៀត។

ផ្ទៃដីកសិកម្មជាតម្រូវការ ដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋនៅក្នុងខេត្ត ដែលឆ្នាំ២០១០ ប្រមាណ៩២.០៦% ជាប្រជាកសិករប្រកបរបរធ្វើស្រែ និង០.៣៥% ជាប្រជាកសិករប្រកប

របរធ្វើចំការ។ បច្ចុប្បន្នខេត្តកំពុងរៀបចំឲ្យមានប្រភេទដំណាំ ដើម្បីគាំទ្រដល់វិស័យឧស្សាហកម្ម ដែលមានទ្រង់ទ្រាយធំ បើទោះបីជាស្ថានភាពផ្ទៃដីខេត្ត មិនមានដីទំនេរសម្រាប់ដាំដំណាំលក្ខណៈជាឧស្សាហកម្ម ម្យ៉ាងដោយដីទំនេរខ្លះជាដីព្រៃស្ថិតក្រោមការគ្រប់គ្រងការពារ និងអភិរក្ស ហើយនោះជាលក្ខណៈដីភ្នំ។

យើងឃើញមានបញ្ហាមួយចំនួន ដែលកើតមានចំពោះការគ្រប់គ្រងដីធ្លី ដែលតម្រូវឲ្យអាជ្ញាធរខេត្ត ត្រូវតែដោះស្រាយ។ បញ្ហាទាំងនោះមានៈ អ្នកកាន់កាប់ឯកជនភាគច្រើនគ្មានប័ណ្ណកាន់កាប់ ហើយការចេញប័ណ្ណតាមរយៈការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំមានភាពយឺតយ៉ាវ។ ប្រព័ន្ធចុះបញ្ជីដីអភិវឌ្ឍន៍មិនបានល្អ និងគ្មានតម្លាភាព។ ពុំទាន់មានផែនការគោលសុរិយោដីហើយការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធមានត្រឹមកម្រិតគម្រោងសាកល្បងប៉ុណ្ណោះ។ ច្បាប់និង នីតិវិធីពាក់ព័ន្ធពុំមានគ្រប់គ្រាន់។ ការផ្សព្វផ្សាយព័ត៌មាន និងការអប់រំដីធ្លីនៅមានកម្រិត ហើយការយល់ដឹងអំពីសិទ្ធិលើដីធ្លីក្នុងចំណោមប្រជាពលរដ្ឋក្នុងខេត្តនៅទាប។ ផែនការប្រើប្រាស់ដី និងការគ្រប់គ្រងធនធានធម្មជាតិ មិនបានធ្វើសមាហរណកម្មជាមួយគ្នា និងមិនបានធ្វើវិមជ្ឈការ។ ដីរដ្ឋមិនបានធ្វើអត្តសញ្ញាណកម្មច្បាស់លាស់ ហើយការគ្រប់គ្រងមិនបានត្រឹមត្រូវបន្ទាប់ពីដំណើរការអន្តរកាល ដែលនាំទៅរកការបង្កើនល្បឿន នៃការរំលោភយកដី និងការកាប់បំផ្លាញព្រៃឈើ។ គ្រួសារក្រីក្រជាច្រើនគ្មានដី ឬដីតិចសម្រាប់ការចិញ្ចឹមជីវិត។ ដីបង្កបង្កើនផលភាគច្រើន មិនសុទ្ធតែស្ថិតក្នុងការផលិតទេ។ ភាពក្រីក្រធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនមិនមានលទ្ធភាពទិញឬជួលដីបាន។ ក្នុងនោះដែរ ដីសម្បទានសង្គមកិច្ច ដីសម្បទានកសិកម្ម ដីសម្បទានដាំដុះ និងដីសម្បទាន នៅទំនេរមិនទាន់មានការស្រុះស្រួលគ្នា១០០%នៅឡើយ។

ទន្ទឹមនឹងវឌ្ឍនភាពខាងលើ បញ្ហាប្រឈមមួយចំនួនត្រូវបន្តដោះស្រាយរួមមានៈ

- គោលនយោបាយរៀបចំដែនដី គោលនយោបាយជាតិ ស្តីពីលំនៅឋាន និងសារាចរណែនាំ ស្តីពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នក្នុងទីក្រុង និងទីប្រជុំជនពុំទាន់បានចាត់តាំងអនុវត្តឲ្យមានប្រសិទ្ធភាពនាំឲ្យមានបាតុភាពសាងសង់សំណង់ថ្មី ៗ នៅលើដីសាធារណៈកើតមានជាបន្តបន្ទាប់ស្របពេល ករណីចាស់ពុំទាន់បានដោះស្រាយ
- ប្រជាពលរដ្ឋត្អូញត្អែរពីថ្លៃសេវាក្រៅផ្លូវការក្នុងការផ្ទេរអចលនទ្រព្យ និងជាកត្តានាំឲ្យប្រជាជនគេចវេស ពីការផ្ទេរដីធ្លីតាមនីតិវិធីសុរិយោដី និងនាំឲ្យបាត់បង់ពន្ធប្រថាប់ត្រាស្របពេលដែលប្រព័ន្ធវាយតម្លៃថ្លៃដីផែនទីថ្លៃដី ពុំទាន់មានតម្លាភាព គណនេយ្យភាព។ ឯការងារ សាងសង់ក៏មានបញ្ហាប្រហាក់ប្រហែលគ្នានេះដែរ
- ការប្រមូលទិញដីបង្កកទុក ដោយមិនប្រើប្រាស់ និង មិនធ្វើផលិតកម្មលើដីទាំងនោះ ក៏

នៅមានកម្រិត

- ប្រជាពលរដ្ឋប្រមាណ១០% ត្រូវបានបាត់បង់ដីធ្លីគ្មានដីបង្កបង្កើនផលដោយសារភាពក្រីក្រ និងជម្ងឺដោយលក់ដីទៅឲ្យអ្នកដទៃ
- ទំនាស់ដីធ្លីនៅកើតមានជាបន្តបន្ទាប់ ផ្តើមចេញពីការយល់ដឹងច្បាប់ភូមិបាល នៅមានកម្រិត និងបំពានលើច្បាប់។

### ១.២.៣.២ ធនធានធម្មជាតិ

ដោយសារផ្ទៃដីមួយភាគធំរបស់ខេត្តកំពង់ស្ពឺ ជាតំបន់ខ្ពស់រាប ហើយមានភ្នំព័ទ្ធជុំវិញជាហេតុធ្វើឲ្យខេត្ត មិនសូវមានលក្ខណៈអំណោយផលគ្រាប់គ្រាន់សម្រាប់ប្រភពស្ទឹង បឹងបួរ ដែលជា លក្ខខណ្ឌមួយចាំបាច់សម្រាប់ការ ប្រកបរបរកសិកម្មរបស់ប្រជាពលរដ្ឋក្នុងខេត្ត ដែលនោះជាធនធានធម្មជាតិមួយដ៏សំខាន់ ដែលរាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរខេត្តកំពុងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង។ ធនធានទឹកដ៏សំខាន់នេះ បានធ្វើឲ្យប្រជាពលរដ្ឋដែលមានទីតាំងស្ថិតនៅជាប់នឹង ប្រភពទឹកនោះ ប្រើប្រាស់នូវសក្តានុពល ដែលខ្លួនមានសម្រាប់ការបង្កើនសេដ្ឋកិច្ចគ្រួសារតាមរយៈការធ្វើកសិកម្មទាំងរដូវប្រាំង និងវស្សា ការដាំដុះផ្សេងៗ និងក៏មានការវិនិយោគពីវិស័យឯកជនផង ដែរលើការចិញ្ចឹមសត្វ និងការដាំដុះលើ ដំណាំឧស្សាហកម្មផ្សេងៗ។

កង្វះខាតប្រភពទឹកនេះ ក៏ជាហេតុផលមួយធ្វើឲ្យការនេសាទនៅក្នុងខេត្ត មិនសូវមានសក្តានុពលខ្លាំងក្លាដូចបណ្តាខេត្តដ៏ទៃទៀត។ ប្រជាពលរដ្ឋមានការលំបាកក្នុងការបង្កើនសេដ្ឋកិច្ចគ្រួសារតាមរយៈការនេសាទ បើទោះបីមានការពង្រីកការជីកស្រះចិញ្ចឹមត្រី ជាលក្ខណៈគ្រួសារនិង មានការគាំទ្រពីគម្រោងអភិវឌ្ឍន៍នានាក្នុងខេត្តក៏ដោយក៏ធនធានជលផលនៅក្នុងខេត្ត ជួបការលំបាកដដែល។ ក្នុងនោះដែរប្រភពទឹក មិនសំខាន់សម្រាប់តែវិស័យកសិកម្មទេ តែក៏សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃផងដែរ។ ជាក់ស្តែងភាគរយគ្រួសារដែលប្រើប្រាស់ប្រភពទឹកស្អាត នៅរដូវប្រាំងមានចំនួនកើនឡើងពី៥២.១២% នៅឆ្នាំ២០០៩ និងឆ្នាំ២០១០មានចំនួន៦៣.៤៥%។ តែផ្ទុយទៅវិញភាគរយគ្រួសារ ដែលប្រើប្រាស់ប្រភពទឹកមិនស្អាតនៅរដូវប្រាំង មានចំនួនថយចុះគួរឲ្យកត់សម្គាល់ដែរ គឺពី៤៧.៨៨% នៅឆ្នាំ២០០៩ និងឆ្នាំ ២០១០ មានចំនួន៣៦.៥៥%។

ធនធានព្រៃឈើ មានតួនាទីយ៉ាងសំខាន់ចំពោះប្រជាពលរដ្ឋខេត្តកំពង់ស្ពឺ ដែលរស់នៅតាមទីជនបទ និងការបង្កើតប្រាក់ចំណូលសម្រាប់ដោះស្រាយជីវភាពរស់នៅ នោះក៏ព្រោះតែជនក្រីក្រនិងអ្នកអត់មានដីធ្លីដែលមានជម្រើសរកស៊ីចិញ្ចឹមជីវិតតិចតួចក៏អាចងាកទៅរកព្រៃឈើ ដើម្បីទ្រទ្រង់ការចិញ្ចឹមជីវិតរបស់គេដែរ។ កំណើនការកាប់បំផ្លាញព្រៃឈើ ការរេចរឹលនិងបញ្ហា ផ្សេងៗរារាំងលទ្ធភាពចូលទៅក្នុងព្រៃ ជំរុញឲ្យប្រជាពលរដ្ឋក្នុងភូមិធ្វើដំណើរឆ្ងាយៗ ទៅពីលំនៅដ្ឋាន

ដើម្បីប្រមូលអនុផលព្រៃឈើ។ ពេលដែលព្រៃឈើរេចរឹល ហើយលទ្ធភាពចូលទៅកាន់តំបន់ព្រៃកាន់តែតិច ដោយសារមូលហេតុជាច្រើននោះ ជីវភាពប្រជាពលរដ្ឋរស់នៅតាមទីជនបទក៏ជួបប្រទះការលំបាកច្រើនជាងមុន ដោយត្រូវចំណាយពេលពលកម្ម និងថវិកាច្រើនក្នុងការប្រថុយប្រថានស្វែងរកអនុផលព្រៃឈើ ដែលមានកាន់តែតិចទៅៗ។ អនុផលព្រៃឈើដែលអាចប្រមូលបានសម្រាប់ជីវភាព ប្រជាពលរដ្ឋរស់នៅតាមទីជនបទក្នុងខេត្ត មានដូចជា ផ្សិត ជ័រទឹក ជ័រចុង ផ្លែឈើ ស្លឹក ឬស មើម រុក្ខជាតិឱសថ អុស ធ្យូង កូនឈើសសរ ផ្តៅ ខ្លឹមច័ន្ទ ឈើដៃខ្លា ឬស្សីព្រិច ឬស្សី វល្លិ៍រមៀត សត្វស្លាប ថនិកសត្វ ត្រី សត្វល្អិត ទឹកឃ្មុំ។ល។

ការដកហូតផលអនុផលព្រៃឈើ ពីសហគមន៍ត្រូវមានការអនុញ្ញាត ពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងខណ្ឌរដ្ឋបាលព្រៃឈើដែរ ហើយក៏មានប្រភេទឈើកំរដែលសហគមន៍និងអាជ្ញាខេត្ត មិនអនុញ្ញាតឲ្យកាប់រំលំ មានដូចជា: បេង សុក្រម កកោះ ក្រញូង ឈើទាលស្រទ្បៅ ត្រសេក ត្រាច លំបោរ ផ្ចឹក ក្រឡាញ់ កំពីងរាជ នាងផ្លែត ដូងថែម ម៉ៃ សាក់ ស្វាយព្រៃ គគីរ រំដួល បង្គោ មៀនព្រៃ រ៉ូល និងព្យុង។

ក្រៅពីធនធានដែលប្រជាពលរដ្ឋបានអាស្រ័យផលខាងលើ ខេត្តកំពង់ស្ពឺនៅមានធនធានធម្មជាតិជាច្រើនទៀតទាំងលើដី ក្នុងដី ក្នុងទឹក លើទឹក និងមានខ្យល់អាកាសដ៏ល្អបរិសុទ្ធដែលអាចជាប្រភពសំខាន់ សម្រាប់ជួយជ្រោមជ្រែងការអភិវឌ្ឍផ្នែកទេសចរណ៍ ឧស្សាហកម្មវិស័យរ៉ែ និងថាមពល ប្រភពថាមពលវារីអគ្គីសនី កសិកម្ម វប្បធម៌ សិប្បកម្ម និងការវិនិយោគផ្សេងៗ ដូចជា ភ្នំ ព្រៃឈើ ទឹកជ្រោះ ជ្រលងភ្នំ ជ្រោះភ្នំ ដងអូរ ស្ទឹង បឹងធម្មជាតិ ស្ថានីយបូរាណវិទ្យា និងតំបន់វាលរាបធំៗ និង តំបន់មានជីជាតិខ្ពង់រាបជាច្រើន ហើយតំបន់ទាំងនេះបានក្លាយជាតំបន់មួយដែលអាជ្ញាធរខេត្ត និងអ្នកពាក់ព័ន្ធទាំងអស់កំពុងការពារអភិរក្សស្រាវជ្រាវ និងធ្វើការអភិវឌ្ឍ។

### ១.២.៣.៣ បរិស្ថាន

ចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលបានបង្កើតនូវគ្រោងឆ្អឹងសំខាន់ៗ ការរៀបចំការគ្រប់គ្រងនិងការប្រើប្រាស់នៃធនធានធម្មជាតិ និងបរិស្ថាន។ ក្រសួងបរិស្ថានសហការជាមួយអង្គការក្រៅរាជរដ្ឋាភិបាលគឺ ជាទីភ្នាក់ងារដ៏សំខាន់ក្នុងការទទួលខុសត្រូវចំពោះការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ខណៈដែលក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ ជាទីភ្នាក់ងារដែលទទួលខុសត្រូវចំពោះការការពារព្រៃឈើ។

ដោយឡែកខេត្តកំពង់ស្ពឺក៏ជាខេត្តមួយ ដែលមិនខុសពីបណ្តាខេត្តដ៏ទៃ ក្នុងព្រះរាជាណាចក្រកម្ពុជាទេ ដែលមានកាតព្វកិច្ចក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលដើម្បីធ្វើឲ្យបរិស្ថានស្អាត និងទប់ស្កាត់គ្រោះថ្នាក់ទាំងឡាយ ដែលបណ្តាលមកពីការបំពុលបរិស្ថាន។ មន្ទីរបរិស្ថាន

និងមន្ទីរកសិកម្មខេត្ត បានទទួលការធ្វើប្រតិភូកម្មអំណាចពីក្រសួងសាមីរបស់ខ្លួនតាមរយៈកម្មវិធីជាតិតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាយន្តការមួយដ៏សំខាន់សម្រាប់ការចូលរួមកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ការធ្វើអនាម័យ ការកែលម្អ និងការសំអាតលំនៅដ្ឋាន ហាក់មានភាពផុលផុសយ៉ាងខ្លាំងនៅតាំងពីឆ្នាំ២០០៥ ដោយប្រជាពលរដ្ឋបានយល់ដឹងពីកត្តាគ្រោះថ្នាក់ ដែលបង្កដោយការខ្វះអនាម័យ និងការមិនយល់ពីបរិស្ថានជំវិញផ្ទះ។ មន្ទីរបរិស្ថាន មន្ទីរសុខាភិបាល និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មានតួនាទីសំខាន់ ដោយបានបង្កើតយុទ្ធនាការអប់រំផ្សព្វផ្សាយអប់រំដោយផ្ទាល់ និងតាមរយៈ វេទិកានិងការប្រជុំផ្សេងៗ ឬការបើកវគ្គបណ្តុះបណ្តាលស្តីពីបរិស្ថាននិងការរស់នៅ។ ជាក់ស្តែង ភាគរយគ្រួសារដែលមានបង្គន់អនាម័យមានការកើនឡើងគួរឲ្យកត់សម្គាល់ គឺពី១១.៨១ % នៅឆ្នាំ ២០០៧ ១៤.៦២% ឆ្នាំ២០០៨, ១៧.៤៨% ឆ្នាំ២០០៩ និងឆ្នាំ២០១០ មានចំនួន២១.៤៨% ទូទាំងខេត្ត។

ការស្តាបនាសួនច្បារថ្មីៗ ការដាំកូនឈើលម្អ និងការរៀបចំប្រព័ន្ធលូទឹកស្អុយតាមទីផ្សារ និងទីប្រជុំជននានា តាំងពីថ្នាក់ខេត្តរហូតដល់ថ្នាក់ស្រុកក្រុង មានការកើនឡើងគួរឲ្យកត់សម្គាល់។ ជាក់ស្តែង ប្រជាពលរដ្ឋក្នុងក្រុងច្បារមន បានប្តូររបៀបរស់នៅរបស់ខ្លួនខ្លះ ដោយទុកពេលវេលាសម្រាប់ការហាត់ប្រាណ និងការកំសាន្តតាមសួនច្បារសាលាខេត្ត តាមដងស្ទឹងព្រៃត្នោតតែក៏មានកង្វល់មួយចំនួនទាក់ទងចំនួនប្រជាពលរដ្ឋ ដែលរងគ្រោះថ្នាក់ពីការបំពុលបរិស្ថាន បើទោះបីភាគរយទូទាំងខេត្ត បានថយចុះក៏ដោយក៏វានៅមានចំនួនច្រើនដែរ គឺពី២,២១៦គ្រួសារឆ្នាំ២០០៩មកនៅ១,៨១៩គ្រួសារ នៅឆ្នាំ២០១០ ហើយចំនួនគ្រួសារដែលទទួលយកសេវាប្រមូលសំរាមបានកើនឡើង ពី៨៥០គ្រួសារ ក្នុងឆ្នាំ២០០៩ដល់ ៩០៦គ្រួសារក្នុងឆ្នាំ២០១០ ដែលនេះជាចំនួននៅទាបនៅឡើយ។

ដោយឡែក គ្រោះថ្នាក់ដែលបណ្តាលមកពីការហុយធូលីថ្មភ្នំតាមតំបន់ ដែលមានរណ្តៅថ្ម ដូចជា ស្រុកភ្នំស្រួច ស្រុកគងពិសី ស្រុកសំរោងទង ស្រុកឧដុង្គ បានបណ្តាលឲ្យប្រជាពលរដ្ឋនៅតំបន់នោះមានការត្អូញត្អែរច្រើន ធូលីដែលធ្វើឲ្យបរិស្ថាននៅតំបន់នោះកាន់តែអាក្រក់ពិបាករស់នៅជាពិសេសបញ្ហាផ្លូវដង្ហើម ហើយដីកសិកម្មនៅនោះ នឹងរងការរឹងក្តាំងនាពេលអនាគតព្រោះតែធូលីផេះនៃថ្មភ្នំអាចធ្វើឲ្យដីស្រែទាប់លើទៅជារឹង និងគ្មានជីជាតិមិនអាចធ្វើការដាំដុះបាន ហើយក៏មិនទាន់មានស្ថាប័នណាបានសិក្សាឲ្យបានច្បាស់ ពីផលប៉ះពាល់នេះ នៅឡើយទេ។

រដូវប្រាំងកាន់តែមានរយៈពេលយូរទៅៗ ជាហេតុធ្វើឲ្យដីសម្រាប់ធ្វើការដាំដុះមានភាពប្រែប្រួលដែរ។ ដីដែលដែលធ្លាប់មានជីជាតិអាចនឹងបាត់បង់នៅកម្រិតឥទ្ធិពលរបស់ខ្លួន ជាហេតុបង្ខំឲ្យប្រជាកសិករត្រូវប្រើប្រាស់ជីគីមីកាន់តែច្រើនដែរ ព្រោះបើគាត់មិនប្រើ នោះផលដែលបានមកក៏មិនច្រើនដែរ តែនោះជាហេតុផលមួយដែលធ្វើឲ្យជីវិតសត្វ និង មនុស្សក៏មានភាពប្រែប្រួលដែរ ខណៈពេលដែលគាត់មិនមានពេលវេលាសម្រាប់ផលិតជីធម្មជាតិនោះ។ ចំនួនកសិករប្រើប្រាស់ជីគីមី បានកើនពី ៨៩,៦៩០គ្រួសារ នៅឆ្នាំ២០០៩ ដល់៩៥,៦៣៣គ្រួសារ នៅឆ្នាំ២០១០។

## ១.២.៤. ស្ថានភាពនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ

ខេត្តកំពង់ស្ពឺមានទីតាំងនៅភាគខាងលិចនៃរាជធានីភ្នំពេញ។ ខេត្តមានព្រំប្រទល់ខាងជើងជាប់និងខេត្តកំពង់ឆ្នាំង ខាងកើតជាប់និងខេត្តកណ្តាល ខាងលិចជាប់នឹងខេត្តព្រះសីហនុ ខាងត្បូងជាប់នឹងខេត្តកំពត និងខេត្តតាកែវ។ បើយើងធ្វើការវិភាគទៅលើឋានលេខាឬវិទ្យាសាស្ត្រ ខាងផែនទីវិញខេត្ត ត្រូវបានចែកចេញជាពីរតំបន់ គឺតំបន់វាលទំនាប ស្ថិតនៅផ្នែកខាងកើត នៃទីរួមខេត្ត និងតំបន់ខ្ពង់រាបស្ថិតនៅផ្នែកខាងលិចនៃទីរួមខេត្តដែលគ្របដណ្តប់ដោយព្រៃឈើ ព្រមទាំងមានជួរភ្នំក្រវ៉ាញលាតសន្ធឹងនៅទិសខាងជើងនៃទីរួមខេត្ត ហើយខេត្តកំពង់ស្ពឺ គឺត្រូវបានគេចាត់ទុកថាជាខេត្តដែលស្ថិតក្នុងតំបន់ជនបទ។

ពាក់ព័ន្ធទៅនិងស្ថានភាព នៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ យើងសង្កេតឃើញថា ខេត្តកំពង់ស្ពឺបាននិងកំពុងទទួលរងបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ និងការប្រែប្រួលដែលបង្កឡើងដោយគ្រោះមហន្តរាយសំខាន់ៗ ដូចជាការបំផ្លិចផ្លាញដោយសារខ្យល់ព្យុះ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការប្រែប្រួលអាកាសធាតុ ដូចជាភាពរាំងស្ងួត សីតុណ្ហាភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនគ្រប់គ្រាន់ ភ្លៀងធ្លាក់ខុសរដូវ និងគ្រោះទឹកជំនន់ជាដើម។ល។

ទន្ទឹមនឹងវឌ្ឍនភាពខាងលើ បញ្ហាប្រឈមមួយចំនួនត្រូវបន្តដោះស្រាយរួមមាន៖

- ការគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ថ្វីត្បិតតែប្រទេសកម្ពុជា ជាប្រទេសមួយដែលទើបតែងើបផុតពីសង្គ្រាមស៊ីវិល និងទទួលបាននូវសុខសន្តិភាពពេញលេញក៏ដោយ ប៉ុន្តែ ផលវិបត្តិនៃសង្គ្រាមបានបន្សល់ទុកយុទ្ធភ័ណ្ឌ មិនទាន់ផ្ទុះជាច្រើនដែលបង្កឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋ។ ជាក់ស្តែងក្នុងខេត្តកំពង់ស្ពឺ មានជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះសរុបចំនួន៤៣៤នាក់ ដែលនៅក្នុងនោះគ្រោះថ្នាក់ក្នុងឆ្នាំ២០០៧ មានចំនួន ៣៨៧នាក់ ឆ្នាំ២០០៨ មានចំនួន៨នាក់ និងឆ្នាំ២០១០មានចំនួន៣៩នាក់ កត្តាគ្រោះទាំងអស់នេះ ហើយដែលជាផ្នែកមួយក្នុងការបង្កើននូវវិបត្តិក្នុងសង្គមក៏ដូចជា ការបង្កើននូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្នុងខេត្តកំពង់ស្ពឺ

ទាំងមូលដែរ។

- ការរងគ្រោះដោយសារគ្រោះធម្មជាតិ មានប្រជាពលរដ្ឋមួយចំនួនក្នុងខេត្តកំពង់ស្ពឺ ត្រូវបានទទួលរងនូវវិបត្តិ នៃគ្រោះធម្មជាតិដូចជា ភាពរាំងស្ងួតដែលជាមូលហេតុធ្វើឲ្យគ្រួសារទាំងនោះ មិនអាចទទួលបានទិន្នផលស្រូវប្រចាំឆ្នាំរបស់ពួកគេ។

បើផ្អែកតាមទិន្នន័យមូលដ្ឋានភូមិឃុំ(CDB)បានបង្ហាញថា មានគ្រួសារសរុបចំនួន១០,៣៥៦ គ្រួសារទទួលរងនូវភាពរាំងស្ងួតដែលនៅ ក្នុងនោះគ្រួសារទទួលរងគ្រោះ ក្នុងឆ្នាំ២០០៧ មានចំនួន ៩,២៣៧គ្រួសារឆ្នាំ២០០៨ មានចំនួន៩៩២គ្រួសារឆ្នាំ២០០៩មានចំនួន ៣៣គ្រួសារ និងឆ្នាំ២០១០ មានចំនួន៩៤គ្រួសារ។ បើយើងពិនិត្យមើលទិន្នន័យ នៃភាពគ្រោះថ្នាក់ដោយសារភាពរាំងស្ងួតនៅឆ្នាំ២០១០ដែលមានចំនួន៩៤គ្រួសារនោះបានបង្ហាញថា ស្រុកច្បារមន មានចំនួន៤គ្រួសារ ស្រុកគងពិសីមានចំនួន៤គ្រួសារ ស្រុកភ្នំស្រួចមានចំនួន២៥គ្រួសារ ស្រុកឧដុង្គមានចំនួន២៧ គ្រួសារ និងស្រុកសំរោងទង មានចំនួន៣៤គ្រួសារ ផ្អែកតាមទិន្នន័យនេះបញ្ជាក់ថា មានស្រុកចំនួនបីក្នុងចំណោមស្រុកទាំងប្រាំខាងលើទទួល រងគ្រោះថ្នាក់ដោយសារភាពរាំងស្ងួតខ្លាំង ដែលជាចំនុចមួយត្រូវបានយកមកពិចារណា សម្រាប់ស្វែងរកវិធានការណ៍ដោះស្រាយ ដើម្បីកាត់បន្ថយនូវអត្រាគ្រោះថ្នាក់នាពេលអនាគត។

## ១.២.៥. ស្ថានភាព នៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

សកម្មនានានៃការងារគ្រប់គ្រង់រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ មានភាពប្រសើរឡើងគួរឲ្យកត់សម្គាល់ ក្រោយពីមានកំណែទម្រង់រដ្ឋបាលសាធារណៈ និងការដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការគាំទ្រដល់មូលដ្ឋានផ្ទាល់ តាមរយៈការពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍ពង្រឹង និងពង្រីកលិទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។ ក្នុងនោះដែរ បទល្មើសផ្សេងៗមានការថយចុះផងដែរ បើយើងប្រៀបធៀបមុនពេលអនុវត្តនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព។ ខាងក្រោមនេះ ជាស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្នទាក់ទងនឹងការងារគ្រប់គ្រង់រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់របស់ខេត្តដែលកំពុងជួប ប្រទះនាពេលកន្លងមកដែលទាមទារឲ្យមានការដោះស្រាយបន្ថែម៖

### ១.២.៥.១ ការងារអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អគឺ ជាស្នូលនៃការរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងគោលដៅគៀងគរនូវការចូលរួមរបស់សាធារណជន ប្រកបដោយសមធម៌ និងភាពត្រឹមត្រូវក្នុងគ្រប់បញ្ហាតាមបែបប្រជាធិបតេយ្យនិងគ្មានអំពើហឹង្សា ធ្វើឲ្យវឌ្ឍនភាពផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចគួរឲ្យមានមោទនភាព តាមរយៈសមិទ្ធិផលទាំងឡាយបានឆ្លុះបញ្ចាំងពីកំណែទម្រង់រដ្ឋបាល

សាធារណៈស្តែងតាមរយៈលទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ទី២ ត្រូវបានបង្កើតឡើងដោយផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្រុមប្រឹក្សា ទាំង៨៧ឃុំ-សង្កាត់ ដែលមានសមាជិក៦០៩នាក់ មានទាំងតួនាទីមួយចំនួនផង ត្រូវបានបណ្តុះបណ្តាលថៃបំប៉នឲ្យបំពេញនូវតួនាទីភារកិច្ច សិទ្ធិអំណាចតាមច្បាប់ និងគោលការណ៍នានាជាធរមាន បានរួចចំណែកដល់កិច្ចអភិវឌ្ឍ សេដ្ឋកិច្ច សង្គមតាមភូមិ-ឃុំ-សង្កាត់ និងការលើកស្ទួយសេវាកម្មនានាជូនប្រជាពលរដ្ឋឲ្យកាន់តែមានប្រសិទ្ធិភាព រួមចំណែកតាត់ បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

រដ្ឋបាលខេត្តតែងតែខិតខំពង្រឹងការងារអភិបាលជាប្រចាំដើម្បីឆ្លើយតបទៅ នឹងតម្រូវការរបស់មូលដ្ឋាន និងប្រជាពលរដ្ឋ។ ក្រោយពេលមានច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់បោះឆ្នោតពាក់ព័ន្ធ និងរដ្ឋបាលទាំងនេះក្រុម ប្រឹក្សា ខេត្តដែលមានសមាជិក១៧នាក់ (ស្រី២នាក់) គណៈអភិបាលខេត្ត៦នាក់ (ស្រី១នាក់) និងមន្ត្រីចំណុះសាលាខេត្តចំនួន១១៥នាក់(ស្រី៣៣នាក់) បានចាប់ផ្តើមរៀនសូត្រពីតួនាទីភារកិច្ច សិទ្ធិអំណាច និងរបៀបរបបធ្វើការងារ បាននាំឲ្យការងារអភិបាលកិច្ចចូលក្នុងរបត់មួយថ្មីទៀត។ ក្រោយពីបានបង្កើតគណៈកម្មាធិការនានា ជាជំនួយការរដ្ឋបាលខេត្តបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលនិងក្លាយជាឧបករណ៍ដ៏សំខាន់សម្រាប់ធ្វើជាត្រីវិស័យក្នុងដំណើរលើកកម្ពស់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ខេត្តឲ្យមានការរីកចម្រើន។

ទន្ទឹមនឹងវឌ្ឍនភាព ដែលទទួលបាន បញ្ហាប្រឈមមួយចំនួនដែលទាមទារឲ្យមានការដោះស្រាយឲ្យបានគឺ:

- សមត្ថភាព គុណភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានកម្រិតស្របពេលដែលតួនាទីភារកិច្ចមានច្រើនរាប់មិនអស់
- ការធ្វើវិជ្ឈការ និងវិសហមជ្ឈការរបស់វិស័យជំនាញនានា ពុំទាន់ស៊ីសង្វាក់និងស្របគ្នាជាមួយរដ្ឋបាលស្រុក ក្រុង ឃុំ សង្កាត់
- អន្តរការនានាដែលជាជំនួយការឲ្យក្រុមប្រឹក្សាខេត្ត ថ្វីត្បិតតែជាមនុស្សដែលមានគ្រប់ពីរដ្ឋបាលមុន តែបើពិនិត្យនូវតួនាទី ភារកិច្ច សិទ្ធិអំណាច របៀបរបបធ្វើការមានលក្ខណៈស៊ីជម្រៅ ស្របពេលដែលសមត្ថភាពរបស់មន្ត្រីនៅមានកម្រិត និងខ្វះបទពិសោធន៍។
- បញ្ហាធនធានថវិកា សម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់នៅរដ្ឋបាលខេត្ត ពុំទាន់មានទន្ទឹមនឹងថវិកាមូលនិធិរបស់ឃុំសង្កាត់ ក៏មិនច្រើនពុំទាន់ឆ្លើយទៅនឹងសំណូមពរតម្រូវ

ការរបស់ប្រជាពលរដ្ឋដ៏ច្រើនស្អេកស្កះ

- ការងារបណ្ដុះបណ្ដាល និងហ្វឹកហាត់នៅរដ្ឋបាល គឺជាការចាំបាច់របស់រដ្ឋបាល និងឃុំ។
- គុណភាព សមត្ថភាពរបស់មន្ត្រីរាជការគ្រប់ផ្នែក-ថ្នាក់ ពុំទាន់ឆ្លើយតបតាមតម្រូវការការងារនាពេលបច្ចុប្បន្ន
- គោលការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានចាត់តាំងផ្សព្វផ្សាយជូនមន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋយ៉ាងទូលំទូលាយ។ ក្នុងជំហានដំបូងនេះ មន្ត្រីពាក់ព័ន្ធចំនួនជាង ១០០០នាក់ ត្រូវបានធ្វើសេចក្ដីប្រកាសពីទ្រព្យសម្បត្តិរបស់ខ្លួនស្របតាមគោលការណ៍កំណត់។ មន្ត្រីរាជការ និងប្រជាពលរដ្ឋបានស្វាគមន៍អបអរសាទរ និងច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

### ១.២.៥.២ ការគ្រប់គ្រងដែនដី

ក្នុងខេត្តបានបែងចែកជា០៨ស្រុក ក្រុង មានភូមិចំនួន ១,៣៧៣ ក្នុងនោះភូមិមានក្របខ័ណ្ឌចំនួន១,៣០៨ភូមិ ដែលមានផ្ទៃដីសរុប៦,៩៦៩.៧១៩ គីឡូម៉ែត្រការ៉េ។

ចំនួនសមាជិកក្រុមប្រឹកក្សាឃុំ សង្កាត់ ដែលជាប់ឆ្នោតអាណត្តិទី២ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ មានចំនួន៦០៩នាក់ (កើនជាងអាណត្តិទី១ចំនួន០៤អាសនៈ) ក្នុងនោះស្ត្រី៥៦នាក់ មកពីគណបក្សប្រជាពលរដ្ឋកម្ពុជាចំនួន៤១៥នាក់ មកពីគណបក្សសមរង្ស៊ីចំនួន ១៣៦នាក់ គណបក្សនរោត្តរណរិទ្ធិចំនួន៣៦នាក់ និងគណបក្សហ៊្វុនស៊ិនប៉ិច១២នាក់ ក្នុងនោះសមាជិកជាប់ឆ្នោតជាថ្មីមានចំនួន២០៣នាក់ ស្មើនឹង៣៣.៣៣ % ។

សាលាឃុំ សង្កាត់ចំនួន៤៣កន្លែង ត្រូវបានសាងសង់រួចជាស្ថាពរ បំពាក់សម្ភារៈផ្សេងៗដាក់ឲ្យដំណើរការរួចហើយ ដោយឡែកការងារសាងសង់សាលាឃុំសង្កាត់ ដែលនៅសល់ចំនួន ៤៩ ទៀតមិនទាន់ដំណើរការដោយត្រូវបានផ្អាកជំនួយ ។

ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ដែលជាប់ឆ្នោតអាណត្តិទី១ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០០៩មានចំនួន១៣៦នាក់ ក្នុងនោះស្ត្រី១៨នាក់។ សាលាក្រុងស្រុកទាំង៨ ត្រូវបានសាងសង់ទាំងកន្លែងធ្វើការ និងសាលប្រជុំរួចជាស្ថាពរ។ ចំនួនសមាជិកក្រុមប្រឹក្សាខេត្ត ដែលជាប់ឆ្នោតអាណត្តិទី១ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ មានចំនួន១៧នាក់ ក្នុងនោះស្ត្រី២នាក់។

ចំពោះការកំណត់ព្រំប្រទល់ស្រុក ក្រុង ឃុំ សង្កាត់ និងភូមិ បានរៀបចំដោះស្រាយបានល្អស្របពេលដែលខេត្តបានចុះបញ្ជីក្បាលដីជាលក្ខណៈប្រព័ន្ធ ឯបញ្ហាព្រំប្រទល់ជាមួយខេត្តផ្សេងៗក៏កំពុងមានបញ្ហាធ្ងន់ធ្ងរដែរ ដោយឡែកបញ្ហាព្រំប្រទល់ជាមួយខេត្តតាកែវ ខេត្តព្រះសីហនុ និងខេត្តកំពត ត្រូវមានការសម្របសម្រួលកំណត់លើផែនទីឲ្យស្របតាមទិដ្ឋភាពជាក់ស្ដែង ដែលបាន

ពិភាក្សាឯកភាពគ្នារួចហើយ ។

បញ្ហាប្រឈមដែលត្រូវដោះស្រាយគឺ ការរៀបចំប្លង់គោលសម្រាប់គ្រប់គ្រងដែនដី ឲ្យបានច្បាស់លាស់។

### **១.២.៥.៣ ការងារគ្រប់គ្រងស្ថិតិ**

ការងារគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ជាបញ្ហាចាំបាច់ក្នុងការគ្រប់គ្រងរដ្ឋបាល ដែលកន្លងមករដ្ឋបាលស្រុក ក្រុង ឃុំ សង្កាត់ និង សមត្ថភាពជំនាញពាក់ព័ន្ធតែងតែអនុវត្តជាប្រចាំ ខែ ត្រីមាស ឆមាសនិងឆ្នាំ។ សកម្មភាពផ្លាស់ចេញផ្លាស់ចូលការស្នាក់នៅ និងចំណាកស្រុកត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ឲ្យរដ្ឋបាលស្រុក ក្រុង ឃុំ សង្កាត់ ជំរុញការអភិវឌ្ឍខាងធនធានមនុស្សស្របតាមតំណាក់កាលនីមួយៗ។ តាមការជំរឿនប្រជាពលរដ្ឋឆ្នាំ២០០៨ ដោយមានការចូលរួមរបស់មន្ត្រីរាជការ និងប្រជាពលរដ្ឋក្នុងខេត្ត បានបង្ហាញនូវអត្រាស្រករអាយុតាមប្រភេទនីមួយៗ យ៉ាងច្បាស់លាស់មកដល់ឆ្នាំ២០១០នេះ ក្នុងខេត្តមានចំនួនប្រជាពលរដ្ឋ៧៦៥,៣០២ នាក់ ចំនួនគ្រួសារដែលរស់នៅ លើដីសាធារណៈមានចំនួន៥០៦គ្រួសារ ជនអនាថាមានចំនួន ២៦៦នាក់។

បន្ទាប់ពីការចុះអត្រានុកូលដ្ឋាននៅក្នុងយុទ្ធនាការពីឆ្នាំ ២០០៥ ដល់ ២០១០មក យើងមានមូលដ្ឋានសម្រាប់ជំរុញកែលម្អកិច្ចការនេះ ឲ្យបានល្អស្របតាមគោលការណ៍ច្បាប់ចាប់ពីឆ្នាំ២០០៨ ដល់២០១០ ទារកដែលមិនបានចុះបញ្ជីកំណើតមានចំនួន២៩.៧៦ %នៃទារកសរុប។

ប៉ុន្តែបញ្ហាប្រឈមដែលនៅសេសសល់រួមមានៈ

- កិច្ចការចុះអត្រានុកូលដ្ឋាន ក្នុងពេលយុទ្ធនាការមានការខុសឆ្គងជាច្រើនដូចជាកំហុសឆ្គងខាងអក្ខរាវុទ្ធ ថ្ងៃ ខែ ឆ្នាំកំណើត និងទិន្នន័យមួយចំនួនទៀតដែលមកដល់ពេលនេះ យើងពុំទាន់បានកែតម្រូវ និងមិនអាចធ្វើការកែតម្រូវបាន
- សារៈសំខាន់នៃការងារអត្រានុកូលដ្ឋាន ពុំទាន់បានយល់ជ្រួតជ្រាបគ្រប់ស្រទាប់ប្រជាពលរដ្ឋនៅឡើយ។ នៅមានក្មេង១.១៦៤នាក់ ត្រូវជា២៤.៦៩% ដែលពុំទាន់បានចុះបញ្ជីកំណើតក្នុងចន្លោះឆ្នាំ២០០៨-២០១០
- ការបំពាក់បំប៉ន់ ការបណ្ដុះបណ្ដាពង្រឹងមន្ត្រីអត្រានុកូលដ្ឋាននៅតែជាការចាំបាច់។

### **១.២.៥.៤ រដ្ឋបាល ការងារសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ**

ចំណុចគួរឲ្យកត់សម្គាល់សភាពការណ៍ឆ្នាំ២០១០ បទល្មើសឧក្រិដ្ឋកើតមានចំនួន១៩/២៥ ករណី ថយចុះ០៦ករណី ស្មើនឹង ២៤% ដែលជាអំពើឃាតកម្មបទល្មើសមានស្ថានទម្ងន់(ប្លន់) មានចំនួន៧ករណីប្រហែលគ្នាឆ្នាំមុន បទល្មើសរំលោភសេពសន្ថវៈក៏មានការថយចុះ៥ករណី គឺ២៣/២៨

ករណីស្មើនឹង១៧.៨៥% បទល្មើសមជ្ឈឹមមាន ចំនួន៧៦/៦៣ករណី កើនឡើង១៣ករណី ស្មើនឹង ១៧.១០% ។

កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសបានចំនួន ១៥២ករណី ឃាត់ខ្លួនជនល្មើសបាន ២១៧នាក់ បទឧក្រិដ្ឋ ២៤ករណី ឃាត់ខ្លួនជនល្មើស ៣៧នាក់ និងបទល្មើសមជ្ឈឹម១១៨ករណី ឃាតខ្លួនជនល្មើស ១៨០នាក់ បង្ក្រាបជាក់ស្តែង៧៨ករណីស្មើនឹង ៨២.១០% ធ្វើការគ្រប់គ្រង ចំពោះក្មេងទំនើងមានចំនួន ១៥ក្រុម កំណត់មុខសញ្ញាជនល្មើស ៥៨នាក់ ។ ការងារប្រឆាំងការជួញដូរ និងការពារអនីតិជនបង្ក្រាបបាន ១៥ករណី ឃាត់ខ្លួនជនល្មើស១៥នាក់ ស្មើនឹង ៦៥.២១% ប្រទូស្តកេរ្តិ៍ខ្មាស់២ករណីឃាត់ខ្លួនជនល្មើស២នាក់ប្រើអំពើហឹង្សាក្នុងគ្រួសារ១១ករណី ឃាត់ខ្លួន១១នាក់។ បទល្មើសគ្រឿងញៀនបង្ក្រាបបាន ៨ករណីឃាត់ខ្លួន បានជនល្មើស១០នាក់ ស្រី៤នាក់ រឹបអូសថ្នាំញៀនប្រភេទយ៉ាម៉ាចំនួន ១៦៣គ្រាប់ និងម្សៅទឹកកកចំនួន ៣៤កញ្ចប់តូច ។

ការងារចរាចរណ៍ផ្លូវគោក កើតមានចំនួន ៩៤/៧៦ កើនឡើង ១៨លើកស្មើនឹង២៣.៦៨% មូលហេតុគ្រោះថ្នាក់ចរាចរណ៍ កើនឡើងបណ្តាលមកពីការបើកបរហួសល្បឿនកំណត់ពី ៣៤% ការបើកបរឆ្លងកាត់ផ្លូវធ្វេសប្រហែសកើនឡើង ៣៣% ការបើកបរមានជាតិស្រវឹងថយចុះ ២៧% និងវ៉ាប្រជែងក្នុងស្ថានភាពគ្រោះថ្នាក់ថយចុះ៥០% ។

ការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពក្នុងការចូលរួមចំណែកថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម និងបានចាត់តាំងចលនាប្រជាការពារនៅទូទាំងខេត្ត មានចំនួន ៦,៦៤៣ក្រុមមនុស្សរួម៦៦,១២៦នាក់។

បញ្ហាប្រឈមត្រូវបន្តការយកចិត្តទុកដាក់ដោះស្រាយរួមមាន៖

- ការអប់រំលើកទឹកចិត្តជូនកម្លាំងទាំង៣ នៅតែជាការចាំបាច់ ពិសេសលើមុខជំនាញ និងសីលធម៌សង្គម
- ការគាំទ្រលើកទឹកចិត្តដល់កម្លាំងប្រជាការពារត្រូវតែមាន ដើម្បីជាស្នូលក្នុងការបំផុសចលនាឲ្យប្រជាពលរដ្ឋចូលរួមក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព
- ការផ្សព្វផ្សាយអប់រំបំផុសចលនាប្រជាពលរដ្ឋទាំងមូលដ្ឋានឲ្យចូលរួមក្នុងកិច្ចការពារសុវត្ថិភាពភូមិ-ឃុំ ត្រូវធ្វើឲ្យបានសកម្មថែមទៀត
- វិធានការគ្រប់គ្រងមុខសញ្ញាធ្លាប់ប្រព្រឹត្តិបទល្មើស និងការបង្ការទប់ស្កាត់ កុំឲ្យមានមុខសញ្ញាថ្មី គឺជាប្រការចាំបាច់តម្រូវឲ្យអ្នកពាក់ព័ន្ធទាំងអស់ខិតខំធ្វើបន្តទៀត
- វិធានការគ្រប់គ្រងមុខសញ្ញាធ្លាប់ប្រព្រឹត្តបទល្មើសចាស់ និងបង្កាកុំឲ្យមានមុខសញ្ញាថ្មី គឺជាប្រការចាំបាច់តម្រូវឲ្យអ្នកពាក់ព័ន្ធខិតខំធ្វើបន្តទៀត ។

# ជំពូកទី ២

## ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត

# ជំពូកទី២

## ២. ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត

### ២.១ ចក្ខុវិស័យអភិវឌ្ឍន៍

ដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ខេត្តកំពង់ស្ពឺត្រូវមានចក្ខុវិស័យអភិវឌ្ឍន៍រួមមួយរបស់ខ្លួនឲ្យបានច្បាស់លាស់គឺ៖

" លើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋឲ្យធូរធារប្រកបដោយសមធម៌ និងសោភ័ណភាពស្រស់បំព្រង ដើម្បីជំរុញឲ្យមានសន្តិសុខស្បៀង សុខុមាលភាព សមភាពយេនឌ័រ ចំណេះដឹង និងសន្តិសុខសណ្តាប់សាធារណៈ តាមរយៈកំណែទម្រង់លើគ្រប់វិស័យ ដោយប្រកាន់ខ្ជាប់ នូវគោលការណ៍ប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ឆ្ពោះទៅកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងតម្លាភាព។ "។

### ២.២ គោលដៅអភិវឌ្ឍន៍

ដើម្បីសម្រេចឲ្យបានចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួន ខេត្តក៏ត្រូវបង្កើតនូវគោលដៅអភិវឌ្ឍន៍តាមផ្នែកសំខាន់ចំនួន៤ដូចខាងខាងក្រោម៖

#### ២.២.១ គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច បានកំណត់ឡើងក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចឆ្ពោះទៅកាន់វឌ្ឍនភាព ដោយផ្អែកលើមូលដ្ឋានបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងខេត្ត តាមវិស័យនីមួយៗ តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម ការធ្វើពិពិធកម្មកសិកម្ម ការកែឆ្នៃកសិផល ការលើកកម្ពស់កំណែទម្រង់ដីធ្លី ការពង្រីក និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្តជនបទ ការកសាងផ្លូវថ្នល់ ការរៀបចំប្រព័ន្ធធារាសាស្ត្រ ការតបណ្តាញអគ្គីសនី ការតបណ្តាញទឹកស្អាត ការអភិវឌ្ឍន៍ជនបទ ព្រមទាំងការផ្តល់សេវាឥណទាន និងការពង្រីកទីផ្សារសេដ្ឋកិច្ច..។ល។ គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចត្រូវបានកំណត់តាមវិស័យ ដូចខាងក្រោម៖

##### ២.២.១.១ គោលដៅអភិវឌ្ឍន៍វិស័យកសិកម្ម

ការលើកកម្ពស់វិស័យកសិកម្ម គឺជាបញ្ហាចំបងបំផុត ដែលខេត្តត្រូវយកចិត្តទុកដាក់។ ទិន្នផលស្រូវជាមធ្យមក្នុងឆ្នាំ២០១០ មានចំនួន២.៦០តោន/ហិចតា ជាគោលដៅនៅឆ្នាំ២០១៥ ត្រូវសម្រេចឲ្យបាន៣.១០តោន/ហិចតា តាមរយៈការបង្កើនការយកចិត្តទុកដាក់ ក្នុងការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម លើកកម្ពស់ចំណេះដឹង និងចំណេះធ្វើរបស់កសិករ ការដាំដុះ

ការកែលម្អ ការគ្រប់គ្រងទឹក និងការផ្លាស់ប្តូរទៅរកប្រពលវប្បកម្មកសិកម្ម ដោយយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពផលិតលើផ្ទៃដី និងរដូវដាំដុះលើដីដែលមានស្រាប់ ការបង្កើនផលិតកម្មដំណាំបន្លែ ការបង្កើនផលិតកម្មសត្វ ដើម្បីធានាការអូសទាញ និងបម្រើម្ហូបអាហារ។ ដើម្បីលើកកម្ពស់វិស័យកសិកម្មទូទាំងខេត្ត សំដៅជំរុញទិន្នផលស្រូវជាមធ្យមឲ្យបាន៣.១០តោន/ហ.តក្នុងឆ្នាំ២០១៥ ខេត្តបានកំណត់នូវគោលដៅអភិវឌ្ឍន៍វិស័យកសិកម្ម រយៈពេល៥ឆ្នាំរបស់ខ្លួន ដូចខាងក្រោម៖

“នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងមានជីវភាពល្អប្រសើរ មានចំណូលប្រចាំឆ្នាំកើនឡើង តាមរយៈលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម ”។

### ២.២.១.២ គោលដៅក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

ការកសាងប្រព័ន្ធធារាសាស្ត្រ ការស្តារអាងស្តុកទឹក ការស្តារប្រឡាយចែកចាយទឹកខ្នាតតូចពីប្រឡាយមេទំនប់ទឹក ទំនប់បង្ហៀរ ជាបញ្ហាសំខាន់ដែលខេត្តត្រូវយកចិត្តទុកដាក់បំផុត។ ការរៀបចំលទ្ធភាព នៃសក្តានុពលពីប្រព័ន្ធធារាសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាទឹក វាមិនត្រឹមតែផ្តល់សារៈសំខាន់ចំពោះវិស័យកសិកម្ម តែមួយមុខប៉ុណ្ណោះទេ តែវាក៏បានជួយផ្តល់ទឹកស្អាត សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ នៅតំបន់ជនបទ និងទីក្រុងផងដែរ។ វិធានការជួសជុល ថែទាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនេះ នឹងធ្វើឲ្យខេត្តទទួលបាននូវការរីកចម្រើនយ៉ាងឆាប់រហ័សនាពេល៥ឆ្នាំខាងមុខ។

ដើម្បីសម្រេចនូវគោលដៅ ក្នុងការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងទទួលបានការសាងសង់ និងជួសជុលទំនប់ទឹក ការស្តារប្រឡាយស្រោចស្រព ប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោពស្រពខ្នាតតូចដើម្បីប្រើប្រាស់ប្រចាំថ្ងៃ និងពង្រីកផ្ទៃដីស្រោចស្រពដាំដុះ ”។

### ២.២.១.៣ គោលដៅអភិវឌ្ឍន៍វិស័យគមនាគមន៍

ផ្លូវជាមធ្យោបាយដ៏សំខាន់បំផុត ស្របតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលបានកំណត់ថា បណ្តាញគមនាគមន៍គឺជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច។ ក្នុងគោលដៅនេះ ខេត្តមានគោលដៅពង្រឹង និងពង្រីកការតភ្ជាប់បណ្តាញគមនាគមន៍ ឲ្យក្លាយជាសរីរាង្គសេដ្ឋកិច្ចមួយនៅក្នុងខេត្ត ដោយកៀគររកថវិកាសម្រាប់ការកសាង ជួសជុល និងថែទាំផ្លូវគមនាគមន៍គិតទាំងផ្លូវឯកជនសំខាន់ៗ ឲ្យមានចីរភាពក្នុងការធ្វើចរាចរណ៍ទៅមករបស់ប្រជាពលរដ្ឋពីភូមិឃុំមួយទៅភូមិឃុំមួយ និងការទាក់ទងជាមួយមជ្ឈដ្ឋានខាងក្រៅ។ ការជំរុញឲ្យមានការស្តាបនា និងជួសជុល

ឡើងវិញ នូវផ្លូវលំក្រាលគ្រួសក្រហមទាំងអស់ ដែលមានស្រាប់ ឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ពិតជាកាតាព្វកិច្ចមួយទៀតដែលខេត្តត្រូវយលចិត្តទុកដាក់ផងដែរ។

ដើម្បីទទួលនូវគោលដៅអភិវឌ្ឍន៍ លើវិស័យគមនាគមន៍ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

**“** នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងមានផ្លូវល្អប្រើប្រាស់កាន់តែប្រសើរ និងងាយស្រួលធ្វើដំណើរទៅមក ទាំងនៅជនបទ និងទីប្រជុំជន **”**។

### ២.២.១.៤ គោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

ការជំរុញលើកទឹកចិត្តដល់ម្ចាស់សហគ្រាសធុនធំ តូច និងមធ្យម សិប្បករគ្រប់ប្រភេទក្នុងការខិតខំសម្របសម្រួលលើការចុះបញ្ជី ការគៀងគរការផ្ដល់ហិរញ្ញប្បទាន និងការពង្រីកសេវាកម្មគាំទ្រផ្សេងៗ ជាកិច្ចការមួយដ៏មានសារៈសំខាន់ចំពោះអាជ្ញាធរខេត្ត ដើម្បីជំរុញឲ្យម្ចាស់អាជីវកម្មធនធានរ៉ែ ជាពិសេសរ៉ែខ្សាច់ និងថ្មដែលជាសក្ដានុពលដ៏ចាំបាច់ក្នុងការមកចុះបញ្ជីការ និងបង់ពន្ធសួយសាររ៉ែ ឲ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល។ វិធានការគ្រប់គ្រងប្រើប្រាស់ឲ្យមានតម្លៃសេដ្ឋកិច្ចសម្រាប់កិច្ច អភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន និងលើកទឹកចិត្តឲ្យមានសេវាករផ្គត់ផ្គង់អគ្គីសនីទាំងអស់ ដោយពង្រីកការតបណ្ដាញចែកចាយផ្គត់ផ្គង់អគ្គីសនី ឲ្យបានដល់ស្រុក និងក្រុងទាំង៨។

ដើម្បីចូលរួមលើកស្ទួយការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រ៉ែ និងថាមពលនេះ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

**“** នៅឆ្នាំ២០១៥ វិស័យឧស្សហកម្ម រ៉ែ និងថាមពល នឹងទទួលបានការលើកកម្ពស់តាមរយៈការពង្រឹងលើ អាជីវកម្មខ្សាច់ដោយអនុវត្តតាមបទដ្ឋានបច្ចេកទេស និងការតបណ្ដាញអគ្គីសនីសម្រាប់ប្រើប្រាស់គ្រប់ៗផ្ទះ តាមតំបន់ដែលមានសក្ដានុពល **”**។

### ២.២.១.៥ គោលដៅអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ជនបទ

ការពង្រឹងការថែទាំ ជួសជុលផ្លូវលំ និងចងក្រងក្រុមប្រជាពលរដ្ឋជាគណៈកម្មការថែទាំ និងជួសជុលគ្រប់ប្រភេទដែលមានស្រាប់ក្នុងគោលដៅដើម្បីអភិវឌ្ឍវិស័យអភិវឌ្ឍន៍ជនបទ ជាកិច្ចចំបងដែលខេត្តទាំងមូលត្រូវយកចិត្តទុកដាក់។ ការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់នៅតាមជនបទដូចជា អណ្ដូង ស្នប់ អណ្ដូងចម្រុះ ស្រះទឹកស្អាត ពាងយក្ស នៅតាមសាលារៀន និងតាមសហគមន៍ ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងនៅជិតផ្ទះ ព្រមទាំងការអនុវត្តសហគមន៍ដឹកនាំអនាម័យទាំងស្រុង ការប្រើប្រាស់បង្គន់អានាម័យជាអ្វីដែលប្រជាពលរដ្ឋកំពុងមានតម្រូវការ និងទាមទារឲ្យមានការដោះស្រាយជាបន្ទាន់។

ដើម្បីបំពេញនូវតម្រូវការ ក្នុងការចូលរួមអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ជនបទនេះ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងមានទឹកស្អាត និងផ្លូវលំជនបទប្រើប្រាស់ និងរស់នៅប្រកបដោយសុខុមាលភាព ”។

### ២.២.១.៦ គោលដៅអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម

ការគៀងគរពាណិជ្ជករឲ្យចូលរួមក្នុងការវិនិយោគវិស័យកសិកម្ម ដូចជាការវិនិយោគម៉ាស៊ីនកិនស្រូវ និងពង្រីកផលិតផលកសិកម្ម ដើម្បីអាចនាំចេញអង្គឲ្យបានច្រើនទៅក្រៅប្រទេស ការខិតខំគៀងគរ និងស្វែងរកទីផ្សារសម្រាប់ផលិតផលកសិផលរបស់ប្រជាពលរដ្ឋ ព្រមទាំងការជំរុញពាណិជ្ជកររកស៊ីលក់ដូរទាំងអស់កំណត់តម្លៃទំនិញបិទលើមុខទំនិញឲ្យបានច្បាស់លាស់ ដោយឲ្យម្ចាស់អាជីវកម្មទាំងអស់ក្នុងខេត្តចុះបញ្ជីការពាណិជ្ជកម្មឲ្យបានត្រឹមត្រូវពីក្រសួងពាណិជ្ជកម្ម។

ដើម្បីចូលរួមអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងជំរុញការចុះបញ្ជីការពាណិជ្ជកម្មឲ្យបានត្រឹមត្រូវពីក្រសួងពាណិជ្ជកម្ម ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ អាជីវកម្មគ្រប់ប្រភេទ នឹងមានច្បាប់អនុញ្ញាតទាំងអស់ទូទាំងខេត្ត ”។

### ២.២.១.៧ គោលដៅអភិវឌ្ឍន៍វិស័យពន្ធដារ

វិធានការសម្រាប់អាជីវកម្ម និងចុះពិនិត្យលើទំនិញគ្រប់ប្រភេទ ជាកិច្ចការមួយដ៏ប្រសើរសម្រាប់ការជំរុញការប្រមូលពន្ធគ្រប់ប្រភេទឲ្យបានគ្រប់ចំនួនតាមផែនការ និងងាយស្រួលក្នុងការគ្រប់គ្រងចំណូលពន្ធដារគ្រប់ប្រភេទពីអាជីវកម្មគ្រប់ប្រភេទក្នុងខេត្ត ដែលតម្រូវឲ្យមានការចូលរួមពីអង្គភាពពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មាន និងកិច្ចការផ្សេងៗ ដោយសហការគ្រប់ពេលវេលា។

ដើម្បីបង្កើនចំណូលខេត្ត និងធ្វើឲ្យមានដំណើរការល្អ ក្នុងការប្រមូលពន្ធគ្រប់ប្រភេទឲ្យបានគ្រប់ចំនួនតាមផែនការ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ការប្រមូលពន្ធគ្រប់ប្រភេទ នឹងមានការកើនឡើងតាមរយៈការអនុវត្តបានត្រឹមត្រូវគ្រប់ប្រភពពន្ធត្រូវប្រមូល ”។

### ២.២.១.៨ គោលដៅអភិវឌ្ឍន៍វិស័យឯកជន

វិស័យឯកជន បានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចជនបទ និងសេដ្ឋកិច្ចទីប្រជុំជន តាមរយៈការអនុវត្តនូវប្រព័ន្ធ ឯកសារតែមួយ និងសេវាច្រកចេញចូលតែមួយ សំដៅសម្រួលលើកទឹកចិត្តឲ្យវិស័យឯកជនចូលរួមក្នុងការអភិវឌ្ឍវិស័យនានារបស់ខេត្ត។ ការរៀបចំស្ថាបនា និងកែសម្រួលទីផ្សារធំៗនៅក្នុងតំបន់ទីប្រជុំជនមួយចំនួនឲ្យមានអានាម័យ សណ្តាប់ធ្នាប់ និងរបៀបរៀបរយ និងការជំរុញការវិនិយោគផ្នែកវិស័យឯកជនទៅ

លើរោងចក្រវាយនភ័ណ្ឌ និងសហគ្រាសធំៗ ព្រមទាំងសហគ្រាសធន់តូចនិងមធ្យមឲ្យកើនឡើង ជាតម្រូវការមួយដែលខេត្តចង់បាន។

ដើម្បីអភិវឌ្ឍវិស័យឯកជន និងជំរុញការវិនិយោគផ្នែកវិស័យឯកជនឲ្យផុលផុស ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

" នៅឆ្នាំ២០១៥ ការវិនិយោគផ្នែកវិស័យឯកជនទៅលើរោងចក្រសហគ្រាស នឹងបង្កើតឲ្យបាន១៥កន្លែង និងពង្រីកមុខរបរអាជីវកម្ម និងជំរុញសហគ្រាសធន់តូច និងមធ្យមឲ្យកាន់តែប្រសើរ "។

## ២.២.១.៩ គោលដៅអភិវឌ្ឍន៍វិស័យទេសចរណ៍

ជំរុញអ្នកប្រកបរបរអាជីវកម្មទេសចរណ៍ ក្នុងការពង្រឹង ចលនាប្រលងប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត និងសេវាកម្មល្អ ជាកិច្ចការមួយទៀត ដែលខេត្តមិនអាចរំលងបាន ហើយទាមទារការពង្រឹងគុណភាព ដោយផ្សព្វផ្សាយច្បាប់ តាមរយៈការបណ្តុះបណ្តាលអំពីមគ្គុទ្ទេសទេសចរណ៍ និងការបដិសណ្ឋារកិច្ចភ្ញៀវដល់ភ្នាក់ងារទេសចរណ៍ និងអ្នកប្រកបអាជីវកម្មលើវិស័យទេសចរណ៍។ ការថែរក្សាបរិស្ថាន និងអនាម័យក្នុងរមណីយដ្ឋាន សេវាកម្មកំសាន្តនានា ជាកាតាព្វកិច្ចមួយ ដែលត្រូវទាមទារនូវការចងក្រងតំបន់ទេសចរណ៍ធម្មជាតិ និងសហគមន៍ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឲ្យចូលទស្សនារមណីយដ្ឋានក្នុងខេត្ត ប្រកបដោយនិរន្តភាព។

ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ និងពង្រឹងចលនាប្រលងប្រឡងប្រណាំងបីល្អ ទីក្រុងស្អាត រមណីដ្ឋានស្អាត និងសេវាកម្មល្អ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

" នៅឆ្នាំ២០១៥ ទេសចរណ៍សហគមន៍ នឹងត្រូវបានពង្រឹង ពង្រីក និងអភិរក្សនៅតាមតំបន់សក្តានុពល "។

## ២.២.១.១០ គោលដៅអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ ហាក់ដូចជាមានការខ្វះខាតច្រើននៅឡើយ ពីព្រោះប្រជាពលរដ្ឋភាគច្រើនពុំទាន់យល់ដឹង ពីប្រភេទសេវាកម្ម និងផលប្រយោជន៍របស់វានៅឡើយទេ។ កង្វះខាតធនធានមនុស្ស និងសម្ភារៈ និងឧបករណ៍ប្រើប្រាស់ទំនើបៗលើការបម្រើសេវាកម្មទាំងពីរ មិនទាន់ធ្វើឲ្យទៅដល់ទីជនបទនៅឡើយទេ។ កង្វះខាតការផ្សព្វផ្សាយច្បាប់និងការគ្រប់គ្រងលើវិស័យនេះនៅមានភាពធូរលុង។

ដើម្បីបំពេញកង្វះខាតខាងលើនេះ និងដើម្បីចូលរួមអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋខេត្តកំពង់ស្ពឺ នឹងមានសេវាប្រៃសណីយ៍ និងទូរគមនាគមន៍តាមបណ្តាស្រុកទូទាំងខេត្ត ”។

## ២.២.២ គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច

ការចូលរួមលើកស្ទួយអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍ ជាកិច្ចការមួយសំខាន់របស់ខេត្តទាំងមូល តាមរយៈការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការពង្រឹង និងកែលម្អវិស័យព្រះពុទ្ធសាសនា និងកិច្ចការធម្មការ ការកាត់បន្ថយចលនាចំណាកស្រុក...។ល។

ដើម្បីចូលរួមសម្រេចឲ្យបានចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួន ខេត្តក៏ត្រូវបង្កើតនូវគោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ចតាមវិស័យនានាដូចខាងក្រោម៖

### ២.២.២.១ គោលដៅអភិវឌ្ឍន៍វិស័យអប់រំ

ការលើកកម្ពស់ក្នុងការអនុវត្តយុទ្ធសាស្ត្រ អប់រំសម្រាប់ទាំងអស់គ្នា ដើម្បីឲ្យទូទាំងខេត្តធានាសមធម៌ ក្នុងការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ សម្រាប់កុមារគ្រប់រូបតាមសកម្មភាពអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ និងការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាអប់រំ តាមរយៈការលើកទឹកចិត្តដល់ការបង្រៀនរបស់គ្រូ និងការរៀនសូត្ររបស់សិស្សថ្នាក់បឋម និងមធ្យមសិក្សាទាំងសាលារៀនរដ្ឋក៏ដូចជាសាលាឯកជន ជាភារកិច្ចចំបងក្នុងការអភិវឌ្ឍវិស័យអប់រំ តាមទីជនបទ និងតាមទីប្រជុំជនធំៗក្នុងខេត្ត។ គោលនយោបាយអប់រំកុមារតូច ត្រូវតែជំរុញឲ្យមានសកម្មភាពល្អតាមរយៈការពង្រឹងមត្តេយ្យរដ្ឋ និងឯកជនដែលមាន និងការរៀបចំបង្កើតមត្តេយ្យសហគមន៍បន្ថែមទៀតគិតទាំងមត្តេយ្យខ្នងផ្ទះផង។

ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពលើវិស័យអប់រំនេះ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ សិស្សានុសិស្សទាំងពីរភេទ នឹងទទួលបានសេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅគ្រប់កម្រិតសិក្សា រួមទាំងប្រជាពលរដ្ឋដែលមិនចេះអក្សរ នឹងទទួលបានការអប់រំក្រៅប្រព័ន្ធដ៏មានប្រសិទ្ធភាពខ្ពស់ ”។

### ២.២.២.២ គោលដៅអភិវឌ្ឍន៍ វិស័យសុខាភិបាល

ប្រជារាស្ត្រមានសុខភាពល្អ គឺជាមូលដ្ឋានគន្លឹះសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចដោយចីរភាព។ រដ្ឋបាលខេត្ត នឹងបន្តជំរុញការលើកកម្ពស់ ការផ្តល់

សេវាសុខភាព ជូនប្រជាពលរដ្ឋពិសេសប្រជាពស្ត្រក្រីក្រ និងកុមារការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក បញ្ហាសុខភាពបន្តពូជសុខភាពមាតា សុខភាពទារក និងកុមារ និងទប់ស្កាត់ជម្ងឺរាតត្បាត នានាឲ្យមានប្រសិទ្ធភាព។ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បរិក្ខាពេទ្យ និងបច្ចេកវិទ្យា និងការលើកកម្ពស់សេវាគាំទ្រផ្សេងៗទៀតត្រូវតែធ្វើឲ្យសម្រេចលទ្ធផលជាវិជ្ជមាន។

ដើម្បីលើកកម្ពស់សេវាសុខភាព ជូនប្រជាពលរដ្ឋ និងកុមារ ព្រមទាំងការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ សុខុមាលភាពរបស់ប្រជាពលរដ្ឋ នឹងត្រូវបានលើកកម្ពស់ ”។

### ២.២.២.៣ គោលដៅអភិវឌ្ឍន៍វិស័យយេនឌ័រ

សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី គឺជាគោលដៅអភិវឌ្ឍន៍មួយយ៉ាងសំខាន់របស់ខេត្ត តាមរយៈការបញ្ជ្រាបយេនឌ័រក្នុងរាល់វិស័យ និងសកម្មភាពការងារជាអាទិភាព និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការពង្រឹងសមត្ថភាពស្ត្រីក្នុងការសម្រេចចិត្ត និងយន្តការនានារបស់ខេត្ត-ឃុំដូច ជាវិស័យសេដ្ឋកិច្ច កសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល...។ល។

ដើម្បីលើកតម្កើងតម្លៃស្ត្រីក្នុងសង្គម និងពង្រឹងសមត្ថភាពស្ត្រីក្នុងការសម្រេចចិត្ត ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនឹងត្រូវបានការលើកកម្ពស់ ”។

### ២.២.២.៤ គោលដៅកាត់បន្ថយស្ថានភាពនៃភាពក្រីក្រ

គោលនយោបាយសំខាន់ របស់រដ្ឋបាលខេត្ត គឺគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នេះគឺជាបំណងប្រាថ្នាសំខាន់បំផុត ការពង្រឹងយន្តការគ្រប់វិស័យលើកកម្ពស់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។ កិច្ចខិតខំអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ ជូនប្រជាពលរដ្ឋឲ្យបានជោគជ័យជាជំហានៗ ជាគោលដៅសំខាន់របស់រាជរដ្ឋាភិបាល និងរដ្ឋបាលខេត្តទាំងមូល។

ដើម្បីជំរុញកម្រិតជីវភាពប្រជាពលរដ្ឋ ឲ្យប្រសើរឡើង តាមរយៈគោលនយោបាយកាត់បន្ថយភាពក្រីក្រ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ស្ថានភាពក្រីក្រ នឹងត្រូវបានកាត់បន្ថយចំនួន៦%បន្ថែមទៀត ”។

### ២.២.២.៥ គោលដៅអភិវឌ្ឍន៍វិស័យសាសនា

ការរៀបចំបង្កើតឲ្យមានសាលាពុទ្ធិកសម្រាប់ព្រះសង្ឃ ឲ្យបានកម្រិតបឋមសិក្សា ការជំរុញឲ្យមានសកម្មភាពនានាក្នុងព្រះពុទ្ធសាសនា ជ្រើសរើសវត្តដែលមានលទ្ធភាព ឲ្យបង្កើតសាលាផ្នែកព្រះពុទ្ធសាសនា ដើម្បីធ្វើឲ្យប្រសើរឡើងវិញនៃការអភិវឌ្ឍវិស័យសាសនា ជាកិច្ចការមួយ

ផ្សេងទៀត ដែលអាជ្ញាធរខេត្ត និងប្រជាពលរដ្ឋត្រូវយកចិត្តទុកដាក់ក្នុងការកែលម្អ និងលើកស្ទួយព្រះពុទ្ធសាសនាឡើងវិញ។

ដើម្បីជំរុញការអភិវឌ្ឍវិស័យសាសនា ពិសេសការកែលម្អ និងលើកស្ទួយព្រះពុទ្ធសាសនាឡើងវិញ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“នៅឆ្នាំ២០១៥ វិស័យព្រះពុទ្ធសាសនា និងកិច្ចការធម្មការ នឹងត្រូវបានពង្រឹងនិងកែលម្អ”។

### ២.២.២.៦ គោលដៅអភិវឌ្ឍន៍លើវិស័យអន្តោប្រវេសន៍ និងបម្លាស់ទី

ការទប់ស្កាត់ចំណាកស្រុកប្រកបដោយគ្រោះថ្នាក់ ដែលជាឥទ្ធិពលអវិជ្ជមានដល់ការងារអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ទាមទារឲ្យមានការចូលរួមយ៉ាងសកម្ម និងការយល់ដឹងកម្រិតខ្ពស់ពីប្រជាពលរដ្ឋតាមសហគមន៍ក្រីក្រ ក្នុងការបញ្ជូនសមាជិកគ្រួសារ ទៅរកការងារនៅតំបន់ឆ្ងាយពីផ្ទះ និងប្រកបដោយគ្រោះថ្នាក់។ ការលើកទឹកចិត្តដល់វិស័យឯកជន និងការជំរុញការចូលរួមពីសង្គមស៊ីវិល និងអង្គការ អភិវឌ្ឍន៍ជាដៃគូរក្នុងដែនសមត្ថកិច្ច ដើម្បីបង្កើនការងារ ជាកិច្ចការសំខាន់ដែលអាជ្ញាធរខេត្តត្រូវការដោះស្រាយជាចាំបាច់។

ដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកប្រកបដោយគ្រោះថ្នាក់ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ចលនាចំណាកស្រុក នឹងត្រូវបានកាត់បន្ថយ ”។

### ២.២.២.៧ គោលដៅអភិវឌ្ឍន៍វិស័យផ្សេងៗពាក់ព័ន្ធ និងផ្នែកសង្គមកិច្ច

ក្រៅពីវិស័យសំខាន់ៗខាងលើ ខេត្តត្រូវដាក់ចេញនូវគោលដៅរួមក្នុងការខិតខំលើកកម្ពស់សកម្មភាពរបស់វិស័យផ្សេងៗទៀតដូចជា វិស័យវប្បធម៌ និងសិល្បៈ ដែលមានភារៈកិច្ចជួយលើផ្នែកសិប្បកម្ម ផ្នែកចម្លាក់ និងការងារតម្បាញដែលជាសកម្មភាពជួយលើកស្ទួយផ្នែកសង្គមកិច្ច។ វិស័យសង្គមកិច្ច អតីតយុទ្ធជន វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ...។ល។ បម្រើជីវភាពខាងស្មារតី នៅក្នុងសង្គមបានល្អប្រសើរ។ ដូចនេះខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដើម្បីចូលរួមចំណែកក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យអភិវឌ្ឍន៍ខេត្តដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការពង្រឹងសមត្ថភាពទាំងជំនាញ និងចំណេះដឹង ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធលើគ្រប់វិស័យ នឹងត្រូវបានលើកតម្កើង ”។

## ២.២.៣ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.២.៣. ១ គោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងដីធ្លី

ការប្រើប្រាស់ដ៏មាននិរន្តភាព នៃធនធានធម្មជាតិទាំងឡាយ គឺជាកត្តាដ៏សំខាន់បំផុតមួយ

សម្រាប់ការអភិវឌ្ឍនៅក្នុងខេត្ត។ ចំនួនប្រហែល៣/៤នៃប្រជាពលរដ្ឋសរុបក្នុងខេត្ត គឺពាក់ព័ន្ធផ្ទាល់ក្នុងវិស័យកសិកម្ម និងអាស្រ័យទាំងស្រុងលើដីកសិកម្មទាំងនោះ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់គេ។ វិស័យកសិកម្ម និងព្រៃឈើបានផ្តល់ផលប្រមាណ៤០% ដល់ផលិតផលជាតិសរុប (GDP) ក្នុងនោះ វិស័យទេសចរណ៍ក៏ពឹងពាក់ផងដែរលើភាពអាស្ចារ្យរបស់ធម្មជាតិ និងវប្បធម៌។

ដើម្បីជំរុញការចុះបញ្ជីដីធ្លី និងកាត់បន្ថយវិវាទដីធ្លី និងការអប់រំឲ្យប្រជាពលរដ្ឋយល់ដឹងពីការថែទាំធនធានធម្មជាតិនិងបរិស្ថាន និងការចាត់វិធានការរាល់ការសាងសង់សំណង់ ដែលគ្មានការអនុញ្ញាតទូទាំងខេត្ត ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូច ខាងក្រោម៖

“ នៅឆ្នាំ២០១៥ ការចុះបញ្ជីដីធ្លីនឹងត្រូវបានបង្កើនរួមនិងវិវាទដីធ្លីនឹងត្រូវបានកាត់បន្ថយ ”។

## ២.២.៣. ២ គោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានត្រូវបន្តពឹងផ្អែកលើយន្តការដែលមានស្រាប់របស់ខ្លួន និងការស្វែងរកការគាំទ្រថ្មីបន្ថែមទៀត ដើម្បីកែប្រែភាពអសកម្មទាំងឡាយ ដែលខេត្តបានពើងប្រទះកន្លងមក តាមរយៈការផាកពិន័យ ឬបញ្ឈប់ចំពោះកសិដ្ឋានអាជីវកម្មណា ដែលគ្មានច្បាប់ ឬមិនគោរពកិច្ចសន្យាការពារបរិស្ថាន ការអភិវឌ្ឍតំបន់ ដែលមានសក្តានុពលដើម្បីកាត់បន្ថយការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងជីវចម្រុះដោយរក្សានូវបឹងបួរធម្មជាតិ និងតំបន់អភិរក្សធនធានធម្មជាតិនានា។

ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងយល់ដឹងបន្ថែមពីការថែរក្សាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ”។

## ២.២.៣.៣ គោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយបណ្តាលមកពីធម្មជាតិ គឺជាកង្វល់មួយដែលវាមិនមែនជាការទទួលខុសត្រូវរបស់នរណាម្នាក់ ឬស្ថាប័នណាមួយឡើយ តែវាជាកង្វល់រួម និងរបស់ជាតិនៅលើផែនដីទាំងមូល ដែលរដ្ឋបាលខេត្តតែម្នាក់ឯងមិនអាចដោះស្រាយបាន តែការពិនិត្យ និងពិភាក្សាផ្តល់យោបល់លើសកម្មភាពការងារផ្សេងៗទាន់ទងនឹងការបន្សាំ ទៅនឹងបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយបណ្តាលមកពីធម្មជាតិ ដូចភាពរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ អគ្គីភ័យ ការឡើងកំដៅ និងការកើតជម្ងឺអាកាសធាតុផ្សេងៗ ជាកិច្ចសំខាន់ដែលរដ្ឋបាលខេត្តត្រូវយកចិត្តទុកដាក់។

ដើម្បីទប់ទល់ និងគ្រប់គ្រងទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយបណ្តាល

មកពីធម្មជាតិនេះ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

" នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងយល់ដឹងបន្ថែមពីការការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ និងកាត់បន្ថយបាននូវគ្រោះថ្នាក់នានាដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ"។

## ២.២.៤ គោលដៅអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីបង្កើនប្រសិទ្ធភាព ក្នុងការចាត់តាំងអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល សំដៅលើកស្ទួយការផ្តល់សេវាសាធារណៈ ឲ្យកាន់តែល្អប្រសើរឡើងឆ្លើយតបទៅនឹងបំណងរបស់ប្រជាពលរដ្ឋ និងការពង្រឹងប្រព័ន្ធច្បាប់ដើម្បីលើកកម្ពស់ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ រដ្ឋបាលខេត្តមានគោលដៅអភិវឌ្ឍន៍មួយចំនួនដូចខាងក្រោម៖

### ២.២.៤.១ គោលដៅអភិវឌ្ឍន៍ការគ្រប់គ្រងដែនដី និងការងារអភិបាលកិច្ចល្អ

ដើម្បីចូលរួមក្នុងការអនុវត្ត គោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការជំរុញឲ្យច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព តាមរយៈការអប់រំផ្សព្វផ្សាយជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋឲ្យបានទូលំទូលាយ សំដៅបង្ការទប់ស្កាត់ជាមុន ដោយមានការគាំទ្រពីសាធារណៈជន និងការចូលរួមរបស់វិស័យឯកជន ព្រមទាំងការអភិវឌ្ឍសមត្ថភាព របស់ក្រុមប្រឹក្សាខេត្តក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ និងយន្តការនានា។

ដើម្បីសម្រេចនូវការអភិវឌ្ឍការគ្រប់គ្រងដែនដី និងការងារអភិបាលកិច្ចល្អ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

" នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងទទួលបានសេវាសាធារណៈកាន់តែល្អប្រសើរ "។

### ២.២.៤.២ គោលដៅអភិវឌ្ឍន៍លើការងារគ្រប់គ្រងស្ថិតិ

ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន ជាគោលដៅមួយយ៉ាងសំខាន់ដែលរដ្ឋបាលខេត្ត ត្រូវយកចិត្តទុកដាក់ឲ្យបានល្អប្រសើរ សម្រាប់បម្រើការអភិវឌ្ឍធនធានមនុស្សឲ្យបានជោគជ័យ ទន្ទឹមនឹងការពង្រឹងវិធានការគ្រប់គ្រងស្ថិតិវិស័យផ្សេងៗទៀត ឲ្យបានច្បាស់លាស់ ដើម្បីមានមូលដ្ឋានព័ត៌មានទិន្នន័យបម្រើឲ្យកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ។

ដើម្បីសម្រេចនូវការអភិវឌ្ឍលើការងារគ្រប់គ្រងស្ថិតិ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

" នៅឆ្នាំ២០១៥ ការងារគ្រប់គ្រងស្ថិតិលើការរៀបចំកិច្ចការចុះអត្រានុកូលដ្ឋាន និងការធ្វើ

អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ នឹងមានភាពប្រសើរឡើង ”។

### ២.២..៣.៤ គោលដៅអភិវឌ្ឍន៍លើការធានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ការពង្រឹង សន្តិសុខនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈជាគោលដៅគន្លឹះ របស់រដ្ឋបាលខេត្ត ដែលជាបរិស្ថានបង្កឱកាស ដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយនានា ពិសេសគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ បើទោះបីការយកចិត្តទុកដាក់លើគ្រប់អ្នកពាក់ព័ន្ធក៏ដោយ ក៏មានភាពបញ្ហា និងបទល្មើសជាច្រើនបាន និងកំពុងកើតឡើងជាបន្តបន្ទាប់រហូតដែរ។

ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងទប់ស្កាត់បទល្មើសផ្សេងៗ ខេត្តបានដាក់ចេញនូវគោលដៅរបស់ខ្លួនដូចខាងក្រោម៖

“ នៅឆ្នាំ២០១៥ បញ្ហាសុវត្ថិភាព ស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងកង្វះខាតលើការគ្រប់គ្រងស្ថិតិ នឹងត្រូវបានកាត់បន្ថយជាអតិប្បរមា ”។

## ២.៣ គោលបំណងអភិវឌ្ឍន៍

### ២.៣.១ គោលបំណងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

### ២.៣.១.១ គោលបំណងអភិវឌ្ឍន៍វិស័យកសិកម្ម

ដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងការធ្វើឲ្យប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺមានជីវភាពល្អប្រសើរ មានចំណូលប្រចាំឆ្នាំកើនឡើង តាមរយៈលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្មនៅឆ្នាំ២០១៥នោះ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍន៍វិស័យកសិកម្មដូចខាងក្រោម៖

- បង្កើនទិន្នផលស្រូវដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភឲ្យបានពី២.៦០ត/ហ.ត នៅឆ្នាំ២០១០ទៅ៣.១០ត/ហ.ត នៅឆ្នាំ២០១៥។
- បង្កើនការផលិតស្រូវ និងការនាំអង្ករចេញឱ្យបានពី២០០០តោននៅឆ្នាំ២០១០ ទៅ២០០០០តោននៅឆ្នាំ២០១៥។
- បង្កើនផលិតកម្មសត្វដើម្បីធានាការអូសទាញ និងបម្រើម្ហូបអាហារឱ្យបាន១៩.៧១%បន្ថែមទៀតនៅឆ្នាំ២០១៥។
- បង្កើនការប្រើប្រាស់ឡជីវឧស្ម័ន រួមចំណែកលើកកម្ពស់សុខភាព និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិឱ្យបាន ពី១,១២២គ្រឿង នៅឆ្នាំ២០១០ ទៅ៣,៥២០គ្រឿង នៅឆ្នាំ២០១៥។

- បង្កើនផលិតកម្មដំណាំបន្លែឱ្យបានពី២៨.៦៨% បន្ថែមទៀតនៅឆ្នាំ២០១៥។
- បង្កើនការវិនិយោគកសិ-ឧស្សាហកម្មឱ្យបាន ពី៨០០០ហ.តនៅឆ្នាំ២០១០ទៅ ៣៦០០០ ហ.ត នៅឆ្នាំ២០១៥។
- បង្កើនការចិញ្ចឹមត្រីឱ្យបានពី៣៨.៥% បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.២ គោលបំណងអភិវឌ្ឍន៍វិស័យធនធានទឹក

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ដើម្បីធ្វើឲ្យប្រជាពលរដ្ឋទទួលបានការសាងសង់ និងជួសជុល ទំនប់ទឹក ការស្តារប្រឡាយស្រោចស្រព ប្រព័ន្ធដោះទឹក និងប្រព័ន្ធស្រោចស្រពខ្នាតតូចដើម្បីពង្រីកផ្ទៃដីស្រោចស្រពដាំដុះ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យធនធានទឹកដូចខាងក្រោម៖

- ស្តារប្រព័ន្ធស្រោចស្រពឲ្យបាន១៧%បន្ថែមទៀតនៅឆ្នាំ២០១៥។
- ពង្រីកផ្ទៃដី ស្រោចស្រពដាំដុះឲ្យបាន១២%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៣ គោលបំណងអភិវឌ្ឍន៍វិស័យគមនាគមន៍

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យគមនាគមន៍ ដើម្បីធ្វើឲ្យប្រជាពលរដ្ឋទទួលបានការជួសជុល និងថែទាំផ្លូវគមនាគមន៍ជនបទកាន់តែប្រសើរ ខេត្តបានកំណត់នូវគោលបំណងខាងការ អភិវឌ្ឍវិស័យគមនាគមន៍ដូចខាងក្រោម៖

- ថែទាំ និងជួសជុលផ្លូវលំជនបទទាំងអស់ឱ្យបាន២០% បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៤ គោលបំណងអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រ៉ែ និងថាមពល ទទួលបាននូវការលើកកម្ពស់ តាមរយៈការពង្រឹងអាជីវកម្មខ្សាច់ដោយអនុវត្តតាមបទដ្ឋានបច្ចេកទេស និងការតបណ្តាញអគ្គីសនីសម្រាប់ប្រើប្រាស់គ្រប់ៗផ្ទះ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យឧស្សាហកម្ម រ៉ែ និងថាមពលដូចខាងក្រោម៖

- ពង្រឹងការធ្វើអាជីវកម្មខ្សាច់ទាំងអស់ដោយអនុវត្តត្រឹមត្រូវតាមបច្ចេកទេស និងមិនប៉ះពាល់បរិស្ថានឱ្យបាន១៥%បន្ថែមទៀតនៅឆ្នាំ២០១៥។
- តបណ្តាញអគ្គីសនីតាមលំនៅដ្ឋានឱ្យបាន៥០%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៥ គោលបំណងអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ជនបទ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ជនបទ ក្នុងការធ្វើឲ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ និងរស់នៅប្រកបដោយសុខមាលភាព ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យអភិវឌ្ឍន៍ជនបទដូចខាងក្រោម៖

- ជំរុញឱ្យមានទឹកស្អាត បង្គន់អនាម័យប្រើប្រាស់គ្រប់គ្រួសារឱ្យបាន២៥%បន្ថែមទៀត នៅឆ្នាំ២០១៥។

### ២.៣.១.៦ គោលបំណងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ដែលតម្រូវឲ្យអាជីវកម្មគ្រប់ប្រភេទមានច្បាប់អនុញ្ញាតទាំងអស់ទូទាំងខេត្ត ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យពាណិជ្ជកម្មរបស់ខ្លួនដូចខាងក្រោម៖

- ជំរុញការអនុវត្តច្បាប់អនុញ្ញាតគ្រប់គ្រងអាជីវកម្មទូទាំងខេត្ត និងជំរុញការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារឱ្យបាន៤០% បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៧ គោលបំណងអភិវឌ្ឍន៍វិស័យពន្ធដារ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យពន្ធដារ ដែលចង់ឲ្យការប្រមូលពន្ធគ្រប់ប្រភេទមានការកើនឡើងតាមរយៈការអនុវត្តបានត្រឹមត្រូវគ្រប់ប្រភពពន្ធត្រូវប្រមូល ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យពន្ធដាររបស់ខ្លួនដូចខាងក្រោម៖

- បង្កើនការប្រមូលពន្ធដាឱ្យបាន៣៨.៩៣%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៨ គោលបំណងអភិវឌ្ឍន៍វិស័យឯកជន

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យឯកជន ក្នុងការជំរុញការវិនិយោគផ្នែកវិស័យឯកជនទៅលើរោងចក្រសហគ្រាស ដោយបង្កើតឲ្យបាន១៥កន្លែង និងពង្រីកមុខរបរអាជីវកម្ម និងជំរុញសហគ្រាសធន់តូច និងមធ្យមឲ្យកាន់តែប្រសើរ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យឯកជនរបស់ខ្លួនដូចខាងក្រោម៖

- ជំរុញការវិនិយោគផ្នែកវិស័យឯកជនទៅលើរោងចក្រវាយនភ័ណ្ឌ និងសហគ្រាសធំៗកើនឡើង១៥កន្លែង និងសហគ្រាសធន់តូច និងមធ្យមឱ្យបាន២២%បន្ថែមទៀតនៅឆ្នាំ២០១៥។
- ជំរុញការរៀបចំស្ថាបនា និងកែសម្រួល ទីផ្សារ ធំៗនៅក្នុងតំបន់ទីប្រជុំជនមួយចំនួនឲ្យមានអានាម័យសណ្តាប់ធ្នាប់ និងរបៀបរៀបរយឱ្យបានឱ្យបាន២៥%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.១.៩ គោលបំណងអភិវឌ្ឍន៍វិស័យទេសចរណ៍

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យទេសចរណ៍ ក្នុងការធ្វើឲ្យទេសចរណ៍សហគមន៍ទទួលនូវការបានពង្រឹង ពង្រីក និងអភិរក្សនៅតាមតំបន់សក្តានុពល ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យទេសចរណ៍របស់ខ្លួនដូចខាងក្រោម៖

- ពង្រឹងពង្រីកនិងអភិរក្សតំបន់ ទេចរណ៍វប្បធម៌ធម្មជាតិ និងប្រវត្តិសាស្រ្តព្រមទាំងជំរុញឲ្យមានការកើនឡើងនូវរមណីដ្ឋានឱ្យបាន១០%បន្ថែមទៀតទូទាំងខេត្តនៅឆ្នាំ២០១៥។

### ២.២.១.១០ គោលបំណងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការជំរុញឲ្យប្រជាពលរដ្ឋមានសេវាប្រៃសណីយ៍ និងទូរគមនាគមន៍តាមបណ្តាស្រុកទូទាំងខេត្ត ខេត្តបានកំណត់ នូវគោលបំណងខាងការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍របស់ខ្លួនដូចខាងក្រោម៖

- ពង្រីកការតភ្ជាប់ប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍ និងសេវាប្រៃសណីយ៍ទៅតាមបណ្តាស្រុកទូទាំងខេត្តឱ្យបាន៥%បន្ថែមទៀតនៅឆ្នាំ២០១៥។
- ស្តារហេដ្ឋារចនាសម្ព័ន្ធនានាឲ្យទៅដល់បណ្តាស្រុក និងឃុំ-សង្កាត់ទាំង៨២ ឱ្យបាន១០% នៅឆ្នាំ២០១៥។

## ២.៣.២ គោលបំណងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច

### ២.៣.២.១ គោលបំណងអភិវឌ្ឍន៍វិស័យអប់រំ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យអប់រំ ដោយធ្វើឲ្យសិស្សានុសិស្សទាំងពីរភេទទទួលបានសេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅគ្រប់កម្រិតសិក្សារួមទាំងប្រជាពលរដ្ឋ ដែលមិនចេះអក្សរទទួលបានការអប់រំក្រៅប្រព័ន្ធដ៏មានប្រសិទ្ធភាពខ្ពស ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យអប់រំរបស់ខ្លួនដូចខាងក្រោម៖

- បង្កើនកុមារចូលរៀនគ្រប់កម្រិតសិក្សា៖
  -មត្តេយ្យសិក្សាឱ្យបាន២៤.០៩% បន្ថែមទៀតនៅឆ្នាំ២០១៥
  -បឋមសិក្សាឱ្យបាន៤.៨% ទៀត បន្ថែមនៅឆ្នាំ២០១៥
  -មធ្យមសិក្សាបឋមភូមិឱ្យបាន២៣.៨% បន្ថែមទៀតនៅឆ្នាំ២០១៥
  -មធ្យមសិក្សាទុតិយភូមិឱ្យបាន១០.៩% បន្ថែមទៀតនៅឆ្នាំ២០១៥
- ពង្រឹងគុណភាពអប់រំបានឱ្យល្អប្រសើរដោយបង្កើនអត្រាឡើងថ្នាក់តាមផែនការគ្រប់កម្រិតសិក្សា៖
  -បឋមសិក្សាឱ្យបាន៤.៦៨% បន្ថែមទៀតនៅឆ្នាំ២០១៥
  -មធ្យមសិក្សាបឋមភូមិឱ្យបាន១៤.៣៨% បន្ថែមទៀតនៅឆ្នាំ២០១៥
  -មធ្យមសិក្សាទុតិយភូមិឱ្យបាន៨.២៩% បន្ថែមទៀតនៅឆ្នាំ២០១៥
- លើកកម្ពស់ពលរដ្ឋអាយុពី១៥ទៅ៤៥ឆ្នាំដែលមិនចេះអក្សរឲ្យឆ្លងផុតអនក្ខរភាពចំនួន២% បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.២.២ គោលបំណងអភិវឌ្ឍន៍វិស័យសុខាភិបាល

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យសុខាភិបាល ក្នុងការលើកកម្ពស់សុខុមាលភាព

របស់ប្រជាពលរដ្ឋ ព្រមទាំងការកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យសុខាភិបាលរបស់ខ្លួនដូចខាងក្រោម៖

- កាត់បន្ថយ អត្រាមរណៈភាពមាតានិងទារកឲ្យបាន៦% បន្ថែមទៀតនៅឆ្នាំ២០១៥។
- ទប់ស្កាត់ជម្ងឺឆ្លង និងបញ្ហាសុខភាពដ៏ទៃទៀត មានការបង្ការមេរោគអេសដ៍ ការបង្ការជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងជម្ងឺផ្សេងៗដល់ប្រជាពលរដ្ឋទូទៅឱ្យបាន១០%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.២.៣ គោលបំណងអភិវឌ្ឍន៍វិស័យយេនឌ័រ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យយេនឌ័រ ក្នុងការធ្វើឲ្យមានសមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាច ការលើកកម្ពស់ដល់ស្រ្តីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យយេនឌ័ររបស់ខ្លួនដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពដល់ស្រ្តីឱ្យទទួលបាននូវសមភាពយេនឌ័រឱ្យបាន៤០%បន្ថែមទៀតនៅឆ្នាំ២០១៥។
- បង្កើនចំនួនស្រ្តីទៅក្នុងតួនាទីធ្វើសេចក្តីសម្រេច ចិត្តគ្រប់កម្រិតឱ្យបាន១០%បន្ថែមទៀតនៅឆ្នាំ២០១៥។
- ពង្រឹងការលើកកម្ពស់សមត្ថភាពសេដ្ឋកិច្ចសង្គមរបស់ស្រ្តីឱ្យបាន៣៣%បន្ថែមទៀតនៅឆ្នាំ២០១៥។
- ពង្រឹងសមត្ថភាពយល់ដឹងជាមូលដ្ឋានដល់ស្រ្តី អំពីសុខភាព អនាម័យ និងជម្ងឺឆ្លងទូទៅឱ្យបាន២០%បន្ថែមទៀតនៅ២០១៥។

### ២.៣.២.៤ គោលបំណងអភិវឌ្ឍន៍វិស័យស្ថានភាព នៃភាពក្រីក្រ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ក្នុងការកាត់បន្ថយស្ថានភាពនៃភាពក្រីក្រ ក្នុងការធ្វើឱ្យស្ថានភាពក្រីក្រ ទទួលបានការកាត់បន្ថយចំនួន៦%បន្ថែមទៀត ខេត្តបានកំណត់នូវគោលបំណងក្នុងការកាត់បន្ថយភាពក្រីក្ររបស់ខ្លួនដូចខាងក្រោម៖

- ជំរុញរាល់សកម្មភាពនានា ពិសេសផលិតភាពកសិកម្មដើម្បីធ្វើឲ្យមានកំណើនសេដ្ឋកិច្ចចំនួន២០% បន្ថែមទៀតនៅ២០១៥ ដើម្បីកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ។

### ២.៣.២.៥ គោលបំណងអភិវឌ្ឍន៍វិស័យសាសនា

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍វិស័យសាសនា ក្នុងការធ្វើឱ្យវិស័យព្រះពុទ្ធសាសនានិងកិច្ចការធម្មការ ទទួលបានការពង្រឹង និងកែលម្អ ខេត្តបានកំណត់នូវគោលបំណងអភិវឌ្ឍន៍ខាងវិស័យសាសនារបស់ខ្លួនដូចខាងក្រោម៖

- បង្កើតឱ្យមានពុទ្ធិកបឋម និងអនុវិទ្យាល័យ និងពង្រឹងសមត្ថភាពអាចារ្យឱ្យបាន៤០% បន្ថែមទៀតនៅឆ្នាំ២០១៥។

#### ២.៣.២.៦ គោលបំណងអភិវឌ្ឍន៍វិស័យស្ថានភាពអន្តោប្រវេសន៍ និងបម្លាស់ទី

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍លើវិស័យអន្តោប្រវេសន៍ និងបម្លាស់ទីដើម្បីកាត់បន្ថយចលនាចំណាកស្រុកមិនត្រឹមត្រូវ និងមានគ្រោះថ្នាក់ ខេត្តបានកំណត់នូវគោលបំណងរបស់ខ្លួនដូចខាងក្រោម៖

- ទប់ស្កាត់ការ ធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋឱ្យបាន០.៤៣%បន្ថែមទៀតនៅឆ្នាំ២០១៥
- ជំរុញការចូលរួមពីសង្គមស៊ីវិល និងអង្គការអភិវឌ្ឍន៍ជាដៃគូរក្នុងដែនសមត្ថកិច្ច ដើម្បីរួមចំណែកលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋតាមទីជនបទឱ្យបាន២០%បន្ថែមទៀតនៅឆ្នាំ២០១៥។

### ២.៣.៣ គោលបំណងអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

#### ២.៣.៣.១ គោលបំណងអភិវឌ្ឍន៍ ក្នុងការគ្រប់គ្រងដីធ្លី

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍នៃការគ្រប់គ្រងដីធ្លី ដោយការជំរុញ និងបង្កើនឲ្យមានការចុះបញ្ជីដីធ្លី រួមនឹងការកាត់បន្ថយវិវាទដីធ្លី ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យគ្រប់គ្រងដីធ្លីរបស់ខ្លួនដូចខាងក្រោម៖

- បង្កើនការចុះបញ្ជីដីធ្លី ជាលក្ខណៈប្រព័ន្ធ និងដាច់ដោយដុំ ឲ្យបាន៤០%បន្ថែមទៀតនៅឆ្នាំ២០១៥។
- កាត់បន្ថយ វិវាទដីធ្លីឲ្យបាន៣០% បន្ថែមទៀតនៅឆ្នាំ២០១៥។

#### ២.៣.៣.២ គោលបំណងអភិវឌ្ឍន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ក្នុងការជំរុញឲ្យប្រជាពលរដ្ឋ មានការយល់ដឹងបន្ថែមពីការថែរក្សាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យគ្រប់គ្រងធនធានធម្មជាតិរបស់ខ្លួន ដូចខាងក្រោម៖

- លើកកម្ពស់ការគ្របគ្រងធនធានធម្មជាតិនិងបរិស្ថានដោយមានប្រជាពលរដ្ឋចូលរួមថែរក្សា និងអភិរក្សឱ្យបាន៥០%បន្ថែមនៅឆ្នាំ២០១៥។
- ជំរុញការគ្រប់គ្រងកាកសំណល់ឱ្យបាន៤០% បន្ថែមទៀតនៅឆ្នាំ២០១៥។

#### ២.៣.៣.៣ គោលបំណងអភិវឌ្ឍន៍ក្នុងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ក្នុងការធ្វើឲ្យប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ យល់ដឹងបន្ថែមពីការការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍវិស័យគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយរបស់ខ្លួនដូចខាងក្រោម៖

- ជំរុញការចូលរួមថែរក្សា និងគ្រប់គ្រងបរិស្ថានរបស់ប្រជាពលរដ្ឋ និងការបន្សាំខ្លួននឹងការប្រែប្រួលអាកាសធាតុ និងគ្រប់គ្រងគ្រោះមហន្តរាយឱ្យបាន៨០%បន្ថែមទៀតនៅឆ្នាំ២០១៥

### ២.៣.៤ គោលបំណងអភិវឌ្ឍន៍ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

#### ២.៣.៤.១ គោលបំណងអភិវឌ្ឍន៍ការគ្រប់គ្រងដែនដី ការងារអភិបាលកិច្ចល្អ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ក្នុងការគ្រប់គ្រងដែនដី និងការងារអភិបាលកិច្ចល្អក្នុងការធ្វើឱ្យប្រជាពលរដ្ឋទទួលបានសេវាសាធារណៈកាន់តែល្អប្រសើរ ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍនៃការគ្រប់គ្រងដែនដី និងការងារអភិបាលកិច្ចល្អរបស់ខ្លួនដូចខាងក្រោម៖

- បង្កើនការងាររដ្ឋបាលសាលាខេត្ត ក្រុង ស្រុកទាំង៨ និងជំរុញការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបាន៨០%បន្ថែមទៀតនៅឆ្នាំ២០១៥។

#### ២.៣.៤.២ គោលបំណងអភិវឌ្ឍន៍ការងារគ្រប់គ្រងស្ថិតិ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍លើការងារគ្រប់គ្រងស្ថិតិ ក្នុងការធ្វើឲ្យមានភាពប្រសើរឡើង នៃការងារគ្រប់គ្រងស្ថិតិ ការរៀបចំកិច្ចការចុះអត្រានុកូលដ្ឋាន និងការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ខេត្តបានកំណត់នូវគោល បំណងខាងការអភិវឌ្ឍនៃ ការងារគ្រប់គ្រងស្ថិតិរបស់ខ្លួនដូចខាងក្រោម៖

- រៀបចំកិច្ចការចុះអត្រានុកូលដ្ឋាន និងជំរុញការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋដែលហួសសុពលភាពឱ្យបាន១៥% បន្ថែមទៀតនៅឆ្នាំ២០១៥។

#### ២.៣.៤.៣ គោលបំណងអភិវឌ្ឍន៍ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍លើការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងការកាត់បន្ថយបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងកង្វះខាតលើការគ្រប់គ្រងស្ថិតិជាអតិប្បរមា ខេត្តបានកំណត់នូវគោលបំណងខាងការអភិវឌ្ឍនៃការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈរបស់ខ្លួនដូចខាងក្រោម៖

- កាត់បន្ថយបញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឱ្យបាន១០%បន្ថែម ឬជាអតិប្បរិមានៅឆ្នាំ២០១៥។

## ២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍

### ២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច

### ២.៤.១.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម

ដើម្បីសម្រេចឲ្យបាននូវគោលដៅ និងគោលបំណងក្នុងផ្នែកសេដ្ឋកិច្ចលើវិស័យកសិកម្ម គឺការបង្កើនទិន្នផលស្រូវពី២.៦០តោន/ហ.ត ឡើងដល់៣.១០តោន/ហ.ត ទប់ស្កាត់បញ្ហាអសន្តិសុខស្បៀង និងការជំរុញការនាំចេញអង្ករទៅការទីផ្សារបរទេស តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១៥ ខេត្តបានសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រត្រូវអនុវត្តមានដូចជា៖

- បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែតាមបែបប្រពលវប្បកម្មដំណាំស្រូវ
- ជំរុញការស្តារប្រព័ន្ធស្រោចស្រពការជីកប្រឡាយថ្មីដើម្បីជួយសំរួលជូនប្រជាកសិករ
- បើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសសន្សំជីធម្មជាតិ និងធ្វើជីកំប៉ុស្តិ៍
- ជំរុញការដាំដំណាំឆ្លាស់ទៅតាមប្រភេទដី ធ្វើយ៉ាងណាបង្កើនគុណភាពដី
- ទប់ស្កាត់ការដុតជញ្ជ្រាំង ដោយបង្វែរទៅជាសកម្មភាពភ្ជួរលុបគល់ជញ្ជ្រាំងវិញ
- បើកវគ្គផ្សព្វផ្សាយអំពីថ្នាំពុល ផលប៉ះពាល់ និងជីគីមីដែលមានគុណភាពដែលបានចុះបញ្ជីពីស្ថាប័នរដ្ឋ
- បើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសប្រើប្រាស់ថ្នាំ និងជីគីមីកសិកម្ម
- ពង្រឹងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយដល់ភ្នាក់ងារកសិកម្មថ្នាក់ខេត្ត ស្រុក ក្រុង ឃុំ សង្កាត់
- ជំរុញ និងលើកទឹកចិត្តកសិករក្នុងក្រុមផលិតកម្មកសិកម្ម
- ចងក្រងក្រុមកសិករអ្នកផលិតពូជស្រូវ និងស្វែងរកទីផ្សារសម្រាប់កសិផល
- បណ្តុះបណ្តាលបច្ចេកទេសបន្សុទ្ធពូជ
- វគ្គបច្ចេកទេសជីវិតដី

បង្កើនសកម្មភាពផលិតកម្មដំណាំស្រូវ សម្រាប់ការនាំអង្ករចេញ ឲ្យបានចំនួន២០,០០០តោនក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- លើកកម្ពស់ការវិនិយោគផ្នែកឯកជនក្នុងការបង្កើតម៉ាស៊ីនកិនស្រូវ
- បណ្តុះបណ្តាលបច្ចេកទេសប្រមូលផល និងការទុកដាក់ស្រូវអង្ករ
- ផ្តល់ការលើកទឹកចិត្តដល់អ្នកវិនិយោគឯកជន ក្នុងការវិនិយោគវិស័យកសិកម្ម
- ចងក្រងក្រុមធនាគារស្រូវក្នុងគោលបំណងជំរុញការលើកកម្ពស់តម្លៃស្រូវលើទីផ្សារជាតិ

ជំរុញដល់សកម្មភាពផលិតកម្ម និងបសុសត្វ ខេត្តមានគោលបំណងបង្កើនការចិញ្ចឹមសត្វពី០.២៩% ឲ្យឡើងដល់២០% នៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រ ត្រូវអនុវត្តមានដូចជា ៖

- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ

- ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ
- បង្កើតទីផ្សារសម្រាប់ផលពីការចិញ្ចឹម សត្វ និងកសិផលទូទៅ
- ជំរុញការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងលក្ខណៈកសិដ្ឋាន
- លើកទឹកចិត្តដល់អ្នកវិនិយោគឯកជន ដើម្បីបង្កើតសហគ្រាសផលិតចំណីសត្វ

ជំរុញដល់សកម្មភាពវារីវប្បកម្ម និងមច្ឆជាតិ ខេត្តមានគោលបំណងបង្កើនការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ និងសម្រាប់ទីផ្សារឲ្យបានកើនពី១.៥% ឲ្យឡើងដល់៤០% នៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្រ្តត្រូវអនុវត្តមានដូចជា៖

- ផ្សព្វផ្សាយច្បាប់ជលផល
- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី
- ផ្តល់ពូជត្រីដែលមានគុណភាព
- ទប់ស្កាត់នូវបទល្មើសនេសាទ និងដកហូតឧបករណ៍ នេសាទខុសច្បាប់
- ជំរុញអ្នកវិនិយោគខ្នាតតូចសម្រាប់របរចិញ្ចឹមត្រី
- អភិរក្ស និងអភិវឌ្ឍជម្រកត្រីតាមស្រះ និង តាមបឹងធម្មជាតិនានា ក្នុងខេត្ត

បង្កើនផ្ទៃដីដាំដុះបន្លែ និងដំណាំរួមផ្សំ ខេត្តមានគោលបំណង បង្កើនផ្ទៃដីដាំដុះពី០.៣២% ដល់២៥ % នៅក្នុងឆ្នាំ២០១៥ ដែលតម្រូវឲ្យមានយុទ្ធសាស្រ្តត្រូវអនុវត្តដូចជា៖

- បណ្តុះបណ្តាល បច្ចេកទេសដាំដំណាំ និងបន្លែសរីរាង្គ
- ស្វែងរកទីផ្សារសម្រាប់ផលដំណាំកសិករ
- ជំរុញការសង់ ស្តារ និងជីកនូវប្រព័ន្ធស្រោចស្រព
- រៀបចំទីផ្សារសម្រាប់កសិកម្ម និង ផលិតផលនានាក្នុងខេត្ត
- ចងក្រងកសិករជាសហគមន៍ជាសមាគមជួយខ្លួនឯង
- ផ្តល់ឥណទានដល់កសិករដើម្បីជំរុញការផលិតដំណាំរួមផ្សំ
- ជំរុញការដាំដុះតាមតំបន់ដែលអំណោយផលដល់ប្រភេទដំណាំនីមួយៗ

### ២.៤.១.២- យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យធនធានទឹក

ដើម្បីសម្រេចឲ្យបាននូវគោលដៅ និងគោលបំណងក្នុងផ្នែកសេដ្ឋកិច្ច លើវិស័យធនធានទឹកគឺការធានានូវប្រភពទឹកប្រើប្រាស់ សម្រាប់កាងារកសិកម្ម និងមានទឹកស្អាតប្រើប្រាស់បាន ១៧% បន្ថែមទៀតក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្រ្តត្រូវអនុវត្តមានដូចជា៖

- ជំរុញការជីក និងស្តារប្រព័ន្ធស្រោចស្រពដែលមានស្រាប់ទូទាំងខេត្ត
- ធ្វើការជួសជុល និង សង់សំណង់ធារាសាស្រ្តតាមសណ្តាស្ទឹងតូច និងស្ទឹងព្រែកត្នោត
- រៀបចំបង្កើតឲ្យមានស្ថានីយ៍បូមទឹកនិងផ្តល់ម៉ាស៊ីនបូមទឹកខ្នាតធំសម្រាប់អន្តរាគមន៍ពេល

មានគ្រោះរាំងស្ងួត

- ចងក្រងសហគមន៍ប្រើប្រាស់ទឹក
- ជួសជុលសណ្តារស្ទឹងព្រែកត្នោត និងសណ្តារស្ទឹងតូច
- រៀបចំស្រះ បឹង អាងទឹក រណ្តៅខ្សាច់ធំៗ ធ្វើជាប្រភពទឹកបន្ថែម
- ធ្វើបញ្ជីបច្ចុប្បន្នភាពអាងស្តុងទឹកអាង ទំនប់ទឹក និងប្រឡាយស្រោចស្រព

### ២.៤.១.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសាធារណៈការ និងដឹកជញ្ជូន

ដើម្បីសម្រេចឲ្យបាននូវគោលដៅ និងគោលបំណងក្នុងផ្នែកសេដ្ឋកិច្ច លើវិស័យសាធារណៈការ ផ្លូវលំជនបទទូទាំងខេត្តត្រូវបានថែទាំ និងជួសជុល២០%ក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រ ត្រូវអនុវត្តដូចជា៖

- បង្កើតគណៈកម្មាធិការគ្រប់គ្រង ថែទាំ និង ជួសជុលផ្លូវលំ
- បង្កើនវិធានការណ៍គ្រប់គ្រង ថែទាំ និង ជួសជុលផ្លូវឲ្យមានប្រសិទ្ធភាព
- ត្រួតពិនិត្យ និងតាមដាន សម្របសម្រួលការកសាងផ្លូវគ្រប់គំរោង រួមទាំងគំរោងរបស់ ឃុំ សង្កាត់ ក្រុង ស្រុក និងថ្នាក់ខេត្ត
- គៀងគរសប្បុរសជន ជួយជួសជុល និងកសាងផ្លូវសំខាន់ៗ
- ពង្រឹងប្រជាពលរដ្ឋឲ្យចូលរួមការពារ និងថែទាំផ្លូវក្នុងភូមិ ឃុំ សង្កាត់របស់ខ្លួន ។

### ២.៤.១.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហ៍កម្ម រ៉ែ និងថាមពល

លើវិស័យឧស្សាហកម្មរ៉ែ និង ថាមពល គោលបំណងរបស់ខេត្តគឺ អាជីវកម្មខ្សាច់ទាំងអស់ត្រូវបានគ្រប់គ្រងតាមបទដ្ឋាន និងបច្ចេកទេសឲ្យបាន១៥%បន្ថែមទៀតក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រត្រូវ អនុវត្តមានដូចជា ៖

- ណែនាំដល់ម្ចាស់អាជីវកម្មឲ្យអនុវត្តតាមបច្ចេកទេស
- ជំរុញការតាមដាន និងមានវិធានការណ៍ទប់ស្កាត់ ចំពោះករណីល្មើសក្នុង អាជីវកម្ម ខ្សាច់
- មានវិធានការណ៍ផាកពិន័យចំពោះការបទល្មើសនានាក្នុងអាជីវកម្មខ្សាច់
- កំណត់តំបន់ត្រូវធ្វើអាជីវកម្មខ្សាច់ឲ្យបានត្រឹមត្រូវ

ប្រជាពលរដ្ឋ នឹងមានអគ្គីសនីប្រើប្រាស់គ្រប់ៗផ្ទះ ក្នុងឆ្នាំ២០១៥ឱ្យបានដល់៥០%បន្ថែមទៀតនៅឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រត្រូវអនុវត្តដូចជា៖

- ជំរុញឲ្យផ្នែកឯកជនវិនិយោគបន្ថែមលើការតភ្ជាប់បណ្តាញអគ្គីសនី
- សំរបសំរួល និង បង្កលក្ខណៈងាយស្រួល ដល់សេវាករអគ្គីសនី
- ពង្រីកតំបន់អគ្គីសនីគ្រប់ស្រុក ក្រុង និងទីប្រជុំជនសំខាន់ៗ

ប្រជាពលរដ្ឋ នឹងមានបណ្តាញទឹកស្អាតប្រើប្រាស់គ្រប់ៗផ្ទះ នៅតំបន់សំខាន់ៗទូទាំងខេត្ត

ក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រត្រូវអនុវត្តដូចជា ៖

- ជំរុញឲ្យផ្នែកឯកជនវិនិយោគបន្ថែមលើការតភ្ជាប់ និង ពង្រីកបណ្តាញទឹកស្អាតឲ្យ បានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់មូលដ្ឋានពិសេសតំបន់ដាច់ស្រយាល។
- សំរបសំរួល និង បង្កលក្ខណៈងាយស្រួល ដល់សេវាករផ្គត់ផ្គង់ទឹកស្អាត
- ពង្រឹងជាប្រចាំអំពីគុណភាពទឹកស្អាត ការផ្តល់សេវារបស់អ្នកផ្គត់ផ្គង់នឹងរក្សាតម្លៃថេរឲ្យនៅសមរម្យ
- ជំរុញឲ្យម្ចាស់អាជីវករផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងច្បារមន សិក្សាតំបន់ទឹកស្អាតនៅលើតំបន់ដែលមានទឹកស្អាត។

### ២.៤.១.៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអភិវឌ្ឍន៍ជនបទ

គោលបំណងរបស់វិស័យអភិវឌ្ឍន៍ជនបទគឺ នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋទាំងអស់នឹងមានទឹកស្អាតប្រើប្រាស់ ព្រមទាំងរស់នៅក្របដោយអនាម័យខ្ពស់ ខេត្តមានយុទ្ធសាស្ត្រត្រូវអនុវត្តដូចជា៖

- ជួសជុលនិងជីកអណ្តូងដើម្បីឲ្យប្រជាពលរដ្ឋបានប្រើប្រាស់ទឹកស្អាតបានគ្រប់គ្រួសារ
- បើកវគ្គអប់រំអំពីការប្រើប្រាស់ទឹកស្អាត ហូបស្អាត អនាម័យរស់នៅល្អ
- បង្កើតឲ្យមានស្ថានីយ៍បន្សុទ្ធទឹកស្អាត
- បង្កើនការផ្តល់ធុងចំពោះទឹកស្អាត
- ជំរុញការត្រួតពិនិត្យធ្វើតេស្តរកសារជាតិអាសេនិច គ្រប់អណ្តូងទាំងអស់
- ជំរុញការសង់បង្គន់អនាម័យ
- បើកវគ្គផ្សព្វផ្សាយអប់រំអំពីការរស់នៅស្អាត
- រៀបចំទិវាអនាម័យលាងដៃកាត់ក្រចក រកទីចាក់សំរាមនិងការគ្រប់គ្រងកាកសំណល់
- ចងក្រងក្រុមកសិករប្រើប្រាស់ទឹកអណ្តូង
- ជំរុញឲ្យអ្នកមានច្បាប់ធ្វើអាជីវកម្មទឹកស្អាតពីក្រសួងឧស្សាហកម្មអនុវត្តគម្រោងរបស់ខ្លួន

### ២.៤.១.៦ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម

គោលបំណងរបស់វិស័យពាណិជ្ជកម្មគឺ គ្រប់អាជីវកម្មទាំងអស់ត្រូវបានគ្រប់គ្រង និងមានច្បាប់អនុញ្ញាតចំនួន៨០% បន្ថែមទៀត នៅឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រត្រូវអនុវត្តដូចជា៖

- ផ្សព្វផ្សាយអប់រំឲ្យអាជីវករទាំងអស់យល់អំពីនីតិវិធី និងទំរង់ផ្លូវច្បាប់នានាក្នុងរបត់សេដ្ឋកិច្ចទីផ្សារសេរី
- រៀបចំឲ្យមានទីផ្សារត្រឹមត្រូវ តាមបណ្តាស្រុកមួយចំនួន

- ជំរុញការចុះបញ្ជី និងធ្វើច្បាប់ពាណិជ្ជកម្ម
- ជំរុញឲ្យអាជីវករបិទតម្លៃមុខទំនិញលើទំនិញរបស់ខ្លួនគ្រប់ទីផ្សារក្នុងខេត្ត ។

### ២.៤.១.៧ យុទ្ធសាស្រ្តអភិវឌ្ឍន៍ការងារពន្ធដារ

ដើម្បីសម្រេចឲ្យបាននូវគោលបំណងលើ វិស័យពន្ធដារក្នុងឆ្នាំ២០១៥ ការប្រមូលពន្ធគ្រប់ប្រភេទ ត្រូវអនុវត្តបានត្រឹមត្រូវគ្រប់ប្រភពប្រមូលពន្ធ ខេត្តមានយុទ្ធសាស្រ្តត្រូវអនុវត្តដូចជា៖

- ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋ និងអាជីវករយល់ដឹងអំពីអត្ថប្រយោជន៍នៃកាតព្វកិច្ចការងារពន្ធដារ
- ផ្សព្វផ្សាយច្បាប់ពន្ធដារ ជូនអាជីវករគ្រប់អាជីវកម្មដ្ឋាន
- ផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ពន្ធលើអចលនទ្រព្យ
- ជ្រើសរើសមន្រ្តីពន្ធដារបន្ថែម ដើម្បីងាយស្រួលប្រតិបត្តិការប្រមូលពន្ធ
- ជំរឿនមូលដ្ឋានអាជីវកម្មក្នុងខេត្ត កំណត់ផលរបរឲ្យបានសមស្រប
- ការដាក់លិខិតប្រកាសរបស់អាជីវករ ប្រកាសបង់ប្រាក់ពន្ធឲ្យបានស្មោះត្រង់
- ផ្សព្វផ្សាយច្បាប់ពន្ធដារ ជូនអាជីវករគ្រប់អាជីវកម្មដ្ឋានឲ្យបានយល់
- រៀបចំឲ្យមានយន្តការថ្នាក់ខេត្តដើម្បីដោះស្រាយចំពោះវិវាទពាក់ព័ន្ធនឹងការងារពន្ធដារ
- ត្រៀមសហការអនុវត្តនៅពេលដែលច្បាប់សារពើពន្ធបានចេញ
- ជំរឿនមូលដ្ឋានអាជីវកម្មក្នុងខេត្ត កំណត់ផលរបរឲ្យបាន ១០០%

### ២.៤.១.៨ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យឯកជន

ដើម្បីសម្រេចឲ្យបាននូវគោលបំណងរបស់ខេត្ត ពាក់ព័ន្ធដល់វិស័យឯកជន ក្នុងឆ្នាំ ២០១៥ ការវិនិយោគ ផ្នែកវិស័យឯកជន ទៅលើរោងចក្រវាយនភ័ណ្ឌ បង្កើតឲ្យបាន១៥កន្លែងនិងសហគ្រាសធន់តូចនិងមធ្យម២២% បន្ថែមទៀតនៅឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្រ្តត្រូវអនុវត្តដូចជា ៖

- គៀងគរ និងបង្កលក្ខណ:ងាយស្រួលដល់វិស័យឯកជនក្នុងការចូលមកបោះទីតាំង និងធ្វើអាជីវកម្មនៅក្នុងខេត្ត
- បង្កើតនូវលក្ខខ័ណ្ឌស្របតាមនានាក្នុងកម្រិតវិនិយោគថ្នាក់ខេត្ត
- បង្កើតនូវក្រុមការងារអចិន្រ្តៃយ៍ដល់ក្រុមប្រឹក្សាខេត្ត ក្នុងកិច្ចការអភិវឌ្ឍន៍លើវិស័យឯកជន
- ជំរុញនូវសកម្មភាពវិនិយោគនានាពិសេសលើវិស័យកសិឧស្សាហកម្ម
- ផ្សព្វផ្សាយអំពីកិច្ចសហការរវាងវិស័យឯកជន និងអាជ្ញាធរមូលដ្ឋានគ្រប់គ្រងទិន្នន័យ និងស្ថិតិអាជីវកម្ម ដើម្បីយន្តការអនុវត្តច្បាប់នានា ពាក់ព័ន្ធនឹងវិស័យឯកជន។

### ២.៤.១.៩ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យទេសចរណ៍

ថ្វីត្បិតតែស្ថានភាពខេត្ត ជាតំបន់កសិកម្ម មានវាលស្រែធំល្វឹងល្វើយ តែខេត្ត មានរមណីយដ្ឋានទេសចរណ៍ធំៗចំនួន ០៥ កន្លែង ដែលជាកត្តាឲ្យខេត្ត រៀបចំពង្រឹងវិស័យទេសចរណ៍ធម្មជាតិ និងប្រវត្តិសាស្ត្របាន ដោយបានដាក់ចេញនូវគោលបំណងគឺ រមណីដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រ ឱ្យបាន១០% បន្ថែមទៀតទូទាំងខេត្តនៅឆ្នាំ២០១៥ខេត្តមានយុទ្ធសាស្ត្រ ត្រូវអនុវត្តដូចជា ៖

- ជំរុញឲ្យភូមិ ឃុំមានដែលមានទីតាំងសមស្របរៀបចំបង្កើតតំបន់ ទេសចរណ៍ធម្មជាតិ
- ផ្សព្វផ្សាយសក្តានុពលលើវិស័យទេសចរណ៍ របស់ខេត្តកំពង់ស្ពឺ ពិសេសតំបន់ទឹក ធ្លាក់ ចំបក់ ឧទ្យានជាតិគីរីរម្យ....
- រៀបចំបង្កើតឲ្យមានទេសចរណ៍សហគមន៍

### ២.៤.១.១០ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយជោគជ័យមន្ទីរបានជ្រើសរើសយកនូវយុទ្ធសាស្ត្រមួយចំនួនដើម្បីសម្រេចនិងស្ថេរភាពក្នុងការអភិវឌ្ឍន៍យូអង្វែងរួមមាន ៖

- ទំនាក់ទំនងល្អជាមួយអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្រុមហ៊ុនឲ្យបានជិតស្និទ្ធក្នុងការធ្វើគំរោងផែនការអភិវឌ្ឍន៍ វិស័យប.ទ
- ទំនាក់ទំនង និងបង្កលក្ខណះងាយស្រួលជាមួយក្រុមហ៊ុនឯកជន ដែលមានបំណងចង់វិនិយោគលើវិស័យ ប.ទ នៅក្នុងខេត្ត
- លើកគំរោងស្នើសុំថវិការពីរាជរដ្ឋាភិបាល និងបណ្តាអង្គការនានា ឲ្យគាំទ្រលើផែនការអភិវឌ្ឍន៍លើវិស័យប.ទ
- បង្កើនចំណេះដឹងជំនាញបន្ថែមដល់មន្ត្រីរាជការ ក្នុងមន្ទីរនៅក្រសួងនិងគ្រឹះស្ថាននានា
- សហការធ្វើការសិក្សាគំរោងជាមួយមន្ត្រីបច្ចេកទេសក្រសួង និងម្ចាស់ជំនួយដើម្បីលើកគម្រោង និងអភិវឌ្ឍន៍មជ្ឈមណ្ឌលប្រព័ន្ធទូរគមនាគមន៍ និងបណ្តាញខ្សែកាបអុបទិច ក្នុងទីរួមខេត្ត
- សហការជាមួយកងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ ដើម្បីធ្វើការត្រួតពិនិត្យលើការប្រើប្រាស់វិទ្យុទាក់ទងខុសច្បាប់
- សហការជាមួយក្រសួង មន្ទីរជំនាញ អាជ្ញាធរខេត្ត-ស្រុក ដើម្បីធ្វើគម្រោងសាងសង់អាគារការិយាល័យប.ទតាមបណ្តាស្រុកនិងបើកឲ្យតំណើរការនូវសេវាកម្មអាជីវកម្មប.ទ

## ២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

### ២.៤.២.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអប់រំ

ដើម្បីសម្រេចឲ្យបាននូវគោលបំណង កុមារតូចដែលមានអាយុ ៣ ទៅ ៥ ឆ្នាំ បានចូល រៀន

មត្តេយ្យសិក្សា កើនចំនួន២៩.០៩%ទៀតនៅឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រ ត្រូវអនុវត្តមានដូចជា៖

- បង្កើតថ្នាក់មត្តេយ្យក្នុងបឋមសិក្សាឲ្យបានដល់៥០%
- សហការជាមួយអាជ្ញាធរភូមិ ឃុំ សង្កាត់ ដៃគូរអភិវឌ្ឍន៍បើកថ្នាក់មត្តេយ្យសិក្សា សហគមន៍ កម្មវិធីអប់រំកុមារតូចតាមផ្ទះ និងគាំទ្រ ឲ្យមានដំណើរការ
- ប្រជុំផ្សព្វផ្សាយពីគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍ កុមារតូចតាម តំបន់ដែលមិនទាន់បានអនុវត្ត និងជំរុញការរៀបចំបរិស្ថានក្នុង និងក្រៅថ្នាក់មត្តេយ្យរដ្ឋ និង សហគមន៍
- បង្កើត និងពង្រឹងសាលាមត្តេយ្យរដ្ឋ ឲ្យមានគ្រប់ឃុំ និងមានគ្រូ និងថ្នាក់រៀនគ្រប់ គ្រាន់
- រៀបចំលើកទឹកចិត្តឲ្យមានមត្តេយ្យសហគមន៍ ឲ្យបាន ១/៣ នៃចំនួនភូមិ ទូទាំង ខេត្ត ដោយជ្រើសរើសឲ្យមានគ្រូមត្តេយ្យសហគមន៍ និងទីកន្លែងសមរម្យ
- បណ្តុះបណ្តាលអ្នកគ្រូមត្តេយ្យរដ្ឋ សហគមន៍បន្ថែម និងបើកវគ្គបំប៉នសមត្ថភាពបច្ចេកទេសបង្រៀនជូនគ្រូមត្តេយ្យ
- សហការជាមួយអាជ្ញាធរដែនដីស្រង់ ពិនិត្យផ្ទៀងផ្ទាត់ស្ថិតិកុមារអាយុ៣-៥ឆ្នាំតាមភូមិ

ដើម្បីសម្រេចឲ្យបាននូវគោលបំណង កុមារទាំងអស់ ទទួលបានការអប់រំមូលដ្ឋានថ្នាក់ទី៩ ដោយគុណភាព មធ្យមសិក្សាបឋមភូមិកើនចំនួន២៣.៨%ទៀតនៅឆ្នាំ២០១៥ខេត្តមានយុទ្ធសាស្ត្រត្រូវអនុវត្តដូចជា ៖

- មតេយ្យសិក្សា បឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ ត្រូវមានអាគារសិក្សាបន្ទប់ រៀន និង បុគ្គលិកសិក្សា គ្រប់គ្រាន់ ទៅតាមនិយាមគរុកោសល្យ ។
- ធ្វើឲ្យសាលាបឋមសិក្សាទាំងអស់ ក្លាយជាសាលាកុមារមេត្រី តាមរយៈការផ្សព្វផ្សាយ គោលនយោបាយកម្មវិធីសាលាកុមារមេត្រី ដល់អ្នកពាក់ព័ន្ធនានា
- បង្រៀន និងរៀនឲ្យបានត្រឹមត្រូវតាមកម្មវិធីដែលបានគ្រោងទុក
- ពង្រឹងភាពជាដៃគូ ជាមួយអ្នកពាក់ព័ន្ធនានា សម្រាប់គាំទ្រ ពង្រឹងការងារអប់រំ
- ផ្សព្វផ្សាយគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និង ធ្វើយុទ្ធនាការប្រមូលកុមារចូល រៀន
- ពង្រឹងការតាមដាន ការរៀន និងបង្រៀនឲ្យបានត្រឹមត្រូវតាមស្តង់ដារកំណត់ និងត្រួត ពិនិត្យជាប្រចាំ
- លើកកម្ពស់គុណធម៌ដល់បុគ្គលិកសិក្សា ជាមួយនឹងស្មារតីស្រលាញ់វិជ្ជាជីវៈ
- ជំរុញការបង្រៀនដោយប្រើប្រាស់កិច្ចតែងការបង្រៀន ការរៀបចំផលិតសម្ភារៈ ឧបទេស តាមមេរៀនតាមមុខវិជ្ជាតាមខែ
- ស្រង់ផ្ទៀងផ្ទាត់ស្ថិតិកុមារដល់វ័យសិក្សាក្នុងផែនទីខ្នងផ្ទះរបស់សាលារៀន

- ពង្រឹងក្រុមបណ្តាញតាមភូមិឲ្យជួយជំរុញមាតា បិតានាំកូនមកចុះ ឈ្មោះ
- ជ្រើសរើសសិស្សក្រីក្រទទួលអាហាររូបករណ៍ពិសេស សិស្សស្រី
- បង្កើតកម្មវិធីអាហារពេលព្រឹកតាមសាលាគោលដៅ
- បង្កើតថ្នាក់ពន្លឿនការសិក្សា,ថ្នាក់អប់រំបញ្ចូលគ្នានិងបង្កើតថ្នាក់ឆ្លងកាត់
- សង់អាគារបន្ថែមចំពោះសាលាខ្វះបន្ទប់រៀន និងផ្សព្វផ្សាយដល់សាលារៀន និងសហគមន៍ពីការហូបទឹកស្អាត និងការប្រើប្រាស់បង្គន់អនាម័យ
- បង្កើនកិច្ចសហការល្អជាមួយមន្ទីរពាក់ព័ន្ធនិងអង្គការនានា
- ពង្រឹងក្រុមប្រឹក្សាកុមារផ្នែកអនាម័យឲ្យយល់ពីតួនាទីភារកិច្ច
- ជំរុញឲ្យប្រើប្រាស់សម្ភារៈ ឧបទេសស្របតាមខ្លឹមសារមេរៀននិងផ្តល់សៀវភៅសិក្សាគោលឲ្យបានគ្រប់គ្រាន់តាមនិយាមប្រើប្រាស់
- ប្រជុំមាតាបិតាសិស្សពីលទ្ធផលការសិក្សារបស់កូននិងផ្តល់បទពិសោធន៍ចំពោះកូនដែលរៀនពូកែនិងបង្កើតកម្មវិធីទស្សនៈកិច្ចសិក្សារបស់មាតាបិតាសិស្សនៅសាលារៀន
- គ្រូត្រូវធ្វើកម្មវិធីសិក្សាលំអិតប្រចាំសប្តាហ៍ ខែ ត្រីមាស និងអនុវត្តវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល
- ពិនិត្យតាមដាន និងលើកទឹកចិត្តសិស្សពូកែ និងគ្រូមានស្នាដៃក្នុងការរៀនការបង្រៀនឲ្យបានញឹកញាប់
- ពង្រឹងបណ្តាញសិស្សតាមភូមិឲ្យអនុវត្តសកម្មភាពតាម តួនាទី
- រៀបចំបរិស្ថានសាលារៀនថ្នាក់រៀនឲ្យបានស្អាត និងផ្តល់ពត៌មានទៅវិញទៅមកជាមួយសហគមន៍ឲ្យបានជាប្រចាំ
- ផ្តល់សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាគ្រប់កម្រិតថ្នាក់ឲ្យបានគ្រប់ និងទាន់ពេលវេលាបំប៉ននសមត្ថភាពដល់ប្រធានក្រុមបច្ចេកទេស លើកកម្មវិធីសិក្សាថ្មី
- ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រជាពិសេសសិស្សស្រី
- បង្កើតអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ
- ពង្រីកអនុវិទ្យាល័យទៅជាវិទ្យាល័យនៅកន្លែងដែលមានសិស្សច្រើនកុះករ

ដើម្បីសម្រេចឲ្យបាននូវគោលបំណង ប្រជាពលរដ្ឋអាយុពី១៥ទៅ៦០ឆ្នាំ ឆ្លងផុតអនក្ខរភាពកើនបាន២%ទៀតនៅឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចតទៅ៖

- សហការជាមួយអាជ្ញាធរ ជំរុញសកម្មភាពថ្នាក់អក្ខរកម្មនៅតាមមូលដ្ឋាន និងផ្សព្វផ្សាយដល់អក្ខរជន
- ផ្សព្វផ្សាយ អប់រំអំពីតួនាទីភារកិច្ច និងអត្ថប្រយោជន៍ ក្នុងការចូលរួមរបស់គ្រួសារ

សហគមន៍ក្នុងការងារអប់រំ

- បង្កើតថ្នាក់អក្ខរកម្មតាមភូមិដែលមានអនក្ខរជនច្រើន និងជ្រើសរើសគ្រូអក្ខរកម្មជាប់កិច្ចសន្យាតាមភូមិ
- បណ្តុះបណ្តាលគ្រូអក្ខរកម្ម និងផ្តល់សម្ភារៈទ្រទ្រង់ថ្នាក់អក្ខរកម្ម
- ស្រងទិន្នន័យពត៌មានអនក្ខរជនតាមភូមិ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃជា ប្រចាំ
- ស្រង់ទិន្នន័យបោះបង់តាមសាលារៀន និងធ្វើបញ្ជីឈ្មោះសិស្សបោះបង់ដែលត្រូវមករៀនវិញក្នុងកម្មវិធីចូលរៀនឡើងវិញ
- បំប៉នគ្រូដែលត្រូវបំប៉នសិស្ស ដំណើរការបំប៉នសិស្សក្នុងខែសីហា និងកញ្ញារៀងរាល់ឆ្នាំ
- បើកថ្នាក់បំពេញវិជ្ជាតាមកម្មវិធីសមមូលនិងបង្កើតមជ្ឍមណ្ឌលអាននិងសិក្សាតាមឃុំ
- បង្កើតមជ្ឍមណ្ឌលបំនិនជិវិត និងជ្រើសរើសជំនាញតាមតំរូវការអ្នករៀន និងទីផ្សារ
- បំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រង និងសហគមន៍ពីមជ្ឍមណ្ឌលសិក្សាសហគមន៍
- តាមដានត្រួតពិនិត្យ និងវាយតំលៃលទ្ធផលអនុវត្ត

## ២.៤.២.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសុខាភិបាល

ដើម្បីសម្រេចគោលបំណងរបស់វិស័យសុខាភិបាល កាត់បន្ថយអត្រាមរណៈភាពមាតា និងទារកឲ្យបានពី១៥% មក៩%នៅក្នុងឆ្នាំ២០១៥ និងសម្រេចបានគោលបំណងលើវិស័យសុខាភិបាលលើកកម្ពស់សុខភាពមាតា និងទារក និងអនាម័យរស់នៅយុទ្ធសាស្ត្ររបស់ខេត្ត គឺ៖

- បើកវេទិកាអប់រំផ្សព្វផ្សាយសុខភាពមាតា និងទារក
- បង្កើនការអប់រំផ្សព្វផ្សាយដល់ស្ត្រីក្នុងការពិនិត្យផ្ទៃពោះឲ្យបានគ្រប់ចំនួន
- ផ្តល់អាហារូបត្ថម្ភដល់កុមារ
- ជំរុញការចាក់ថ្នាំបង្ការដល់កុមារឲ្យបានអស់
- ជំរុញការសង់អណ្តូងទឹកស្អាត
- សង់បង្គន់អនាម័យ
- បើកវគ្គបណ្តុះបណ្តាលដល់ភ្នាក់ងារអនាម័យភូមិ
- ជំងឺឆ្លង ជំងឺរបេងនឹងគ្មានកើតឡើង អ្នកជំងឺត្រូវបានព្យាបាលជាដាច់១០០% នៅក្នុងឆ្នាំ ២០១៥ យុទ្ធសាស្ត្ររបស់ខេត្តគឺ
- បើកវគ្គអប់រំផ្សព្វផ្សាយដល់អ្នកកើតជម្ងឺរបេងថ្មី និង អ្នកសង្ស័យមកពិនិត្យព្យាបាល នៅមណ្ឌលសុខភាព
- ផ្សព្វផ្សាយអំពីជំងឺគ្រុនផ្តាសាយបក្សី និង វិធានការណ៍ការពារ
- រៀបចំឲ្យមានផែនការចាក់ថ្នាំបង្ការ និងព្យាបាល

### ២.៤.២.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យយេនឌ័រ និងសិទ្ធិមនុស្ស

ដើម្បីសម្រេចបានការលើកកម្ពស់ សមភាពយេនឌ័រ ការលើកកម្ពស់តម្លៃស្ត្រីក្នុងសង្គមខ្មែរ គោរពសិទ្ធិ មនុស្ស និងកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ខេត្តមានយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ
- បណ្តុះបណ្តាលអំពីទស្សនៈយេនឌ័រ តួនាទីភារកិច្ចដល់ក្រុមការងារ យេនឌ័រខេត្ត ស្រុក ក្រុង និងប្រជាពលរដ្ឋគ្រប់ជាន់ ថ្នាក់
- រៀបចំទិវាអន្តរជាតិនារី ៨មីនា នៅតាមបណ្តាស្រុក-ក្រុង ទាំង៨ រៀងរាល់ឆ្នាំ
- ពង្រឹងសមត្ថភាពស្ត្រីតាមរយៈវគ្គបណ្តុះបណ្តាលស្តីពី តួនាទីភារកិច្ចដល់សមាជិការ ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈអភិបាលខេត្ត ក្រុង ស្រុក ស្ត្រីជាមេភូមិព្រមទាំងអ្នកទទួលបន្ទុកកិច្ចការនារី កុមារ ឃុំ សង្កាត់ផងដែរ
- រៀបចំវេទិការពិភាក្សាដល់អ្នកទទួលបន្ទុកការងារស្ត្រី កុមារឃុំ សង្កាត់ និងអ្នកដឹកនាំភូមិជាស្ត្រី ដើម្បីបង្កើនសមត្ថភាពអង្គអាចក្លាហានបំពេញការងារ
- រៀបចំកិច្ចប្រជុំនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ក្រុងជាមួយក្រុមការងារយេនឌ័រខេត្ត ស្រុកក្រុង និងដៃគូរអភិវឌ្ឍន៍ពាក់ព័ន្ធនានា(៣លើក/ឆ្នាំ) ដើម្បីពិនិត្យលើគំរោងអាទិ ភាពយេនឌ័របានលើកឡើងក្នុងពេលកសាងកម្មវិធីវិនិយោគនៅតាមឃុំ-សង្កាត់ស្រុកក្រុង មន្ទីរជុំវិញខេត្ត
- ចុះត្រួតពិនិត្យសកម្មភាពឆ្លើយតបបញ្ហាស្ត្រី និងកុមារនៅតាមឃុំ-សង្កាត់ ស្រុក ក្រុង មន្ទីរនានា ដើម្បីធ្វើការវាយតំលៃប្រសិទ្ធិ ភាពក្នុងការបញ្ជ្រាបយេនឌ័រ
- ប្រជុំប្រចាំឆ្នាំដើម្បីធ្វើការបូកសរុបលទ្ធផលនៃការងារបញ្ជ្រាបយេនឌ័រ និងលើក ទិសដៅ សម្រាប់អនុវត្តបន្តបន្ទាប់
- ចុះអប់រំផ្សព្វផ្សាយពីសេវាសុខភាព និង ផ្សព្វផ្សាយពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងរៀបចំទិវាសិទ្ធិមនុស្ស
- ផ្សព្វផ្សាយសេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្សឲ្យបានទូលំទូលាយ។
- បើកវគ្គផ្សព្វផ្សាយពីវិធានការនៃការពន្យាកំណើត និង ច្បាប់ប្រឆាំងជួញដូរស្ត្រី និង កុមារ
- បើកវគ្គផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងបណ្តុះបណ្តាល មុខជំនាញដល់ស្ត្រីមេគ្រួសារ ផ្តល់ឱកាសក្នុងការចូលរួមគ្រប់សកម្មភាព និង អាជីព
- រៀបចំវេទិការអប់រំលុបបំបាត់រាល់រូបភាព និងសកម្មភាពរើងអើងនានាលើស្ត្រី និងកុមារ
- ជំរុញ និងបង្កលក្ខណៈឲ្យស្ត្រីមានលទ្ធភាពចូលរួមក្នុងសង្គម
- ជំរុញលើកទឹកចិត្តឲ្យស្ត្រីបានចូលទៅបំពេញតួនាទីភារកិច្ច និងការសម្រេចចិត្ត ក្នុងអង្គការ

ចាត់តាំងនានាឲ្យបាន១៥% ។

### ២.៤.២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍កាត់បន្ថយភាពក្រីក្រ

ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រក្នុងខេត្ត ឲ្យបាន០៦ % ក្នុងឆ្នាំ២០១៥ខេត្ត មានយុទ្ធសាស្ត្រ ដូចខាងក្រោម ៖

- ជំរុញកិច្ចអភិវឌ្ឍន៍ឲ្យបានជោគជ័យ ដោយសមធម៌ ធានាបាននូវប្រសិទ្ធិភាពតម្លាភាព គណនេយ្យភាព ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍របស់ខេត្ត
- យុទ្ធសាស្ត្រ និងសូចនាករសំខាន់ៗ ដែលថ្នាក់ជាតិបានដាក់ចុះ ត្រូវបានអនុវត្តប្រកបដោយការទទួលខុសត្រូវ
- គៀងគរដៃគូរអភិវឌ្ឍន៍នានា ក្នុងខេត្តដើម្បីជួយគាំទ្រដល់ដំណើរការអនុវត្តគម្រោងពិសេសជួយ គម្រោងដែលជួយដល់ជនក្រីក្រ និងក្រុមងាយរងគ្រោះ
- ជំរុញគៀងគរ ដល់អ្នកវិនិយោគឯកជន ដើម្បីចូលរួមវិនិយោគក្នុងគោលបំណងបង្កើនការងារធ្វើ ជូនប្រជាពលរដ្ឋក្រីក្រ ។
- ជំរុញបើកវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញ និងបំនិនជីវិតជូនប្រជាកសិករក្នុងខេត្ត
- គាំទ្រដំណើរការ និងស្វែងរកទីផ្សារ ផលិតផលកសិកម្មជូនប្រជាកសិករក្នុងមូលដ្ឋានខេត្ត។

### ២.៤.២.៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធម្មការ និងសាសនា

ដើម្បីសម្រេចគោលបំណងរបស់វិស័យធម្មការ និងសាសនាខេត្តនៅក្នុងឆ្នាំ២០១៥ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- បង្កើតសាលាពុទ្ធិកសិក្សាកម្រិតបឋម១៨កន្លែង មធ្យមសិក្សាបឋមភូមិ៥កន្លែង និងមធ្យមសិក្សាទុតិយភូមិ១កន្លែង
- ជ្រើសរើសវត្តដែលមានលទ្ធភាព ឲ្យបង្កើតសាលាផ្នែកពុទ្ធសាសនា តាមការគ្រោងទុក
- ជ្រើសរើសគ្រូក្របខ័ណ្ឌ និងក្រៅក្របខ័ណ្ឌរដ្ឋតាមគោលការរបស់ក្រសួងធម្មការ និងសាសនា
- បង្កើតឲ្យមានមូលនិធិទ្រទ្រង់សាលាពុទ្ធិកសិក្សានៅគ្រប់កម្រិត
- រៀបចំ និងតែងតាំងមន្ត្រីសង្ឃឲ្យបានគ្រប់ចំនួនកំណត់តាមរចនាសម្ព័ន្ធ

### ២.៤.២.៦ យុទ្ធសាស្ត្រអភិវឌ្ឍន៍កាត់បន្ថយអន្តោប្រវេសន៍ និងចំណាកស្រុក

ដើម្បីសម្រេចគោលបំណងលុបបំបាត់ចំណាកស្រុក  នៅក្នុងឆ្នាំ២០១៥ខេត្តមានយុទ្ធសាស្ត្រដូចជា ៖

- អប់រំផ្សព្វផ្សាយអំពីគ្រោះថ្នាក់ នៃការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅទីក្រុង

- គៀងគរអ្នកវិនិយោគទុនមកបណ្តាក់ទុនរកស៊ីនៅក្នុងខេត្ត ដើម្បីបង្កើនមុខរបរ និងការ ងារ
- ស្នើសុំដល់អង្គភាព ក្រសួងស្ថាប័នរដ្ឋ និងគ្រប់ផ្នែកពាក់ព័ន្ធ ដើម្បីគាំទ្រនិងផ្តល់លទ្ធភាព ការងារដល់អ្នកមូលដ្ឋានក្នុងខេត្ត សម្រាប់ការងារក្នុងខេត្ត
- ផ្សព្វផ្សាយអំពីវិធីសាស្រ្តនានា ក្នុងការស្វែងរកការងារធ្វើ និងការចំណាកស្រុកប្រកប ដោយសុវត្ថិភាព

### ២.៤.២.៧ យុទ្ធសាស្រ្តផ្សេងៗទៀតដែលពាក់ព័ន្ធ និងស្ថានភាពសង្គមកិច្ច

ដើម្បីសម្រេចគោលបំណងរបស់វិស័យសង្គមកិច្ចគ្រប់គ្រង និងផ្តល់ជំនាញវិជ្ជាជីវៈដល់ជនគោលដៅ និងគ្រួសារពលីមរណៈពិការ អ្នកកើតជំងឺអេដស៍ បានលទ្ធផលតាមគោលដៅនៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្រ្តដូចជា៖

- បណ្តុះបណ្តាលជំនាញវិជ្ជាជីវដល់គ្រួសារយុទ្ធជនពលីពិការមរណៈ និងដល់និវត្តជន
- បង្កើតសមាគមយុទ្ធជនពលី ពិការ មរណៈ និង និវត្តន៍ជនតាមមូលដ្ឋាន
- បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់អ្នកជំងឺអេដស៍
- បើកវគ្គអប់រំផ្សព្វផ្សាយអប់រំលុបបំបាត់ ការរើសអើងអ្នកផ្ទុក និងអ្នកកើតជម៉ឺអេដស៍
- បើកវគ្គផ្សព្វផ្សាយអប់រំអំពីវិធានការណ៍ការពារឆ្លងអេដស៍

### ២.៤.២.៨ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យវប្បធម៌

ដើម្បីសម្រេចឲ្យបាននូវគោលបំណងលើវិស័យវប្បធម៌ ក្នុងការអភិរក្ស និងអភិវឌ្ឍន៍វិស័យវប្បធម៌ ទប់ស្កាត់ការហូរចូលនូវវប្បធម៌ពាលាអាវ៉ាសែ ខេត្តមានយុទ្ធសាស្រ្ត ដូចជា ៖

- អភិរក្សនិង ថែទាំ តំបន់ទេសចរណ៍ និង ទីទួលបុរាណ
- ជំរុញការចុះបញ្ជីសុរិយោដីតំបន់ទេសចរណ៍ធម្មជាតិ និង ប្រវត្តិសាស្រ្ត
- ទំនាក់ទំនងរកការវិនិយោគពីវិស័យឯកជន
- បើកវគ្គផ្សព្វផ្សាយច្បាប់ការពារបេតិកភណ្ឌជាតិ
- រៀបចំគោលនយោបាយ លើកទឹកចិត្ត ក្នុងការរក្សាទួលបុរាណឲ្យគង់វង្ស
- អប់រំផ្សព្វផ្សាយតាមសាលារៀន វត្តអារាម វិទ្យុ ទូរទស្សន៍ ។

## ២.៤.៣ យុទ្ធសាស្រ្តនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ដើម្បីសម្រេចនូវចក្ខុវិស័យគោលដៅ និងគោលបំណងរបស់ខ្លួនដោយដាក់ចេញនូវយុទ្ធសាស្រ្តមួយសមស្របសម្រាប់កម្រិតខេត្ត ដើម្បីប្រើប្រាស់ដីធ្លី និងយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានឲ្យមាននិរន្តភាពដូចខាងក្រោម៖

### ២.៤.៣.១ យុទ្ធសាស្រ្តការប្រើប្រាស់ដីធ្លី

ដើម្បីជំរុញឲ្យការប្រើប្រាស់ដីធ្លីកាន់តែមានការរីកចម្រើននោះ គណៈអភិបាលខេត្ត សហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តនូវយុទ្ធសាស្ត្ររយៈពេលយូររបស់ខ្លួន ដូចខាងក្រោមៈ

- ពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងទីផ្សារដីធ្លី និងទប់ស្កាត់ ឬដោះស្រាយទំនាស់ដីធ្លីទាំងឡាយ
- ផ្សព្វផ្សាយអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លី អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី ច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ក្រសួងបរិស្ថាន
- ផ្ទេរពីដីឯកជនរបស់រដ្ឋទៅឲ្យបុគ្គលឯកជនក្នុងគោលបំណងបម្រើឲ្យតម្រូវការការដាំដុះលក្ខណៈគ្រួសារ និងលំនៅដ្ឋាន
- ពន្លឿនការចេញប័ណ្ណកាន់កាប់ដីធ្លីឲ្យបានចប់ក្នុងរយៈពេល៣ឆ្នាំ ខាងមុខក្នុងខេត្តទាំងមូល ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីការធានាសុវត្ថិភាព
- បន្តពិនិត្យពិនិត្យឡើងវិញ និងដាក់វិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីទំនេររបស់រដ្ឋនិងក្នុងការដោះស្រាយតាមបទបញ្ញត្តិច្បាប់នូវករណីឯកជនកាន់កាប់ដីរដ្ឋ ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត
- បន្តដោះស្រាយជម្លោះដីធ្លី ដោយប្រើប្រាស់យន្តការច្បាប់ ដើម្បីធានាយុត្តិធម៌ដោយគួបផ្សំជាមួយ នឹងយន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ
- បោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះឲ្យបាន១០០% សម្រាប់ការបង្កើន បណ្តាញផ្លូវថ្នល់ ការពង្រីកផ្ទៃដីកសិកម្ម និងលទ្ធភាពធ្វើដំណើរគ្រប់ច្រកល្ហក ក្នុងខេត្តទាំងមូល
- ពង្រឹងការយកចិត្តទុកដាក់របស់មន្ត្រីសុរិយោដី គ្រប់ជាន់ថ្នាក់ឲ្យពង្រឹងក្រមសីលធម៌ សុចរិតភាព តម្លាភាព គណនេយ្យភាព ប្រសិទ្ធិភាព ដើម្បីជំរុញការផ្តល់សេវាចុះបញ្ជីជូនប្រជាពលរដ្ឋ ប្រកបដោយជំនឿទុកចិត្ត។

## ២.៤.៣.២ យុទ្ធសាស្ត្រការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ដើម្បីឲ្យមានចីរភាព និងការកកើតឡើងវិញនៃធនធានធម្មជាតិ ដើម្បីចូលរួមចំណែកការកាត់បន្ថយភាពក្រីក្រនៅក្នុងខេត្ត តាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការធានាឲ្យបាននូវភាពគង់វង្សក្នុងការប្រើប្រាស់ធនធានធម្មជាតិ គណៈអភិបាលខេត្ត សហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ត្រូវ អនុវត្តនូវការគ្រប់គ្រងធនធានធម្មជាតិរបស់ខ្លួន តាមរយៈយុទ្ធសាស្ត្ររយៈពេលយូររបស់ខ្លួន ដូចខាងក្រោមៈ

- ទប់ស្កាត់ការប្រព្រឹត្តបទល្មើសផ្សេងៗ នៃការចាក់ដីលុប ឬបង្រួមផ្ទៃបឹងបួរធម្មជាតិ ទាំងឡាយណាដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច

- ស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ
- បន្តបង្កើត និងពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក
- ទប់ស្កាត់ការនេសាទខុសច្បាប់
- បង្កើនការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ
- បង្កើត និងបង្កើនការពង្រឹងច្បាប់សម្រាប់សហគមន៍ការពារបឹងធម្មជាតិ
- រៀបចំផែនការធ្វើបញ្ជីសារពើភ័ណ្ឌព្រៃឈើ នៅក្នុងតំបន់ព្រៃ សម្បទាន និងសិក្សាវាយតម្លៃផល ប៉ះពាល់បរិស្ថាន
- ទប់ស្កាត់ការបរបាញ់ និងជួញដូរសត្វព្រៃគ្រប់ប្រភេទ
- អប់រំប្រជាពលរដ្ឋឲ្យយល់ពីកាតព្វកិច្ច ការពារសត្វព្រៃ និងព្រៃឈើ និងបញ្ឈប់ការកាប់រានព្រៃដោយខុសច្បាប់
- ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ នឹងចុះដោះស្រាយរាល់ទំនាស់ផ្សេងៗលើផលប្រយោជន៍ពីផលអនុផលព្រៃឈើ ដោយធ្វើឲ្យមានតម្លាភាពនៃការប្រើប្រាស់ និងនិរន្តរភាពធនធានធម្មជាតិ
- ពង្រឹង និងអភិរក្សធនធានធម្មជាតិ តាមរយៈការលើកកម្ពស់ការផ្សារភ្ជាប់ការអភិរក្សធនធាន ទៅនឹងទេសចរណ៍ធម្មជាតិ
- បន្តចាត់វិធានការទប់ស្កាត់ និងបង្ក្រាប ចំពោះការកាប់បំផ្លាញព្រៃឈើ ការឈូសរាន ដីព្រៃ ការធ្វើអាជីវកម្ម ដោយខុសច្បាប់បែបអនាធិបតេយ្យទាំងឡាយណា ។
- អភិរក្សធនធានជីវៈចម្រុះ ការដាំព្រៃឈើឡើងវិញ ការកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់ ព្រមទាំងមានការលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការដាំដុះព្រៃឯកជនដែលមានលក្ខណៈសេដ្ឋកិច្ច ដោយមានបច្ចេកទេសច្បាស់លាស់ពិសេសក្នុងតំបន់ព្រៃរិចរិល
- ពង្រឹងមន្ត្រីរដ្ឋបាលព្រៃឈើគ្រប់ជាន់ថ្នាក់ក្នុងខេត្ត និងការគ្រប់គ្រងរបស់តំបន់ការពារធនធានធម្មជាតិក្នុងខេត្ត (គីរីរម្យ និងឱរ៉ាល់)
- បង្កើតថ្នាលបណ្តុះកូនឈើ នៅសហគមន៍តំបន់ការពារធម្មជាតិ
- ចាត់វិធានការ និងកែលម្អប្រព័ន្ធលូនៅទីប្រជុំជន និងណែនាំដល់រោងចក្រ សហគ្រាស ឧស្សាហកម្ម អាជីវកម្ម សិប្បកម្ម និងអ្នកពាក់ព័ន្ធ អំពីការបញ្ចេញនូវសារធាតុពុល និងការប្រើប្រាស់សារធាតុគីមីកសិកម្ម។
- ផ្គត់ផ្គង់ទឹកស្អាត ឲ្យបានធំទូលំទូលាយដល់ទីប្រជុំជននៃបណ្តាស្រុកផ្សេងៗ
- លើកទឹកចិត្តដល់ក្រុមហ៊ុនប្រមូលសំណល់រឹងសំរាមឲ្យបានគ្រប់ក្រុងស្រុក
- ត្រូវធានាឲ្យមានទីលានចាក់សំណល់សំរាមការកែច្នៃសំរាម និងបង្កើតជាសហគមន៍ប្រមូលសំណល់សំរាម និងបង្កើតឲ្យមានសេវាប្រមូលសំណល់ឲ្យបានគ្រប់ទីប្រជុំជនទាំង

- ពង្រឹងលក្ខណៈបច្ចេកទេសបរិស្ថានដល់ទីលានចាក់សំណល់សំរាម របស់ខេត្ត(ភ្នំកំប៉ូត) និងបង្កើតឲ្យមានទីលានចាក់សំណល់សំរាមគ្រប់ក្រុង ស្រុកទូទាំងខេត្ត ។
- បង្កើតសួនច្បារតាមស្រុកក្រុងយ៉ាងហោចណាស់ឲ្យបានមួយនៅតាមបណ្ដាស្រុកក្រុងទាំង ៨ និងពង្រីក និងបង្កើតថ្មីសម្រាប់ក្រុងច្បារមន ឬបង្កើតសួនច្បារតាមទីប្រជុំជនផ្សេងៗ
- ផាកពិន័យ ឬបញ្ឈប់ចំពោះកសិដ្ឋាន ការដ្ឋាន អាជីវកម្មណាដែលគ្មានច្បាប់ ឬមិនគោរពកិច្ចសន្យាការពារបរិស្ថាន ពិសេសសំណល់រាវដែលក្លិនស្អុយឬសំណល់ជាសារធាតុគីមី
- បណ្ដុះបណ្ដាល ផ្សព្វផ្សាយដល់មន្ត្រីគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋពីការគ្រោះថ្នាក់ផ្សេង ដែលបង្កឡើងដោយសកម្មភាពរបស់មនុស្ស ពីការខ្ជះខ្ជាយនៃការប្រើប្រាស់ថាមពល និងធនធានផ្សេងៗ។

### ២.៤.៤ យុទ្ធសាស្ត្រការគ្រប់គ្រងគ្រោះមហន្តរាយ និងប្រែប្រួលអាកាសធាតុ

ដើម្បីសម្រេចឲ្យបាននូវគោលបំណង គ្រោះមហន្តរាយនានា ត្រូវបានទប់ស្កាត់មានវិធានការណ៍ការពារ និងដោះស្រាយសង្គ្រោះបានទាន់ពេលវេលាខេត្តមានយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ត្រៀមថ្នាំពេទ្យ ថវិកា និងមធ្យោបាយសង្គ្រោះ
- ជួសជុលផ្លូវលំ ផ្លូវចល័តនានា
- ស្ដារប្រឡាយ ដាក់លូ
- រកទីទួលសុវត្ថិភាព
- ជួសជុលសណ្ដារស្ទឹង
- ប្រពន្ធ័ប្រកាសភាពអាសន្ន
- ត្រៀមសម្ភារៈ មធ្យោបាយ សម្រាប់សង្គ្រោះបន្ទាន់
- ត្រៀមម៉ាស៊ីនបូមទឹក និងប្រេង
- ការផ្ដល់ពូជស្រូវ
- ស្ដារប្រឡាយនិង អាងស្ដុកទឹក
- ការត្រៀមសម្ភារៈ សង្គ្រោះ
- សហការណ៏ការពារសុវត្ថិភាពនៅកន្លែងកើតហេតុ
- ផ្ដល់ពត័មានជូនថ្នាក់ខេត្ត
- រៀបចំក្រុមការងារជួយសង្គ្រោះឲ្យទាន់ពេលវេលា

### ២.៤.៥ យុទ្ធសាស្ត្រនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ

#### ២.៤.៥.១ យុទ្ធសាស្ត្រនៃការគ្រប់គ្រងអភិបាលកិច្ចល្អ

ដើម្បីសម្រេចគោលដៅលើការងារគ្រប់គ្រង និងអភិបាលកិច្ចល្អ សេវាសាធារណៈ នឹងត្រូវ

បានផ្តល់ជូនប្រជាពលរដ្ឋគ្រប់ៗគ្នា ដោយមានគុណភាពរហ័សទាន់ពេលវេលា និងតម្លាភាពនៅក្នុងឆ្នាំ២០១៥ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- រៀបចំឲ្យមានយន្តការនៃការចូលរួមដោយស្មើភាពគ្រប់ផ្នែកពាក់ព័ន្ធ
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ដោយការទទួលខុសត្រូវខ្ពស់
- យន្តការរដ្ឋបាល និងកិច្ចអភិវឌ្ឍន៍នានាត្រូវបានពង្រឹងប្រកបដោយតម្លាភាព
- ពង្រឹងការអនុវត្តដើម្បីបំពេញនូវតម្រូវការ និងសំណូមពររបស់មូលដ្ឋាន ប្រកបដោយការទទួលខុសត្រូវខ្ពស់

### ២.៤.៥.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងដែនដី និងស្ថិត

ដើម្បីសម្រេចគោលបំណងលើការងារគ្រប់គ្រងដែនដី សេវាសាធារណៈ នឹងត្រូវបានផ្តល់ជូនប្រជាពលរដ្ឋគ្រប់ៗគ្នា ដោយមានគុណភាពរហ័សទាន់ពេលវេលានិងតម្លាភាពនៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា ៖

- រៀបចំឲ្យមានយន្តការច្រកចេញចូលតែមួយ
- ផ្តល់ឯកសារ និង ទំរង់នានា អំពីការងារអត្រានុកូលដ្ឋានឲ្យបានគ្រប់
- បើកវគ្គផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- បើកវគ្គបណ្តុះបណ្តាល បន្ថែមដល់មន្ត្រីទទួលខុសត្រូវលើការងារអត្រានុកូលដ្ឋាន
- ស្នើសុំសង់សាលាឃុំ សង្កាត់ឲ្យមានគ្រប់ឃុំ សង្កាត់
- ស្នើសុំសង់ប៉ុស្តិ៍រដ្ឋបាល និងបំពាក់នូវឧបករណ៍សម្ភារៈការិយល័យ និងសម្ភារៈបច្ចេកទេស
- ជំរុញការធ្វើអត្តសញ្ញាណប័ណ្ណឲ្យបានទាន់ពេលវេលា និងបានគ្រប់ៗគ្នា
- ចុះអង្កេត និងសិក្សាស្រាវជ្រាវតំកល់ ឯកសារឲ្យបានច្បាស់លាស់គ្រប់មូលដ្ឋាន
- ពង្រឹងការយកចិត្តទុកដាក់ដោះស្រាយបញ្ហាអន្តោប្រវេសន៍ឲ្យទទួលបានលទ្ធផលមានដោយមានវិធានការជំរុញជនបរទេសអន្តោប្រវេសន៍ឲ្យអនុវត្តច្បាប់របស់កម្ពុជាឲ្យមានប្រសិទ្ធិភាព

### ២.៤.៥.៣ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីសម្រេចគោលបំណងក្នុងការបង្ក្រាបបទល្មើសនានាត្រូវបាន១០%ទៀតនៅក្នុងឆ្នាំ ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- ពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព បន្តធ្វើឲ្យបទល្មើសគ្រប់ប្រភេទមានការថយចុះថែមទៀត ជាពិសេសបទល្មើសរំលោភសេពសន្ថវៈ
- ជំរុញបន្ថែមការងារបង្ក្រាបសកម្មភាពក្មេងទំនើងដោយផ្តោតសំខាន់កន្លែងប្រមូលផ្តុំកំសាន្តសប្បាយនៅតាមភូមិ ឃុំ សង្កាត់ របស់ប្រជាពលរដ្ឋ

- ជំរុញការងារប្រយុទ្ធប្រឆាំងការប្រើប្រាស់គ្រឿងញៀន យកចិត្តទុកដាក់ផ្សព្វផ្សាយ អប់រំអំពីច្បាប់ និងគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន
- លើកកម្ពស់ស្មារតីទទួលខុសត្រូវ និងជំរុញសកម្មភាពឲ្យបានខ្លាំងក្លា ការងារបង្ក្រាបបទល្មើសជួញដូរមនុស្ស ដោយប្រមូលផ្តុំ លើវិធានការលុបបំបាត់ការ ធ្វើសកម្មភាពក្រោមរូបភាព អាពិពាហ៍ពិពាហ៍ក្លែងក្លាយ ការនាំពលករទៅបរទេស ការប្រើប្រាស់ពលកម្មលើអនីតិជន និងបង្ក្រាបហ៊ឹងម៉ាត់ការជួញដូរផ្លូវភេទ
- ពង្រឹងការអនុវត្តច្បាប់ស្តីពី ការគ្រប់គ្រងអាវុធជាតិផ្ទុះឲ្យមានប្រសិទ្ធិភាព ដើម្បីរួមចំណែកកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីអាវុធឲ្យបានជាអតិបរមា
- ពង្រឹងចលនាប្រជាការពារ និងបង្កើនការផ្សព្វផ្សាយអំពីគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដល់ស្រទាប់ប្រជាពលរដ្ឋ
- កសាងប៉ុស្តិ៍យាមតាមគោលដៅ និងបំពាក់វិទ្យុទាក់ទង
- បើកវគ្គផ្សព្វផ្សាយច្បាប់ និង ក្រមព្រហ្មទ័ណ្ឌថ្មីឲ្យបានទូលំទូលាយ
- បង្កើនសកម្មភាពល្បាតចល័តក្នុងភូមិសាស្ត្រ

ដើម្បីសម្រេចគោលបំណង គ្រោះថ្នាក់ចរាចរ ត្រូវបានកាត់បន្ថយដល់កម្រិតអប្បបរមានៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា ៖

- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ប្រមូលផ្តុំវិធានការតឹងរឹងចំពោះការបើកបរដោយស្រវឹងស្រាបើកបរលើសល្បឿនកំណត់សកម្មភាពដឹកជញ្ជូនសំពីងសំពោងជិះលើសចំណុះការប្រើប្រាស់រថយន្តខុសបទដ្ឋានបច្ចេកទេស
- ជំរុញការអនុវត្តច្បាប់ចរាចរណ៍ដូចជា ពាក់មួកសុវត្ថិភាពពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពយានយន្តមានពាក់ស្លាកលេខ បើកបរគោរពស្លាកសញ្ញាចរាចរណ៍.....។ល។
- បន្តផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក និងរិតបន្តឹងការអនុវត្តច្បាប់ ការផាកពិន័យ
- បើកវគ្គបណ្តុះបណ្តាលជំនាញបើកបរ
- ដាក់ស្លាកសញ្ញាចរាចរណ៍ និងផ្សព្វផ្សាយអប់រំអំពីសីលធមិសង្គម ផ្សព្វផ្សាយ ទប់ស្កាត់ការសង់សំណង់លើដីចំណីផ្លូវ

ដើម្បីសម្រេចគោលបំណង ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀនបាន៩០% នៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- បើកវគ្គផ្សព្វផ្សាយអំពីផលប៉ះពាល់នៃគ្រឿងញៀន
- បង្កើនវិធានការណ៍បង្ក្រាប់ និង ទប់ស្កាត់រាល់នៃគ្រឿងញៀន
- បង្កើនមជ្ឈមណ្ឌលអប់រំ និង បន្សាបគ្រឿងញៀន
- កំណត់មុខសញ្ញាជួញដូរ និងលក់ថ្នាំញៀនក្នុងភូមិសាស្ត្រ ខេត្ត

ដើម្បីសម្រេចគោលបំណង ទប់ស្កាត់សកម្មភាពក្មេងទំនើង និងល្បែងស៊ីសងបាន១០០% នៅក្នុងឆ្នាំ២០១៥ ខេត្តមានយុទ្ធសាស្ត្រដូចជា៖

- អប់រំ ដល់អាណាព្យាបាលអំពីការគ្រប់គ្រងបុត្រធិតារបស់ខ្លួន
- គ្រប់គ្រងមុខសញ្ញាក្មេងទំនើង និងគ្រឿងញៀន ដើម្បីអប់រំបន្ត
- ចាត់វិធានការណ៍បង្ក្រាបឲ្យបានទាន់ពេលវេលា
- រៀបចំវេទិការសាធារណៈស្តីពីបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈតាមភូមិ ឃុំ
- ជំរុញអាណាព្យាបាលក្មេង សាលារៀន និងសហគមន៍ ឲ្យមានការទំនាក់ទំនងរាយការណ៍ឲ្យគ្នាទៅវិញទៅមក ដើម្បីបង្ការ និងទប់ស្កាត់ក្មេងទំនើង

## ២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ៖

រដ្ឋបាលខេត្ត នឹងខិតខំបន្តពង្រឹងពង្រីកទំនាក់ទំនងជាមួយបណ្តាមន្ទីរ អង្គភាពជុំវិញខេត្ត ផ្នែកឯកជន អង្គការក្រៅរាជរដ្ឋាភិបាល សង្គមស៊ីវិលផ្សេងៗ ធ្វើជាដៃគូអភិវឌ្ឍន៍រួមផ្សំជាមួយមូលនិធិដែលរាជរដ្ឋាភិបាលផ្ទេរឲ្យដើម្បីឲ្យប្រជាពលរដ្ឋទូទាំងខេត្តទទួលបានផលប្រយោជន៍ជាអតិបរមា ពីធនធានដែលមានសម្រាប់កម្មវិធីអភិវឌ្ឍន៍ ។ លទ្ធផលដ៏សំខាន់ដែលជាអាទិភាពចម្បងរបស់ រដ្ឋបាលខេត្ត គឺត្រូវសម្រេចឲ្យបាននូវ(១) កំណើតនៃការផ្ទេរធនធាន សម្រាប់អភិវឌ្ឍន៍ដល់អ្នកត្រូវ ទទួលផលប្រយោជន៍ជាពិសេសជនងាយរងគ្រោះ និងគ្រួសារក្រីក្រ (២) សមត្ថភាពរបស់អង្គភាព មន្ទីរជំនាញ យន្តការនានាក្នុងការផ្តល់នូវកម្មវិធី និងសេវាកម្មនានា ប្រកប ដោយប្រសិទ្ធ ភាព។

ក្នុងការប្រមូលព័ត៌មាន ពីតម្រូវការចំណាយសម្រាប់អនុវត្តគម្រោងជាអាទិភាពនានារបស់ខេត្ត។ ទោះបីជា មន្ទីរអង្គភាពមានថវិកាគាំទ្រខ្លះក៏ដោយ ក៏ថវិកាទាំងនោះពុំទាន់អាចឆ្លើតតបបានជាមួយតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ស្របពេលដែលរដ្ឋបាលខេត្តក៏ពុំទាន់ដឹងថា ខ្លួនអាច មានធនធានមូលនិធីប៉ុន្មានសម្រាប់បម្រើឲ្យកិច្ចអភិវឌ្ឍន៍។

គម្រោងចំណាយរយៈពេលមធ្យមដែលលើកឡើងសម្រាប់ការចំណាយរយៈពេល ៣ឆ្នាំ ពី ២០១១ ដល់ ២០១៣ គ្រាន់តែជាការប៉ាន់ស្មានលើមូលដ្ឋានតម្លៃដែលបានអនុវត្តនាពេលបច្ចុប្បន្នសម្រាប់គិតគូពីតម្លៃនៃគម្រោងអាទិភាពដែលត្រូវ អភិវឌ្ឍន៍សម្រាប់ រយៈពេលខាងលើ ទៅ តាមផ្នែកវិស័យនីមួយៗ។

## តារាងគម្រោងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

| ផ្នែក/វិស័យ | តម្រូវការថវិកា (ឯកតាពាន់រៀល) | | | | ផ្សេងៗ |
|---|---|---|---|---|---|
| | ២០១១ | ២០១២ | ២០១៣ | សរុប | |
| ផ្នែកសេដ្ឋកិច្ច | | | | | |
| ផ្នែកសង្គមកិច្ច | | | | | |
| ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិបរិស្ថាន | | | | | |
| ផ្នែករដ្ឋនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | |
| **សរុប:** | | | | | |

## តារាងក្របខ័ណ្ឌអភិវឌ្ឍន៍
## (ឆ្នាំ២០១១-២០១៥)

**ចក្ខុវិស័យ៖** លើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋឲ្យធូរធារប្រកបដោយសមធម៌ និងសោភ័ណភាព ស្រស់បំព្រង ដើម្បីជំរុញឲ្យមានសន្តិសុខស្បៀង សុខុមាលភាព សមភាពយេនឌ័រ ចំណេះដឹង និងសន្តិសុខសណ្តាប់សាធារណៈ តាមរយៈកំណែទម្រង់លើគ្រប់វិស័យ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ឆ្ពោះទៅកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងតម្លាភាព។

| គោលដៅ និង គោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១៥ | |
| **១- ផ្នែកសេដ្ឋកិច្ច** | | | | |
| **គោលដៅ: ១.១ នៅឆ្នាំ២០១៥ ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ នឹងមានជីវភាពល្អប្រសើរ មានចំណូលប្រចាំឆ្នាំកើនឡើង តាមរយៈលើកកម្ពស់ផលិតភាពកសិកម្ម និងការធ្វើពិពិធកម្មកសិកម្ម** | | | | |
| ១.១.១- គោលបំណងទី១៖ បង្កើនទិន្នផលស្រូវដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឲ្យបានពី ២.៦០ត/ហ.ត នៅឆ្នាំ២០១០ ទៅ៣.១០ ត/ហ.ត នៅឆ្នាំ២០១៥ | ត/ហ.ត | **២.៦០** | **៣.១០** | -កែលំអផលិតកម្មដំណាំស្រូវតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែតាមបែបប្រពលវប្បកម្ម<br>- ផ្សព្វផ្សាយបច្ចេកទេសកែលម្អដី និងការប្រើប្រាស់សម្ភារៈកសិកម្ម<br>- បណ្តុះបណ្តាលបច្ចេកទេសប្រព័ន្ធកសិកម្មចម្រុះ<br>- ចងក្រងសហគមអភិវឌ្ឍន៍កសិកម្ម<br>- ពង្រឹងសមត្ថភាពដល់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ថ្នាក់ភូមិ<br>- ជំរុញ និងផ្សព្វផ្សាយការលើកទឹកចិត្តដល់ |

| | | | | |
|---|---|---|---|---|
| | | | | កសិករផលិតកម្មកសិកម្ម<br>- កែលម្អ និងពង្រីកប្រព័ន្ធធារាសាស្ត្រ |
| ១.១.២-គោលបំណងទី២៖បង្កើនការផលិតស្រូវ និងការនាំអង្ករចេញឱ្យបានពី ២០០០តោននៅឆ្នាំ២០១០ ទៅ ២០០០០តោន នៅឆ្នាំ២០១៥ | តោន | ២០០០ | ២០០០០ | - បណ្តុះបណ្តាលបច្ចេកទេសផលិតកម្មដំណាំស្រូវ<br>-បញ្ចូលពូជមានទិន្នន័យខ្ពស់ និងមានតម្លៃទីផ្សារ ពិសេសពូជទាំងដប់មុខដែលរដ្ឋផ្សព្វផ្សាយ<br>- បណ្តុះបណ្តាលបច្ចេកទេសក្រោយពេលប្រមូលផល និងការទុកដាក់ស្រូវអង្ករ<br>- គាំទ្រផ្នែកឥណទាន<br>- គៀងគរអ្នកវិនិយោគឯកជនដើម្បីកសាងម៉ាស៊ីនកិនស្រូវ ប្រកបដោយគុណភាពខ្ពស់ |
| ១.១.៣-គោលបំណងទី៣៖បង្កើនផលិតកម្ម សត្វដើម្បីធានាការអូសទាញ និងបម្រើម្ហូបអាហារឱ្យបាន១៩.៧១%បន្ថែមទៀតនៅឆ្នាំ២០១៥ | ភាគរយ | ០.២៩ | ២០ | - ការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនិងការផលិតចំណី<br>- បង្កើនសមត្ថភាពភ្នាក់ងារផលិតកម្ម និងបសុព្យាបាល<br>- ពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វ ភូមិ និងពង្រឹងសហគមន៍ ភ្នាក់ងារសុខភាពសត្វ ភូមិ<br>- បង្កើនសកម្មភាពទប់ស្កាត់ ការរីករាលដាលជម្ងឺឆ្លងសត្វ<br>- ផ្សព្វផ្សាយ និងធ្វើការបង្ហាដាំណាំចំណី សត្វ<br>- ពង្រឹងការត្រួតពិនិត្យចរាចរចំណីសត្វ និងបសុឱសថ |
| ១.១.៤-គោលបំណងទី៤៖ បង្កើនការប្រើប្រាស់ឡជីវឧស្ម័ន រួមចំណែកលើកកម្ពស់សុខភាព និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិឱ្យបានពី១,១២២គ្រឿងនៅឆ្នាំ២០១០ ទៅ៣,៥២០គ្រឿងនៅឆ្នាំ២០១៥ | គ្រឿង | ១,១២២ | ៣,៥២០ | -លើកទឹកចិត្តកសិករ ប្រើប្រាស់បម្លែងលាមកសត្វ មកជាថាមពលដើម្បីប្រើប្រាស់ក្នុងគ្រួសារ<br>-កៀរគរអង្គការនានានៃប្រភពថវិការជួយ ទ្រទ្រង់<br>-បណ្តុះបណ្តាលកសិករ បង្កើតសួនបន្លែ គ្រួសារដោយប្រើប្រាស់ កាកសំណល់ ឡជីវឧស្ម័ន |
| ១.១.៥-គោលបំណងទី៥៖បង្កើនផលិតកម្មដំណាំបន្លែឱ្យបានពី២៤.៦៨% បន្ថែមទៀតនៅឆ្នាំ២០១៥ | ភាគរយ | ០.៣២ | ២៥ | -បណ្តុះបណ្តាលបច្ចេកទេសជាដំណាំបន្លែធម្មជាតិ ឈានទៅការដាំបន្លែសរីរាង្គបម្រើ ឱ្យទីផ្សារ<br>-ផ្សព្វផ្សាយអប់រំកសិករលើការកាត់បន្ថយការប្រើប្រាស់ថ្នាំគីមីពុល<br>-លើកទឹកចិត្តនិងផ្សព្វផ្សាយព័ត៌មានទីផ្សារឱ្យ |

| | | | | |
|---|---|---|---|---|
| | | | | ដល់កសិករ<br>-បញ្ចូលពូជបន្លែល្អ មានគុណភាព និងមានតម្លៃ នៅទីផ្សារ<br>-ស្តារ និងជួសជុលប្រព័ន្ធស្រោចស្រព |
